សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការធ្វើចំណាកស្រុករបស់ប្រជាជនខ្មែរ

ស្រាវជ្រាវចាប់ពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា **ទេព ឆលីកា**
កញ្ញា **ខិន ស្រីលាប**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ឈុន ណារ៉េត**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី ១២

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ ជិន ស្រីលាប និងឈ្មោះ ទេព ឆលីកា ជានិស្សិតថ្នាក់បរិញ្ញាបត្រឆ្នាំទី ៤ ជំនាញរដ្ឋបាលសាធារណៈ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅក្នុងឆ្នាំសិក្សា២០១៨ - ២០១៩

**យើងខ្ញុំសូមគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**

- លោកឪពុក **ជិន ថន** និងអ្នកម្តាយ **ម៉ុន ស៊ុនណា** ដែលត្រូវជាឪពុកម្តាយរបស់នាងខ្ញុំ **ជិន ស្រីលាប**
- លោកឪពុក **ស៊ឹម សោភ័ណ្ឌ** និងវិញ្ញាណក្ខន្ធ័អ្នកម្តាយ **ឃុន ចន្ធូ** ដែលត្រូវជាឪពុកម្តាយរបស់នាងខ្ញុំ **ទេព ឆលីកា**

លោកឪពុក និងអ្នកម្តាយដែលបានផ្តល់កំណើត និងជីវិតដែលពោពេញទៅអត្ថន័យ និងសុភមង្គល ។ ក្រៅពីផ្តល់ជីវិតដល់រូបកូន លោក ឪពុក និងអ្នកម្តាយបានលះបង់ពេលវេលា កម្លាំងកាយ កម្លាំងចិត្ត និងសេចក្តីសុខផ្ទាល់ខ្លួនក្នុងការយកចិត្តទុកដាក់ចិញ្ចឹមបីបាច់ថែរក្សា ផ្តល់ភាពកក់ក្តៅ ទូន្មានប្រៀន ប្រដៅអប់រំកូនឲ្យដើរក្នុងផ្លូវល្អ ចេះជួយដល់សង្គម ទំនុកបម្រុងកូនរហូតដល់បញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ និងដំបូន្មានល្អៗដល់រូបកូនដើម្បីជាទុនក្នុងការរស់នៅក្នុងសង្គម ។ ទង្វើរ និងសេចក្តីស្រលាញ់ របស់លោកទាំងពីរបានធ្វើឲ្យកូនមិនអាចបំភ្លេចបាននូវអំពើល្អ និងគុណូបការៈដ៏សែនធំរកអ្វីប្រៀបផ្ទឹមពុំបាន ។

លោកនាយក នាយករង លោកគ្រូ អ្នកគ្រូ សាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ ដែលបានបង្ហាត់បង្ហាញ ជាគ្រឹះសម្រាប់សិក្សានៅសាកលវិទ្យាល័យ

**ឯកឧត្តមសាកលវិទ្យាធិការ** សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ព្រមទាំងសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តពន្យល់ និងអប់រំដល់រូបយើងខ្ញុំ ។

សាស្ត្រាចារ្យបណ្ឌិត **ឈុន ណារ៉េត** ដែលជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណានេះដែលលោកសាស្ត្រាចារ្យបានចំណាយកម្លាំងកាយចិត្ត និងពេលវេលាដ៏មានតម្លៃរបស់លោកក្នុងការតម្រង់ផ្លូវ និងណែនាំផ្តល់នូវគំនិតយោបល់ ដំបូន្មាន និងវិធីសាស្ត្រល្អៗពាក់ព័ន្ធនឹងប្រធានបទ និងកែលម្អចំណុចខ្វះខាតរបស់យើងខ្ញុំទាំងពីរ តាំងពីដើមរហូតដល់យើងខ្ញុំទាំងពីរអាចចងក្រងនូវស្នាដៃនេះឡើង ។

បងប្អូន មិត្តភក្តិ គ្រូបណ្តុះបណ្តាលទាំងអស់ ដែលបានណែនាំ ផ្តល់ជាគំនិតយោបល់ល្អៗកន្លងមក និងតែងតែលើកទឹកចិត្តដល់រូបយើងខ្ញុំទាំងពីរ ។

ជាចុងបញ្ចប់ យើងខ្ញុំសូមប្រសិទ្ធពរជ័យ ដល់អ្នកមានគុណ ឯកឧត្តម លោកជំទាវ លោក លោកស្រី ញាតិមិត្ត បងប្អូន និងសាស្ត្រាចារ្យទាំងអស់ដែលបានចូលរួមចំណែកឲ្យសារណាបញ្ចប់ការសិក្សាស្តីពី ការធ្វើចំណាកស្រុក ឲ្យបានលេចចេញជារូបរាងឡើង សូមឲ្យមានសុខភាពល្អ មានសុភមង្គល និង មានអាយុយឿនយូរគ្រប់ៗគ្នា។

# អារម្ភកថា

សួស្តីមិត្តៗនិស្សិត និងមិត្តៗអ្នកអានទាំងអស់គ្នា អ្នកសិក្សាស្រាវជ្រាវ និងអ្នកដែលចង់ស្វែងយល់នូវឯកសារផ្សេងៗជាទីរាប់អាន នេះជាសៀវភៅសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈរបស់យើងខ្ញុំដែលបានធ្វើការស្រាវជ្រាវដកស្រង់ និងចងក្រងឡើង និងជ្រើសរើសយកប្រធានបទសារណាអំពី ការធ្វើចំណាកស្រុក ក្នុងរយៈពេលបីខែកន្លងមក សម្រាប់ការបញ្ចប់ថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ដែលបានសិក្សាអស់រយៈពេល៤ឆ្នាំកន្លងមក ។

យើងខ្ញុំជឿជាក់ថា ការស្រាវជ្រាវមួយនេះអាចជាជំនួយដល់អ្នកសិក្សាស្វែងយល់ ក៏ដូចជាអ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយជាក់ជាពុំខាន ។ ការដែលយើងខ្ញុំជ្រើសរើសប្រធានបទនេះដើម្បីធ្វើការសិក្សាស្រាវជ្រាវ គឺពឹងផ្អែកលើសមត្ថភាពផ្ទាល់ខ្លួន ឯកសារមូលដ្ឋានដទៃជាច្រើនទៀត បូករួមជាមួយកត្តាដែល ប្រជាជនចំណាកស្រុកកាន់តែកើនឡើង ស្របពេលដែលក្នុងប្រទេសក៏មានការងារ និងប្រាក់ខែសមរម្យផងនោះ ដើម្បីស្រាយជាចំងល់ដល់យើងខ្ញុំ និងមិត្តអ្នកអាន ដែលមានបំណងចង់ធ្វើការស្វែងយល់អំពីបញ្ហាចំណាកស្រុកនេះ និងធ្វើយ៉ាងណាដើម្បីជួយដល់ប្រជាជនចំណាកស្រុកមានជីវភាពកាន់តែប្រសើរ និងគ្មានការរំលោភបំពានដោយប្រការណាមួយ ។

គ្មានអ្វីល្អឥតខ្ចោះនោះឡើយ កំហុសនៅតែកើតមាន ដូច្នេះក្នុងនាមយើងខ្ញុំ ជាអ្នកចងក្រងឯកសារនេះ កំហុសឆ្គងដែលកើតឡើងដោយអចេតនា ទាំងការប្រើពាក្យពេចន៍ ទាំងអក្ខរាវិរុទ្ធ ទាំងខ្លឹមសារ ឬអត្ថន័យនៅក្នុងអត្ថបទនេះក្តី ជៀសមិនផុតឡើយ ។ សូមមេត្តាអធ្យាស្រ័យ និងជួយកែតម្រូវដើម្បីឲ្យស្នាដៃមួយនេះកាន់តែល្អប្រសើរ យើងខ្ញុំរង់ចាំទទួលនូវការរិះគន់ពីសំណាក់មិត្តអ្នកអាន អ្នកសិក្សាស្រាវជ្រាវ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ មិត្តរួមជំនាន់ និងប្អូនៗជំនាន់ក្រោយ និងស្ថាបនាក្នុងន័យកែលំអដើម្បីឲ្យអត្ថបទមួយនេះកាន់តែល្អ មានសុក្រឹតភាព ។

ជាចុងបញ្ចប់យើងខ្ញុំសូមជូនពរដល់ មិត្តអ្នកអាន អ្នកសិក្សាស្រាវជ្រាវ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងមិត្តរួមជំនាន់ ទទួលបាននូវពរទាំងឡាយបួនប្រការ សម្បត្តិបី អរិយទ្រព្យប្រាំពីរ និងមានក្តីសុខ សំណាងល្អគ្រប់ពេលវេលា ជោគជ័យលើការសិក្សា និងជោគជ័យនូវគោលបំណងដែលប៉ងប្រាថ្នាគ្រប់គ្នាៗ ។

# មាតិកា

ទំព័រ

## សេចក្តីផ្តើម


១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ៣
៣. គោលបំណងនៃការស្រាវជ្រាវ ........ ៣
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ៤
៥. សារៈប្រយោជន៍នៃការសិក្សាស្រាវជ្រាវ ........ ៤
៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៤
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤
**ជំពូកទី ១៖ ទ្រឹស្តី និងស្ថានភាពនៃការធ្វើចំណាកស្រុក** ........ ៥
**១.១ ទ្រឹស្តីពលកម្មចំណាកស្រុក** ........ ៥
១.១.១ និយមន័យ ........ ៥
១.១.២ ទ្រឹស្តីសេដ្ឋកិច្ចសមហេតុផល ........ ៥
១.១.៣ ទ្រឹស្តីវិស័យពីរ ........ ៦
១.១.៤ ទ្រឹស្តីកំណើនមានតុល្យភាព និងទ្រឹស្តីអភិវឌ្ឍន៍មិនស្របគ្នា ........ ៦
**១.២ ស្ថានភាពទូទៅនៃការធ្វើចំណាកស្រុកនៅកម្ពុជា** ........ ៧
១.២.១ ការធ្វើចំណាកស្រុកពីជនបទមកកាន់ទីក្រុង ........ ៨
១.២.២ ការធ្វើចំណាកស្រុកទៅក្រៅប្រទេស ........ ៩
**១.៣ ក្រសួង និងស្ថាប័នពាក់ព័ន្ធ នៅក្នុងការគ្រប់គ្រងពលកម្មចំណាកស្រុក** ........ ៩
១.៣.១ អង្គការអន្តរជាតិ ........ ១០
១.៣.២ អង្គការក្រៅរដ្ឋាភិបាល ........ ១០
**ជំពូកទី ២៖ មូលហេតុ និងផលប៉ះពាល់នៃការធ្វើចំណាកស្រុក** ........ ១១
**២.១ មូលហេតុនៃការធ្វើចំណាកស្រុក** ........ ១១
២.១.១ កត្តាជុំរុញ ........ ១១
២.១.១.១ ភាពក្រីក្រ ........ ១១
២.១.១.២ ភាពគ្មានដីធ្លី ........ ១១

២.១.១.៣ បំណុល ........ ១១
២.១.១.៤ គ្រោះធម្មជាតិ ........ ១២
២.១.១.៥ ការហិនហោចធនធានធម្មជាតិ ........ ១២
២.១.២ កត្តាទាក់ទាញ ........ ១២
២.១.២.១ ឧស្សាហកម្ម ........ ១២
២.១.២.២ ឱកាសការងារ ........ ១២
២.១.២.៣ ការធ្វើចំណាកស្រុកតាមរដូវ ........ ១៣
**២.២ ប្រភេទនៃការធ្វើចំណាកស្រុក** ........ ១៣
២.២.១ ចំណាកស្រុកនៅក្នុងប្រទេស ........ ១៣
២.២.២ ចំណាកស្រុកទៅក្រៅប្រទេស ........ ១៣
២.២.៣ ចំណាកស្រុកទៅក្រៅប្រទេសដោយស្របច្បាប់ ........ ១៤
២.២.៤ ចំណាកស្រុកទៅក្រៅប្រទេសដោយមិនស្របច្បាប់ ........ ១៤
២.៣ ទំនាក់ទំនងសេដ្ឋកិច្ច និងចំណាកស្រុក ........ ១៦
២.៣.១. ការកាត់បន្ថយភាពក្រីក្រ ........ ១៦
២.៣.១.១ តួនាទីនៃកម្រៃពលកម្មនៅក្នុងសេដ្ឋកិច្ច ........ ១៦
២.៣.១.២ ប្រភពហរិញ្ញវត្ថុ ........ ១៦
២.៣.១.៣ ប្រាក់ផ្ញើត្រឡប់មកផ្ទះ ........ ១៦
២.៣.១.៤ ឥទ្ធិពលនៃការធ្វើចំណាកស្រុក នៅក្នុងការអភិវឌ្ឍន៍សហគមន៍ ........ ១៧
**២.៤ សង្គម និងចំណាកស្រុក** ........ ១៧
២.៤.១ ចំណាកស្រុក និង ការកាត់បន្ថយភាពគ្មានការងារធ្វើក្នុងស្រុក ........ ១៨
**២.៥ . ផលប៉ះពាល់នៃការធ្វើចំណាកស្រុក** ........ ១៨
២.៥.១ ផលវិជ្ជមាន ........ ១៨
២.៥.២.ផលអវិជ្ជមាន ........ ១៩
២.៥.២.១ ផលប៉ះពាល់លើគ្រួសារ និងសហគមន៍ដែលមានសមាជិកធ្វើចំណាកស្រុក ........ ២០
២.៥.២.២ ផលប៉ះពាល់លើសុភមង្គលគ្រួសារ ........ ២០
២.៥.២.៣ ផលប៉ះពាល់លើកម្លាំងពលកម្មនៅក្នុងគ្រួសារ ........ ២០
២.៥.២.៤ ផលប៉ះពាល់នៃចំណាកស្រុកទៅលើតំបន់ដែលគេចាកចេញ ........ ២១
២.៥.២.៥ ផលប៉ះពាល់នៃការធ្វើចំណាកស្រុកមកលើកុមារ ........ ២១

**២.៦ បញ្ហាប្រឈម** ............ ២៣
២.៦.១ ការជួញដូរមនុស្ស ............ ២៤
២.៦.១.១ ការជួញដូរតាមរយៈអាពាហ៍ពិពាហ៍ ............ ២៥
២.៦.១.២ ពលកម្មដោយបង្ខំលើនាវានេសាទ ............ ២៦
២.៦.១.៣ ពលកម្មដោយបង្ខំតាមរយៈការងារតាមផ្ទះ ............ ២៦
២.៦.១.៤ ការបង្ខំអោយសុំទាន ............ ២៦
**២.៧ ផលប្រយោជន៍នៃការធ្វើចំណាកស្រុក** ............ ២៦
**២.៨ ផលវិបាកនៃការធ្វើចំណាកស្រុក** ............ ២៩
២.៨.១ ផលវិបាកនៃការធ្វើចំណាកស្រុកពីជនបទកាន់ទីក្រុង ............ ២៩
២.៨.២ ផលវិបាកនៃការធ្វើចំណាកស្រុកទៅក្រៅប្រទេស ............ ២៩
**ជំពូកទី ៣៖ វិធានការ និងដំណោះស្រាយនៃការធ្វើចំណាកស្រុក** ............ ៣០
**៣.១ ការគ្រប់គ្រងការងាររបស់ជនចំណាកស្រុក** ............ ៣០
៣.១.១ ការអភិវឌ្ឍមុខរបរនៅក្នុងប្រទេស ............ ៣០
៣.១.២ ការអភិវឌ្ឍមុខរបរនៅខាងក្រៅប្រទេស ............ ៣០
៣.១.៣ ការអភិវឌ្ឍន៍ និងបទបញ្ញាផ្សេងៗ ............ ៣១
**៣.២ ការធ្វើកិច្ចសហប្រតិបត្តិការ** ............ ៣១
៣.២.១ កិច្ចសហប្រតិបត្តិការទ្វេរភាគី ............ ៣១
៣.២.២ កិច្ចសហប្រតិបត្តិការអន្តរជាតិ ............ ៣២
**៣.៣ វិធានការទប់ស្កាត់** ............ ៣២
៣.៣.១ គោលនយោបាយរាជរដ្ឋាភិបាល ............ ៣២
៣.៣.២ គោលនយោបាយជាតិស្ដីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥ ............ ៣២
**៣.៤ ដំណោះស្រាយ** ............ ៣៥
៣.៤.១ ដំណោះស្រាយបញ្ហាចំណាកស្រុក ............ ៣៥
៣.៤.២ ចំណុចសំខាន់ៗគួរយល់ដឹងមុនពេលធ្វើចំណាកស្រុក ............ ៣៦
៣.៤.៣ សុវត្ថិភាពក្នុងការធ្វើចំណាកស្រុក ............ ៣៦
៣.៤.៤ ការងារដែលប្រជាជនអាចធ្វើបាននៅក្នុងសហគមន៍របស់ខ្លួន ............ ៣៧

**៣.៥ ករណីសិក្សា** ........................................ ៣៧
**សេចក្តីសន្និដ្ឋាន** ........................................ ៤០
**អនុសាសន៍** ........................................ ៤១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមួយដែលមានប្រវត្តិសាស្ត្រដ៏រុងរឿង ហើយក៏ធ្លាប់ជួបប្រទះសង្គ្រាមផ្ទៃក្នុង ក៏ដូចជាសង្គ្រាមជាមួយប្រទេសដ៏ទៃទៀតផងដែរ លើសពីនេះទៅទៀតកម្ពុជាក៏ធ្លាប់ធ្លាក់ក្នុងរបបដ៏ខ្មៅងងឹត គឺរបបប្រល័យពូជសាសន៍ ក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែលធ្វើឲ្យសេដ្ឋកិច្ច ប្រទេសកម្ពុជាធ្លាក់ក្នុងកម្រិតសូន្យ។ ប្រជាជនមួយចំនួនរត់ភៀសខ្លួនទៅក្រៅប្រទេស ដែលយើងអាច និយាយម្យ៉ាងទៀតថាចំណាកស្រុក ឬទេសន្តរប្រវេសន៍។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយកម្ពុជាបានរើបម្រាស់ រួចផុតពីរបបទាំងនោះ។ បន្ទាប់ពីប្រទេសកម្ពុជាបានងើបមុខឡើងវិញ ហើយកម្ពុជាបានផ្លាស់ប្ដូរពីរបបសេដ្ឋកិច្ចផែនការទៅសេដ្ឋកិច្ចទីផ្សារសេរីព្រមទាំងបានធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុង និងក្រៅតំបន់មកធ្វើអោយកំនើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាមានការកើនឡើងជារៀងរាល់ឆ្នាំ។

តាំងពីដើមរហូតមកដល់បច្ចុប្បន្ននេះ ប្រជាជនមួយដែលរស់នៅតាមតំបន់ដាច់ស្រយ៉ាល់ ឬនៅតាមបណ្ដាខេត្តឆ្ងាយៗដែលមានជីវភាពក្រីក្រ ប្រកបរបរចិញ្ចឹមជីវិតដូចជា ការធ្វើកសិកម្ម ដាំដំណាំផលិតរបស់ប្រើប្រាស់ដោយដៃ នេសាទ និងចិញ្ចឹមសត្វជាដើម ចំណែកឯគ្រួសារខ្លះមានសមាជិកគ្រួសារច្រើននាក់ ប៉ុន្តែគ្មានចំណូលគ្រប់គ្រាន់ក្នុងការចំណាយសម្រាប់ជីវភាពគ្រួសារ។ ពួកគេបានសម្រេចចិត្ត ឬបង្ខំចិត្តធ្វើចំណាកស្រុកទៅស្វែងរកការងារនៅទីក្រុង ឬទីប្រជុំជន និងអាចធ្វើចំណាកស្រុកទៅក្រៅប្រទេស ដើម្បីជួយសម្រាលបន្ទុកគ្រួសាររបស់ពួកគេជាជាងរស់នៅក្នុងជីវភាពទីទាល់ក្រ។ ភាគច្រើននៃកំលាំងពលកម្មទាំងនេះជាយុវជនវ័យក្មេងដែលមានចំណេះតិចតួច ឬ មានចំណេះដឹងមិនគ្រប់គ្រាន់ទៅនឹងតំរូវការទីផ្សារការងារ។ ដូច្នេះពួកគេត្រូវធ្វើការក្រោមរូបភាពផ្សេងៗដើម្បីទទួលបានប្រាក់ចំនូលសំរាប់ធ្វើការផ្គត់ផ្គង់ជីវភាពគ្រួសាររបស់ពួកគេ។

ចំណាកស្រុក គឺជាការផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយផ្សេងទៀត ដោយសារជីវភាពរស់ដែលមានការបង្ខិតបង្ខំ ឬដោយការស្ម័គ្រចិត្ត។ ការធ្វើចំណាកស្រុកមានការបែកចេញជាពីរប្រភេទ គឺចំណាកស្រុកនៅពីជនបទមកកាន់ទីក្រុង និងចំណាកស្រុកទៅក្រៅប្រទេស។ ហើយចំណាកស្រុកទៅក្រៅប្រទេសនោះ មានពីរប្រភេទ គឺចំណាកស្រុកទៅក្រៅប្រទេសដោយស្របច្បាប់ និងចំណាកស្រុកទៅក្រៅប្រទេសដោយមិនស្របច្បាប់។ ការធ្វើចំណាកស្រុកទៅក្រៅប្រទេសដោយ

ស្របច្បាប់គឺមានផលប្រយោជន៍ដល់គ្រួសារ និងប្រទេសជាតិហើយពុំសូវផ្ដល់ជាផលអវិជ្ជមានច្រើនទេ។ ប៉ុន្តែផ្ទុយមកវិញការធ្វើចំណាកស្រុកទៅក្រៅប្រទេសដោយមិនស្របច្បាប់ គឺ

បង្កើតជាបញ្ហាសម្រាប់ខ្លួនឯងផ្ទាល់ គ្រួសារ និងប្រទេសជាតិផងដែរ។ ការធ្វើចំណាកស្រុកនៅតំបន់ខ្លះ គឺជាការពេញនិយមមួយដែលភាគច្រើនយុវជនមានភាពទាក់ទាញពីប្រទេសជិតខាងដោយភាពជឿនលឿន ភាពសម្បូរសប្បាយ និងមានអ្នកស្គាល់នៅភូមិស្រុក ជាមួយដែលទៅធ្វើការនៅក្រៅប្រទេសនោះក៏សម្រេចចិត្តធ្វើចំណាកស្រុកដោយមិនស្របច្បាប់។

ការធ្វើចំណាកស្រុកដោយមិនស្របច្បាប់ គឺនៅតែបញ្ហាសម្រាប់កម្ពុជា ប៉ុន្តែទោះជាយ៉ាងណាក៏ដោយរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាស្ថាប័ន អង្គការ អង្គភាពពាក់ព័ន្ធផ្សេងៗបាននឹងកំពុងរិះរកវិធានការទប់ស្កាត់ និងដំណោះស្រាយជាច្រើនសម្រាប់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីបញ្ហាចំណាកស្រុកនេះយ៉ាងម៉ឺមាញឹកផងដែរ ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

នៅក្នុងការជ្រើសយកប្រធានបទ " ការធ្វើចំណាកស្រុក " នេះមកសិក្សា គឺដើម្បីធ្វើការស្វែងយល់ឲ្យកាន់តែច្បាស់អំពីគុណវិបត្តិមួយចំនួនដូចជា ការធ្វើចំណាកស្រុកនេះពិតជាលើកស្ទួយសេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចគ្រួសារបាន ឬមិនបាន។ តើការធ្វើចំណាកស្រុកនេះមានផលប៉ះពាល់អ្វីខ្លះទៅដល់សង្គម និងប្រជាជន? តើការធ្វើចំណាកស្រុកក្នុងប្រទេស និងចំណាកស្រុកទៅក្រៅប្រទេសមួយណាប្រសើរជាង? តើគ្រួសារដែលមានសមាជិកគ្រួសារធ្វើចំណាកស្រុក និងគ្រួសារដែលគ្មានសមាជិកគ្រួសារធ្វើចំណាកស្រុក មួយណាគ្រាន់បើជាង? តើមានភាពងាយរងគ្រោះអ្វីខ្លះដែលកើតមានចំពោះគ្រួសាររបស់អ្នកធ្វើចំណាកស្រុក? តើមានការដោះស្រាយបញ្ហាចំណាកស្រុកនេះបែបណាខ្លះពីសំណាក់រាជរដ្ឋាភិបាល ក៏ដូចជាអង្គការពាក់ព័ន្ធផ្សេងៗ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនៃប្រធានបទខាងលើនេះធ្វើឡើងក្នុងគោលបំណងដើម្បីយល់ដឹងកាន់តែច្បាស់អំពីបញ្ហានៃការធ្វើចំណាកស្រុក ក៏ដូចជាមូលហេតុនៃការធ្វើចំណាកស្រុករបស់ប្រជាជនខ្មែរទាំងចំណាកស្រុកក្នុងប្រទេស និងចំណាកស្រុកទៅក្រៅប្រទេស ព្រមទាំងស្វែងយល់អំពីគុណប្រយោជន៍ និង គុណវិបត្តិនៃចំណាកស្រុក ដើម្បីរិះរកវិធានការ និងដំណោះស្រាយលើបញ្ហាចំណាកស្រុកនេះក្នុងគោលបំណងធ្វើយ៉ាងណាឲប្រជាពលរដ្ឋ ដែលធ្វើចំណាកស្រុកទទួលបាននូវសុវត្ថិភាពជៀសផុតពីបញ្ហានានា ដូចជា ការរំលោភបំពានផ្លូវភេទ ការជួញដូរមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្មជាដើម ថែមទាំងផ្តល់ជូននូវដំណោះស្រាយដល់ប្រជាពលរដ្ឋដែលមានភាពក្រីក្រដើម្បីជៀសផុតពីការធ្វើចំណាកស្រុកផងដែរ។

### ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវនៃប្រធានបទនេះ គឺធ្វើឡើងដោយផ្តោតទៅលើការធ្វើចំណាកស្រុកនៅកម្ពុជាដែលនិយាយជារួមអំពី ផលប្រយោជន៍ ផលប៉ះពាល់ មូលហេតុចំបងនៃការធ្វើចំណាកស្រុកដែលជាតួនាទីនៅក្នុងការគ្រប់គ្រង និងដំណោះស្រាយរបស់រាជរដ្ឋាភិបាល ក្រសួង និងស្ថាប័នពាក់ព័ន្ធ អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ដែលពួកគេបានធ្វើ សកម្មភាពផ្សេងៗគ្នាដើម្បីសម្រួលដល់ការគ្រប់គ្រង និងការពារពលករចំណាកស្រុកពីបញ្ហាផ្សេងៗ ពួកគេបានធ្វើការយ៉ាងសកម្ម នៅក្នុងការដោះស្រាយបញ្ហារបស់ជនចំណាកស្រុកទាំងក្នុង និងក្រៅប្រទេស។

### ៥. សារៈប្រយោជន៍នៃការសិក្សាស្រាវជ្រាវ

ចំពោះសារៈប្រយោជន៍ក្នុងការសិក្សាស្រាវជ្រាវ ទៅលើប្រធានបទនេះនឹងធ្វើឲ្យយើងមានការយល់ដឹងកាន់តែទូលំទូលាយ អំពីបញ្ហាចំណាកស្រុកដែលប្រទេសកម្ពុជាយើង កំពុងតែជួបប្រទះនាពេលបច្ចុប្បន្ននេះ។ មិនតែប៉ុណ្ណោះ ការសិក្សាស្រាវជ្រាវនេះនឹងផ្តល់ឲ្យអ្នកសិក្សាជំនាន់ក្រោយយកទៅសិក្សា ដើម្បីទទួលបានចំណេះដឹងបន្ថែម ដើម្បីបំពេញនូវសេចក្តីត្រូវការ ក៏ដូចជាអាចជួយបំពេញនូវចន្លោះខ្វះខាតនានារបស់ពួកគេបាន។

### ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ទិន្នន័យ និងឯកសារដែលក្រុមស្រាវជ្រាវយើងប្រមូលបាន ដើម្បីសម្រេចបានជាសមិទ្ធិផលនៃស្នាដៃក្រោមប្រធានបទមួយនេះឡើង គឺយើងបានធ្វើការប្រមូលពីប្រភពផ្សេងៗដូចជា ៖

- ទិន្នន័យ និងឯកសារ ដែលបានដកស្រង់ចំពោះខ្លឹមសារចាំបាច់ និងសំខាន់ៗដែលមាននៅក្នុងច្បាប់ អនុក្រឹត្យ ក្រសួង ស្ថាប័ន អង្គការជាតិ និងអន្តរជាតិ ឯកសារដែលពាក់ព័ន្ធនឹងការធ្វើចំណាកស្រុកនៅក្នុងបណ្ណាល័យនានានៅរាជធានីភ្នំពេញ ព្រមទាំងទិន្នន័យមួយចំនួននៅក្នុងគេហទំព័ររបស់ក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ។
- ការពន្យល់ណែនាំ និងផ្តល់ជាមតិយោបល់ពីសំណាក់សាស្ត្រាចារ្យដឹកនាំ។
- ការធ្វើបទសម្ភាសន៍ផ្ទាល់ពីអ្នកដែលធ្លាប់ធ្វើចំណាកស្រុក។

### ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនៃសារណានេះ មានរចនាសម្ព័ន្ធដូចតទៅ ៖

- សេចក្តីផ្តើម
- ជំពូកទី ១ ទ្រឹស្តី និងស្ថានភាពនៃការធ្វើចំណាកស្រុក
- ជំពូកទី ២ មូលហេតុ និងផលប៉ះពាល់នៃការធ្វើចំណាកស្រុក
- ជំពូកទី ៣ វិធានការ និងដំណោះស្រាយនៃការធ្វើចំណាកស្រុក

- សន្និដ្ឋាន
- អនុសាសន៍
- ឯកសារយោង
- ឧបសម្ព័ន្ធ

# ជំពូកទី ១

# ទ្រឹស្តី និងស្ថានភាពនៃការធ្វើចំណាកស្រុក

## ១.១ ទ្រឹស្តីពលកម្មចំណាកស្រុក

ចំណាកស្រុកមាននិយមន័យទូលំទូលាយណាស់ ដោយជាទូទៅការកំណត់និយមន័យ គឺមានលក្ខណៈ ផ្សេងៗគ្នាដោយផ្អែកលើបែបបទ និងកាលៈទេសៈ។ មានទ្រឹស្តីជាច្រើនដែលនិយាយអំពី លំនាំនៃពលកម្ម ចំណាកស្រុក ឬលំនាំនៃការធ្វើចំណាកស្រុក។ ទ្រឹស្តីទាំងនោះមានដូចជា ទ្រឹស្តីសេដ្ឋកិច្ចសមហេតុផល ទ្រឹស្តីវិស័យពីរ និងទ្រឹស្តីកំណើនមានតុល្យភាព ទ្រឹស្តីអភិវឌ្ឍន៍មិនស្របគ្នា។

### ១.១.១ និយមន័យ

អត្ថន័យនៃពាក្យ ពលករចំណាកស្រុកមិនត្រូវបានកំណត់ជាក់លាក់ជាលក្ខណៈសកលនៅឡើយទេ រហូតមកដល់ពេលនេះ។ អន្តន័យពលករចំណាកស្រុកគឺ សំដៅលើបុគ្គល និងសមាជិកក្រុមគ្រួសារដែលផ្លាស់ទីទៅកាន់បណ្តាលប្រទេស ឬតំបន់ផ្សេងទៀតក្នុងគោលបំណងធ្វើឲ្យជីវភាពធនធាន ឬលក្ខខណ្ឌសង្គមសម្រាប់ខ្លួនផ្ទាល់មានភាពប្រសើរឡើង ព្រមទាំងបង្កើតនូវក្តីសង្ឃឹមសម្រាប់ខ្លួនគេនិងក្រុមគ្រួសាររបស់ពួកគេ។[1]

### ១.១.២ ទ្រឹស្តីសេដ្ឋកិច្ចសមហេតុផល

ការសិក្សាភាគច្រើនអំពីចំណាកស្រុក បានសង្កត់ធ្ងន់លើហេតុផលរបស់ប្រជាជនចំណាកស្រុក។ លោក Todaro សន្មតថា ជនចំណាកស្រុកធ្វើសកម្មភាពជាលក្ខណៈបុគ្គល ដោយផ្អែកលើផលប្រយោជន៍ផ្ទាល់ខ្លួននៃសេដ្ឋកិច្ចសមហេតុផល។ មានន័យថាការសម្រេចចិត្តធ្វើចំណាកស្រុកគឺផ្អែកលើការរំពឹងទុកពី "ផលចំណេញនៃការងារ" នៅកន្លែងគោលដៅដែលត្រូវទៅព្រមទាំង "ការវិភាគចំណាយ-ផលចំណេញ" ក្នុងគំនិតរបស់ជនចំណាកស្រុក។ យោងតាមទស្សនៈនេះការសម្រេចចិត្តធ្វើចំណាកស្រុក គឺជាការសម្រេចចិត្តបែបសេដ្ឋកិច្ចសមហេតុផលមួយ ដោយឈរជាសំខាន់លើកម្រិតខុសគ្នានៃប្រាក់បៀវត្សរ៍នៅតំបន់កំពុងរស់នៅ និងគោលដៅត្រូវទៅ។ សរុបមក គេសម្រេចចិត្តធ្វើចំណាកស្រុកនៅពេលមាន ផលប្រយោជន៍រំពឹងទុកជាពិសេសខាងហិរញ្ញវត្ថុវាធំជាងបន្ទុកចំណាយខាងហិរញ្ញវត្ថុ និង សង្គមកិច្ច។[2]

---

[1] វិទ្យាស្ថានសភាកម្ពុជា "សីលធម៌ និងលក្ខន្តិកចាំបាច់ផ្នែកសេដ្ឋកិច្ចដើម្បីធានាឲ្យការធ្វើចំណាកស្រុកមានលក្ខណៈយុត្តិធម៌វៃឆ្លាតនិងមនុស្សធម៌ជាងមុន" ខែកញ្ញា ឆ្នាំ២០១៥

[2] ទស្សនៈរបស់លោក Todaro "ទ្រឹស្តីសេដ្ឋកិច្ចសមហេតុផល" ឆ្នាំ ១៩៨៩

### ១.១.៣ ទ្រឹស្តីវិស័យពីរ

ឯកសារពីយូរហើយលើចំណាកស្រុកផ្អែកលើគំរូអភិវឌ្ឍន៍ដែលថែងថា ប្រទេសទាំងអស់នៅដំណាក់កាលណាមួយ ត្រូវតែមានចលនាកម្លាំងពលកម្មចេញពីវិស័យកសិកម្មទៅកាន់វិស័យមិនមែនកសិកម្ម។ ជារឿយៗការបែងចែកកម្លាំងពលកម្មទៅតាមវិស័យត្រូវមានចលនាផ្លាស់ប្តូរទីតាំងភូមិសាស្ត្រនៃពលករ ចេញពីតំបន់ជនបទទៅកាន់តំបន់ទីក្រុង។

ចំណាកស្រុកក្នុងប្រទេស តែងត្រូវចាត់ទុកជាដំណើរការធម្មតាមួយដែលក្នុងនេះ កម្លាំងពលកម្មត្រូវបានដកចេញជាបណ្តើរៗពីតំបន់ជនបទ ដើម្បីផ្តល់កម្លាំងពលកម្មដល់កំនើនឧស្សាហកម្មនៅទីក្រុង។ ដំណើរការនេះគួរតែមានគុណប្រយោជន៍ខាងសង្គមច្រើន ពីព្រោះធនធានមនុស្សនៅតាមតំបន់ ដែលការរកចំណូលបន្ថែមរបស់ពួកគេបានសឹងស្មើសូន្យត្រូវបានផ្លាស់ចេញទៅកាន់តំបន់ដែលការរកចំណូលបន្ថែមមានតួរលេខវិជ្ជមាន និងមានកំនើនយ៉ាងឆាប់រហ័ស ដោយសារមូលធនដែលបានបង្គរទុក និងការរីកចំរើនខាងបច្ចេកវិទ្យានេះ គឺជាទស្សនៈរបស់លោក Todaro ឆ្នាំ 1989។ នៅក្នុងដំណើរការអភិវឌ្ឍន៍ចលនាប្រជាជននៅគ្រប់ទិសទី គឺជាលក្ខណៈសំគាល់ដ៏សំខាន់មួយ។ ហេតុការណ៍នេះ លោក Lewis បានដាក់បញ្ជាក់ទៅក្នុង "គំរូវិស័យពីរ" ដែលបានក្លាយទៅជាទ្រឹស្តីទូទៅនៃការអភិវឌ្ឍន៍នៅប្រទេសតតិយលោកដែលមានកម្លាំងពលកម្ម នៅអំឡុងទសវត្សរ៍១៩៦០ដល់១៩៧០។ នៅក្នុងគំរូរបស់ Lewis សេដ្ឋកិច្ចដែលមិនទាន់អភិវឌ្ឍន៍ មានវិស័យពីរជាសំខាន់ (១)វិស័យបុរាណរកបានត្រឹមមួយរស់នៅតាមជនបទដែលមានប្រជាជនលើសកំនត់និងមានផលិតភាពពលកម្មបន្ថែមស្មើសូន្យដូច្នេះ Lewis ក៏អាចចាត់ទុកពលកម្មក្នុងស្ថានភាពទី១ នេះបាន ពីព្រោះពលកម្មបែបនេះ អាចដកចេញពីវិស័យកសិកម្ម ដោយគ្មានការខាតបង់ផលអ្វីមួយទេ។ និង (២)ផលិតភាពខ្ពស់នៃវិស័យឧស្សាហកម្មទំនើបនៅទីក្រុងដែលទទួលយកជាបណ្តើរៗនូវកម្លាំងពលកម្មមកពីវិស័យរកបានមួយរស់ ដូចការបញ្ជាក់ខាងលើរបស់លោក (Todaro 1989)។[3]

### ១.១.៤ ទ្រឹស្តីកំណើនមានតុល្យភាព និងទ្រឹស្តីអភិវឌ្ឍន៍មិនស្របគ្នា

" វិធីកំណើនមានតុល្យភាព" ដែលផុសចេញពីទ្រឹស្តីសេដ្ឋកិច្ចបានសន្មតថា តាមរយៈការកាត់បន្ថយភាពគ្មានការងារធ្វើ និងការផ្តល់ផលជាប្រាក់ផ្ញើរមកផ្ទះនិងជំនាញទទួលបាន សកម្មភាពចំណាកស្រុកបានជួយជំរុញការអភិវឌ្ឍន៍ កាត់បន្ថយគំលាតក្នុងតំបន់ និងនៅទីបំផុតធ្វើអោយចំណាកស្រុកលែងចាំបាច់ទៀត។ "វិធីសាស្ត្រអភិវឌ្ឍន៍មិនស្របគ្នា" ដែលពឹងផ្អែកខ្លាំងលើការសិក្សាកម្រិតមីក្រូ មិនបានទទួលស្គាល់ទេថា ចំណាកស្រុក ប្រាក់ផ្ញើរមកផ្ទះ និងផលត្រឡប់នាំឲ្យមានការ

---

[3] លោក Lewis "ទ្រឹស្តីកំណើនមានតុល្យភាព និងទ្រឹស្តីអភិវឌ្ឍន៍មិនស្របគ្នា" ឆ្នាំ ១៩៥៤

អភិវឌ្ឍន៍យ៉ាងលឿនជាស្វ័យប្រវត្តិនោះទេ ។ ប្រាកដណាស់ ភាពក្រីក្រជាកត្តាបង្ករចំណាកស្រុក ប៉ុន្តែមិនមែនតែភាពក្រីក្រនេះទេ ពីព្រោះវិសមភាពក៏ជាកត្តាមួយដែរ។ សេដ្ឋកិច្ចទីផ្សាបាននាំមកនូវវិសមភាព និងគំលាតបៀវត្សរ៍និងប្រាក់ចំណូលដែលធ្វើឲ្យចំណាកស្រុកកើនឡើង។ តាមមើលវិសមភាពពិតប្រាកដ និងចំណាប់អារម្មណ៍ថាមានវិសមភាព សុទ្ធតែអាចជាកត្តាកំនត់នៃសកម្មភាពចំណាកស្រុក ។

## ១.២ ស្ថានភាពទូទៅនៃការធ្វើចំណាកស្រុកនៅកម្ពុជា

ការធ្វើចំណាកស្រុក គឺជាបញ្ហាសកលដែលត្រូវបានជំរុញដោយសកលភាវូបនីយកម្ម សង្គមនយោបាយ និងការអភិវឌ្ឍខាងសេដ្ឋកិច្ច។ បញ្ហានេះគឺមិនមែនជាបញ្ហាថ្មីសម្រាប់ប្រទេសកម្ពុជាទេ។ មុនសវត្សឆ្នាំ ១៩៩០ ការធ្វើចំណាកស្រុករបស់ប្រជាជនកម្ពុជា គឺជាការគេចចេញពីសង្គ្រាម។ ចាប់តាំងពីបានសន្តិភាពពេញលេញឡើងវិញ ចំនួនប្រជាជនធ្វើចំណាកស្រុកទៅកាន់ប្រទេសដ៏ទៃ ដោយសារតែមូលហេតុសេដ្ឋកិច្ចបានកើតឡើង។

ប្រទេសកម្ពុជាមានកំនើនប្រជាជនគួរឲ្យកត់សម្គាល់ ដែលបណ្តាលឲ្យមានអត្រាកំណើនកម្លាំងពលកម្មផងដែរ។ ស្ថានភាពប្រជាសាស្ត្រនេះមានន័យថា ប្រទេសកម្ពុជាកំពុងព្យាយាមផ្តល់ឱកាសការងារឲ្យបានគ្រប់គ្រាន់សម្រាប់យុវជននិងកំណើនប្រជាជន។ មានការប៉ាន់ប្រមាណថាកម្លាំងពលកម្ម វ័យក្មេងបានចូលក្នុងទីផ្សារការងារនៅក្នុងប្រទេសកម្ពុជាជារៀងរាល់ឆ្នាំ ភាគច្រើននៃពួកគេគ្មានជំនាញឡើយ។ វិស័យរោងចក្រកាត់ដេរ ដែលជាផ្នែកមួយដ៏សំខាន់សម្រាប់វិស័យឧស្សាហកម្ម បានប្រើប្រាស់កម្លាំងពលកម្មជាច្រើនម៉ឺននាក់។ នេះមានន័យថា ភាគច្រើននៃប្រជាជនកម្ពុជាដែលបិតក្នុងអាយុធ្វើការ គឺកំពុងស្ថិតនៅក្នុងវិស័យដ៏ទៃទៀត ជាពិសេសក្នុងវិស័យកសិកម្ម។ រាជរដ្ឋាភិបាលបានប្រឈមនឹងបញ្ហាជាច្រើនក្នុងការផ្តល់ឲយុវជនកម្ពុជានូវជំនាញដែលត្រូវការដើម្បីចូលក្នុងទីផ្សារការងារ។ នេះបង្ហាញឲ្យឃើញយ៉ាងច្បាស់ថាការខ្វះខាតជំនាញតាមតម្រូវការក្នុងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា បានជម្រុញឲ្យប្រជាជនធ្វើចំណាកស្រុកទៅកាន់ប្រទេសដ៏ទៃដើម្បីស្វែងរកការងារធ្វើនៅកន្លែងផ្សេង។

ការធ្វើចំណាកស្រុកនៅក្នុងប្រទេស កើតមានច្រើននៅតាមព្រំដែនកម្ពុជា ថៃ និងវៀតណាម។ ការសិក្សាផ្សេងទៀតបានសង្កត់ធ្ងន់ថាពលករចំណាកស្រុកភាគច្រើនមកពី ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកំពង់ចាម ខេត្តបន្ទាយមានជ័យ និងខេត្តពោធិសាត់។ ដោយមានការថយចុះអត្រាកំណើនសេដ្ឋកិច្ច រឹងមាំ និងតម្រូវការកម្លាំងពលកម្ម ប្រទេសថៃគឺជាគោលដៅទាក់ទាញបំផុតសម្រាប់ការធ្វើចំណាកស្រុកឆ្លងដែនសម្រាប់យុវជនខ្មែរ។ ប្រទេសកូរ៉េខាងត្បូង បានក្លាយជាគោលដៅទីពីរ

សម្រាប់ការធ្វើចំណាកស្រុករបស់ប្រជាជនកម្ពុជាដោយសារតែប្រាក់ឈ្នួលមានតម្លៃខ្ពស់ជាង និងចំណាកស្រុកទៅប្រទេសផ្សេងទៀត។

ក្នុងទសវត្សរ៍កន្លងមក ភាគច្រើននៃអ្នកធ្វើចំណាកស្រុកទៅប្រទេសថៃ គឺជាជនចំណាកស្រុក "មិនទៀងទាត់"។ ការធ្វើចំណាកស្រុកមិនទៀងទាត់អាចត្រូវបានកំណត់ថាជា "ចលនាខុសច្បាប់ដើម្បីធ្វើការនៅក្នុងប្រទេសផ្សេងទៀតដោយពុំមានការអនុញ្ញាត"។ ការសិក្សាដូចគ្នានេះបានគូសបញ្ជាក់ពីភាពខុសគ្នាយ៉ាងខ្លាំងនៅក្នុងស្ថានភាពសង្គមសេដ្ឋកិច្ចរវាងអ្នកធ្វើចំណាកស្រុកទៀងទាត់ និងមិនទៀងទាត់។ ឧទាហរណ៍ អ្នកធ្វើចំណាកស្រុកមិនទៀងទាត់ច្រើនតែទៅធ្វើការងារដែលគ្មានជំនាញមានការអប់រំទាប ការចំណាយលើការប្រើប្រាស់ និងទ្រព្យសម្បត្តិ។ អ្នកធ្វើចំណាកស្រុកមិនទៀងទាត់ឬដោយខុសច្បាប់ត្រូវបានគេរកឃើញថាមានភាពងាយរងគ្រោះជាងអ្នកដែលធ្វើចំណាកស្រុកដោយស្របច្បាប់។

ចំពោះស្ថានភាពទូទៅនៃការធ្វើចំណាកស្រុករបស់ប្រជាជនកម្ពុជា នៅក្នុងប្រទេសកម្ពុជាមានចលនាជាទូទៅពីរ គឺកាធ្វើចំណាកស្រុកពីជនបទមកកាន់ទីក្រុង និងការធ្វើចំណាកស្រុកទៅក្រៅប្រទេស។ ការធ្វើចំណាកស្រុកទាំងពីរប្រភេទនេះ គឺជាការសម្រេចចិត្តរបស់ប្រជាពលរដ្ឋដោយខ្លួនឯងផ្ទាល់អាចមានការបង្ខិតបង្ខំ ឬបណ្តាលមកពីកត្តាផ្សេងៗជាពិសេសនោះគឺដើម្បីដោះស្រាយនូវនូវជីវភាពគ្រួសាររបស់ពួកគេ។[4]

### ១.២.១ ការធ្វើចំណាកស្រុកពីជនបទមកកាន់ទីក្រុង

ប្រជាជនកម្ពុជាប្រមាណជា៨០% ជាកសិករនៅតំបន់ជនបទ។ ភាគច្រើននៃកសិករជាជនក្រីក្រហើយរបរកសិកម្មមិនអាចផ្តល់នូវប្រាក់ចំណូលគ្រប់គ្រាន់សំរាប់ចិញ្ចឹមគ្រួសារដូច្នេះ ពួកគេត្រូវតែស្វែងរកការងារផ្សេងទៀតដោយការធ្វើចំណាកស្រុកទៅកាន់តំបន់ទីប្រជុំជន ឬតំបន់ដែលមានតំរូវការពលកម្មខ្ពស់ជាពិសេសនៅទីក្រុងភ្នំពេញ។ ម្យ៉ាងវិញទៀតអត្រាកំណើនប្រជាពលរដ្ឋខ្មែរមានការកើនឡើងជារៀងរាល់ឆ្នាំ ចំនែកឯកំណើនចំនួនប្រជាជននៅទីក្រុង និងទីប្រជុំជនគឺ មានការកើនឡើងយ៉ាងឆាប់រហ័សក្នុងរយៈពេលមួយទសវត្ស។ នៅក្នុងអំឡុងពេលដែលចំនួនប្រជាពលរដ្ឋមានការកើនឡើង ជារៀងរាល់ឆ្នាំ ហើយការធ្វើចំណាកស្រុកពីទីកន្លែងមួយទៅទីកន្លែងមួយក៏កើតឡើងជាប្រចាំផងដែរ ជាពិសេស គឺមានការធ្វើចំណាកស្រុកពីជនបទមកកាន់ទីក្រុង។ ប្រជាជនមួយចំនួនធ្វើចំណាកស្រុកមកកាន់ទីក្រុងបន្ទាប់ពីប្រមូលផលកសិកម្មរួចហើយវិលត្រលប់ទៅកាន់ស្រុកកំណើតវិញពេលដល់រដូវធ្វើស្រែចំការ ចំណែកឯប្រជាជនមួយចំនួនមិនបានវិល

[4] វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍ "សង្ខេបរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០០៧-២០០៨" ឆ្នាំ ២០០៨

ត្រលប់ទៅស្រុកកំណើតវិញទេ ហើយនិងខ្លះទៀត ធ្វើចំណាកស្រុកជាលក្ខណៈបុគ្គលម្នាក់ឯង ឬជាលក្ខណៈគ្រួសារ។ អ្នកធ្វើចំណាកស្រុកភាគច្រើនមានអាយុចាប់ពី ១៥ ដល់៦៤ឆ្នាំហើយគេកត់សម្គាល់ថា ស្ត្រីមានចំនួនច្រើនជាងបុរស ក្នុងការចាកចេញពីស្រុកកំណើតមកធ្វើការនៅទីក្រុងភ្នំពេញជាពិសេស គឺជាកម្មកររោងចក្រកាត់ដេរ និងការងារនៅតាមហាងផ្សេងៗ។ ក្នុងចំណោមប្រជារាស្ត្រផ្លាស់ប្តូរទីលំនៅមានជិតបីភាគបួនដែលមានការងារធ្វើ ហើយមានតែជាង១% ប៉ុណ្ណោះដែលមិនមានការងារ។ ការកើនឡើងនៃការធ្វើចំណាកស្រុកមកកាន់ទីក្រុងធ្វើអោយដង់ស៊ីតេប្រជាជននៅទីក្រុង មានចំនួនកាន់តែច្រើនឡើង និងកាន់តែចង្អៀត ដូច្នេះហើយទំហំផ្ទៃដីនៅទីក្រុងត្រូវបានគេពង្រីកអោយកាន់តែធំដើម្បីធ្វើការអភិវឌ្ឍន៍។

### ១.២.២ ការធ្វើចំណាកស្រុកនៅក្រៅប្រទេស

ប្រជាជនមួយចំនួនផ្លាស់មកកាន់ទីក្រុងដើម្បីស្វែងរកការងារធ្វើតែមួយចំនួនទៀតបានធ្វើចំណាកស្រុកទៅកាន់ប្រទេសជិតខាង និងប្រទេសផ្សេងៗទៀតដូចជាប្រទេសថៃ ប្រទេសម៉ាឡេស៊ី ប្រទេសកូរ៉េខាងត្បូងជាដើម។ ប្រភពពីអ្នកធ្វើការងារជាមួយពលករចំណាកស្រុកបាននិយាយថា មានប្រជាជនខ្មែររាប់សែននាក់ ដែលកំពុងធ្វើការងារនៅក្រៅប្រទេស។ គិតមកដល់ពេលនេះមានពលករខ្មែរចំណាកស្រុកស្របច្បាប់ និងមិនស្របច្បាប់ជាច្រើននាក់ ដែលកំពុងតែបម្រើការងារនៅក្នុងប្រទេសថៃ ប្រទេសម៉ាឡេស៊ី ប្រទេសកូរ៉េខាងត្បូង ហើយនិងមានពលករខ្មែរកំពុងធ្វើការនៅលើកោះតៃវ៉ាន់ ក្រៅពីនោះទៀត មានពលករខ្មែរធ្វើការនៅក្នុងប្រទេសជប៉ុន និងអារ៉ាប់ផងដែរ [5] ។ ទោះបីជាមានក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅបរទេសដោយស្របច្បាប់យ៉ាងណាក៏ដោយ ក៏នៅមានពលករជាច្រើនឆ្លងដែនទៅធ្វើការនៅបរទេសដោយខុសច្បាប់ព្រោះពួកគេយល់ឃើញថាការរកការងារធ្វើដោយខ្លួនឯង អាចទទួលបានប្រាក់កម្រៃច្រើនជាង ការងារដែលក្រុមហ៊ុនផ្តល់ឲ្យ។ មូលហេតុដែលប្រជាពលរដ្ឋខ្មែរមួយចំនួនបានសុខចិត្តរស់នៅជាជនអន្តោប្រវេសន៍នោះដោយសារតែពួកគេរកការងាដែលទទួលបានប្រាក់ច្រើនជាងក្រុមហ៊ុនដែលបញ្ជូនពលករទៅនោះ ប៉ុន្តែពួកគេទាំងនេះត្រូវគេចវេសពីប៉ូលិសរៀងថ្ងៃ ថែមទាំងប្រឈមមុខជាមួយបញ្ហាជាច្រើនទៀតផង។

## ១.៣ ក្រសួង និងស្ថាប័នពាក់ព័ន្ធ នៅក្នុងការគ្រប់គ្រងពលកម្មចំណាកស្រុក

ទាំងភាគីរាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធដើរតួរនាទីយ៉ាងសំខាន់នៅក្នុងការគ្រប់គ្រងបញ្ហាពលករចំណាកស្រុករបស់ប្រជាជន។ ភាគីទាំងពីរនេះរួមមាន ក្រសួង និងស្ថាប័នពាក់ព័ន្ធ អង្គការ

[5] ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដកស្រង់ចេញពី "ទិន្នន័យប្រចាំឆ្នាំ ២០១៨" ភ្នំពេញ ឆ្នាំ ២០១៨

អន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល។ ពួកគេធ្វើសកម្មភាពផ្សេងៗគ្នាដើម្បីសម្របសម្រួល គ្រប់គ្រង និងការពារពលករចំណាកស្រុកពីបញ្ហាផ្សេងៗ។ ពួកគេបានធ្វើការយ៉ាងសកម្ម នៅក្នុងការដោះស្រាយបញ្ហារបស់ជនចំណាកស្រុកទាំងក្នុង និងក្រៅប្រទេស ។

ក្រសួង និងស្ថាប័នពាក់ព័ន្ធមានចំនួន៦ ដែលធ្វើការគ្រប់គ្រងពលកម្មចំណាកស្រុក។ រួមមានដូចជា នាយកដ្ឋានការងារ និងកំលាំងពលកម្មនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកិច្ចការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្រសួងមហាផ្ទៃទីស្តីការគណៈរដ្ឋមន្ត្រី អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ និងក្រុមការងារអន្តរក្រសួង[6]។

### ១.៣.១ អង្គការអន្តរជាតិ

នៅក្នុងការគ្រប់គ្រងពលកម្មចំណាកស្រុក មិនមែនមានតែភាគីរាជរដ្ឋាភិបាលតែមួយនោះទេ ដែលកំពុងធ្វើការលើផ្នែកនេះ អង្គការអន្តរជាតិជាច្រើនក៏បានចូលរួមនៅក្នុងការគ្រប់គ្រងពលកម្មចំណាកស្រុកនេះដែរ។អង្គការអន្តរជាតិទាំងនោះមានដូចជា អង្គការអន្តរជាតិខាងចំណាកស្រុក (IOM) មូលនិធិអភិវឌ្ឍន៍ដើម្បីស្ត្រីរបស់អង្គការសហប្រជាជាតិ(UNIFEM) មូលនិធិប្រជាជនរបស់អង្គការសហប្រជាជាតិ (UNFPA) គម្រោងអន្តរភ្នាក់ងារស្តីអំពីការជួញដូរមនុស្សនៅក្នុងអនុតំបន់ទន្លេមេគង្គរបស់អង្គការសហប្រជាជាតិ(UNIAP) និង ធនាគារពិភពលោក(WB)[7]។ អង្គការទាំងអស់នេះធ្វើផែនការសកម្មភាពផ្សេងៗគ្នា ប៉ុន្តែពួកគេមានគោលបំណងរួមគឺជួយដោះស្រាយបញ្ហាពលកម្មចំណាកស្រុក ។

### ១.៣.២ អង្គការក្រៅរដ្ឋាភិបាល

ក្រៅពីស្ថាប័នអង្គការអន្តរជាតិមួយចំនួនខាងលើ ក៏មានអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនទៀតដែល ធ្វើការលើពលកម្មចំណាកស្រុកនេះដែរ។ អង្គការក្រៅរដ្ឋាភិបាលទាំងនោះបានកំពុងតែអនុវត្តសកម្មភាពជាច្រើនទៅតាមគោលដៅរបស់គេ។ អង្គការមិនមែនរដ្ឋាភិបាលទាំងនោះមានដូចជា អង្គការខារាមកម្ពុជា (CARAMCambodia) អង្គការគាំទ្រផ្នែកច្បាប់ដើម្បីស្ត្រី និងកុមារ (LSCW) មជ្ឈមណ្ឌលស្ត្រីមានវិបត្តិកម្ពុជា(CWCC) និង អង្គការស្ត្រីកម្ពុជាដើម្បីសន្តិភាព និងការអភិវឌ្ឍន៍(CWPD) ។[8]

---

[6] លោក សុខ ណាត "ការធ្វើចំណាកស្រុករបស់ប្រជាជនកម្ពុជា" ឆ្នាំ២០១៥

[7] លោក សុខ ណាត "ការធ្វើចំណាកស្រុករបស់ប្រជាជនកម្ពុជា" ឆ្នាំ២០១៥

[8] លោក សុខ ណាត "ការធ្វើចំណាកស្រុករបស់ប្រជាជនកម្ពុជា" ឆ្នាំ២០១៥

# ជំពូកទី ២

# មូលហេតុ និងផលប៉ះពាល់នៃការធ្វើចំណាកស្រុក

## ២.១ មូលហេតុនៃការធ្វើចំណាកស្រុក

ការធ្វើចំណាកស្រុកដើម្បីចេញទៅស្វែងរកការងារធ្វើ បណ្តាលមកពីកត្តាជុំរុញ និងកត្តាទាក់ទាញ ដែលត្រូវបានគេចាត់ទុកជាកត្តាចម្បង និងជាមូលហេតុក្នុងការធ្វើចំណាកស្រុក ។[9]

### ២.១.១ កត្តាជុំរុញ

#### ២.១.១.១ ភាពក្រីក្រ

ជីវភាពក្រីក្រជាកត្តាប្រឈមដ៏សំខាន់ ចំពោះប្រជាជនដែលរស់នៅតាមជនបទ ភាពក្រីក្រដែលមានតាំងពីជំនាន់មុនៗ របស់គ្រួសារមួយជាផលលំបាកដែលពួកគេត្រូវជួបប្រទះ ហើយព្យាយាមស្វះស្វែងធ្វើការចាកចេញពីស្រុកកំណើតដើម្បីស្វែងរករកការងារធ្វើដោយសង្ឃឹមថា នឹងទទួលបាននូវជីវភាពមួយដែលសមរម្យ បន្ទាប់ពីធ្វើការចំណាកស្រុក ។

#### ២.១.១.២ ភាពគ្មានដីធ្លី

ដោយប្រជាជនរស់នៅតាមជនបទភាគច្រើនប្រកបរបរកសិកម្ម ដូច្នេះពួកគេត្រូវការដីធ្លីសម្រាប់ការធ្វើកសិកម្ម និងស្រែចំការផ្សេងៗ។ ដោយប្រជាជនមួយចំនួននៅតាមជនបទគ្មានដីធ្លីសម្រាប់ធ្វើកសិកម្ម ដូចនេះមានតែការធ្វើចំណាកស្រុកទៅធ្វើការងារនៅតំបន់ទីប្រជុំជន ឬទៅក្រៅប្រទេសដែលជាមធ្យោបាយមួយដ៏ល្អសម្រាប់ពួកគេក្នុងការចិញ្ចឹមជីវិត និងគ្រួសាររបស់ពួកគេ ។

#### ២.១.១.៣ បំណុល

បញ្ហាគ្មានដីធ្លីត្រូវបានជំពាក់ជំពិន នឹងបំណុលផងដែរ ដោយបំណុលមើលពីក្រៅហាក់ដូចជាគ្មានអ្វីជាបញ្ហាចោទសម្រាប់អ្នកជនបទឡើយ តែទាំងអស់នេះជាកត្តាដែលជំរុញឲ្យមានការធ្វើចំណាកស្រុកកើតឡើង និយាយចំពោះប្រជាជនដែលមានដីធ្លីសម្រាប់ធ្វើការប្រកបកសិកម្ម ធ្វើឲ្យប្រឈមមុខនឹងបញ្ហាបំណុលនេះរហូតឈានដល់ការធ្វើចំណាកស្រុកផងដែរ។ ប្រជាជនមួយបានខ្ចីបំណុលគេ សម្រាប់ធ្វើជាដើមទុនក្នុងការទិញជីគីមី និងការប្រើប្រាស់ផ្សេងៗទៀតសម្រាប់ធ្វើកសិកម្ម ប៉ុន្តែដោយការទទួលទិន្នផលមិនមានផលចំណេញខាតដើមទុនហើយជំពាក់បំណុលគេផងនោះ ទើបមានការសម្រេចចិត្តធ្វើចំណាកស្រុក។ គ្រួសារដែលជំពាក់បំណុលគេតែងតែព្យាយាមសងបំណុលតាមរយៈ ការបញ្ជូនសមាជិកនៅក្នុងគ្រួសាររបស់ពួកគេឲ្យធ្វើចំណាកស្រុក

[9] ព្រភពពី https://soknath.blogspot.com ឆ្នាំ២០១៥

ទៅរកការងារធ្វើនៅឯទីក្រុងឬទៅក្រៅប្រទេស ដើម្បីយកចំណូលទាំងនោះមកទុកសម្រាប់សងបំណុលគេ។

**២.១.១.៤ គ្រោះធម្មជាតិ**

គ្រោះធម្មជាតិ បានបង្ខំឲ្យពលករជាច្រើននៅជនបទកម្ពុជាធ្វើចំណាកស្រុក ដោយសារតែជាកត្តាសំខាន់មួយដែលអាចបង្កឲ្យមានភាពក្រីក្រយ៉ាងឆាប់រហ័សពីព្រោះគ្រោះធម្មជាតិបានបំផ្លិចបំផ្លាញនូវដំណាំ សត្វ និងធ្វើឲ្យពួកគេមិនអាចបន្តការធ្វើកសិកម្មសម្រាប់ទ្រទ្រង់ដល់ការរស់នៅរបស់ពួកគេបាន ក៏សម្រេចចិត្តធ្វើចំណាកស្រុក ។

**២.១.១.៥ ការហិនហោចធនធានធម្មជាតិ**

ការចុះខ្សោយប្រភពចំណូលៈ អ្នកស្រែចំការពឹងផ្អែកទៅលើចំណូលផ្សេងៗដើម្បីទទួលបាននូវតំរូវការជាមូលដ្ឋានសម្រាប់ពួកគេក្នុងការចិញ្ចឹមជីវិតដោយការនេសាទ (រកត្រី ស្ទូចត្រី........ ) និងការប្រមែប្រមូលដំណាំដាំដុះលើទឹកគ្គី លើគោកគ្គី គឺជាប្រភពចំណីអាហារចម្បង និងជាចំណូលរបស់ពួកគេបន្ទាប់ពីការធ្វើស្រែចំការ ។

**២.១.២ កត្តាទាក់ទាញ**

**២.១.២.១ ឧស្សាហកម្ម**

នៅក្នុងទីក្រុងឧស្សាហកម្មមានការរីកលូតលាស់យ៉ាងឆាប់រហ័ស ហើយលំហូរចូលនៃក្រុមជនចំណាកស្រុកចោលជនបទ។ កន្លែងដែលមានការរីកចម្រើនគឺនៅភ្នំពេញ និងនៅបណ្តាក្រុងតូចៗនៅជាប់ជាយដែនប្រទេសថៃ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ទីក្រុងភ្នំពេញនៅតែជាមជ្ឈមណ្ឌលកណ្តាល ដែលប្រមូលផ្តុំនូវរាល់ចំណាកស្រុក។ ពលករចំណាកស្រុកចោលជនបទបានហូរចូលទីក្រុងដើម្បីស្វែងរកការងារធ្វើក្នុងវិស័យសេវាកម្ម ឧស្សាហកម្ម កម្មករសំណង់ កម្មកររោងចក្រជាដើម ។

**២.១.២.២ ឱកាសការងារ**

វិស័យចម្បងពីរក្នុងសេដ្ឋកិច្ចគឺ វិស័យកសិកម្ម និងវិស័យឧស្សាហកម្ម ដែលកសិកម្មបានផ្តល់ការងារដល់ប្រជាជនបានយ៉ាងច្រើន។ នៅតាមជនបទដែលមានស្ត្រី ៨៩% ជាកម្លាំងពលកម្មសកម្មក្នុងវិស័យសេដ្ឋកិច្ចនៅជនបទ ហើយមានចំនួនតែ៤០% ប៉ុណ្ណោះដែលចូលរួមក្នុងវិស័យសេដ្ឋកិច្ច។ វិស័យឧស្សាហកម្មបានផ្តល់ការងារធ្វើដល់ប្រជាពលរដ្ឋតិចជាង៥% ហើយមានតែវិស័យកាត់ដេរប៉ុណ្ណោះដែលមានកំរិតនៃការរីកលូតលាស់ឆាប់រហ័សជាវិស័យដទៃ។ ការងារនៅវិស័យសំណង់ផ្តល់កន្លែងធ្វើការភាគច្រើនសម្រាប់តែចំណាកចោលជនបទតាមរដូវកាលប៉ុណ្ណោះ។ នៅ

ក្នុងវិស័យផលិតកម្ម ពលករចំណាកស្រុកបម្រើក្នុងនោះទទួលបានប្រាក់បៀវត្សន៍ទាប ដោយសារតែគ្មានជំនាញ ។

### ២.១.២.៣ ការធ្វើចំណាកស្រុកតាមរដូវ

ប្រជាជននៅតាមជនបទមួយចំនួនធ្វើការចំណាកស្រុកតាមរដូវ បន្ទាប់ពីរដូវប្រមូលទិន្នផលពីការប្រកបរបរកសិកម្មរួចរាល់ គឺពួកគាត់មិនមានប្រកបរបរអ្វីបន្ថែមនោះទេ ដូចនេះការធ្វើចំណាកស្រុកមកស្វែងរកការងារធ្វើនៅទីក្រុង និងទៅក្រៅប្រទេសជាជម្រើសមួយដែលអាចស្វែងរកប្រាក់ បន្ថែមដើម្បីផ្គត់ផ្គង់ជីវភាពនៅក្នុងគ្រួសារ ។

## ២.២ ប្រភេទនៃការធ្វើចំណាកស្រុក

ចំណាកស្រុកនៅកម្ពុជាត្រូវបានគេចំណាត់ថ្នាក់ជាពីរប្រភេទ។ ចំណាកស្រុកទាំងពីរប្រភេទនោះ មានដូចជា ចំណាកស្រុកនៅក្នុងប្រទេស និង ចំណាកស្រុកទៅក្រៅប្រទេស។ ចំនួនអ្នកធ្វើចំណាកស្រុកទាំងក្នុងស្រុក និងក្រៅស្រុកនេះ មាននិន្នាការកើនឡើងយ៉ាងឆាប់រហ័ស និងគួរឲ្យកត់សម្គាល់។

### ២.២.១ ចំណាកស្រុកនៅក្នុងប្រទេស

កម្មករចំណាកស្រុកភាគច្រើន មកពីគ្រួសារក្រីក្រ ខ្លះមកពីគ្រួសារមានជីវភាពមធ្យម ឬទុរគត។ គ្រួសារអ្នកមានសម្រេចចិត្តនៅស្ងៀម និងមិនធ្វើចំណាកស្រុកទេ ពីព្រោះពួកគេមានសមត្ថភាពបង្កើតប្រភពចំណូលបានច្រើនខណៈដែលសមត្ថភាពគ្រួសារទុរគត ក្នុងការចេញទៅខាងក្រៅប្រទេស និងស្វែងរកការងារធ្វើត្រូវថយចុះដោយសារកំហិតហិរញ្ញវត្ថុ។ តាមការសំគាល់ អ្នកនៅក្នុងភូមិដែលផ្អែកលើធនធានដី (កសិកម្ម កសិកម្ម-ព្រៃឈើ កសិកម្ម-នេសាទ) មានទំនោរធ្វើចំណាកស្រុកច្រើនជាងអ្នកនៅក្នុងភូមិផ្អែកលើធនធានទឹក (នេសាទ នេសាទ-កសិកម្ម)។ រីឯអ្នកភូមិនៅតាមទីប្រជុំជនវិញគឺពឹងផ្អែកយ៉ាងសំខាន់ទៅលើការធ្វើចំណាកស្រុក។ ជាទូទៅអ្នកភូមិធ្វើចំណាកស្រុកតាមរដូវកាលដើម្បីរកការងារខាងកសិកម្ម ឬនេសាទដោយផ្តោតលើភូមិនៅក្បែរខាង ឬភូមិនៅជុំវិញបឹងទន្លេសាប រីឯការចំណាកស្រុករយៈពេលវែងវិញ ផ្តោតទៅលើការងារសំណង់ និងរោងចក្រកាត់ដេរនៅទីក្រុង និងបណ្តាខេត្តធំៗ។[10]

### ២.២.២ ចំណាកស្រុកនៅក្រៅប្រទេស

ចំណាកស្រុកទៅក្រៅប្រទេសបានក្លាយទៅជាប្រភពចំណូល ដ៏សំខាន់របស់គ្រួសារនៅតំបន់ជនបទតាំងពីពាក់កណ្តាលទសវត្សឆ្នាំ១៩៩០មកម្ល៉េះ។ ការធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុង

[10] ព្រភពពី https://soknath.blogspot.com ឆ្នាំ២០១៥

តំបន់យ៉ាងលឿន និងតម្រូវការដ៏ច្រើននូវកម្លាំងពលកម្មគ្មានជំនាញនៅប្រទេសថៃ និងម៉ាឡេស៊ី គឺជាការទាក់ទាញដំបូងមួយសម្រាប់ពលករចំណាកស្រុកកម្ពុជា។ ព្រោះតែកត្តាទាំងពីរខាងលើ និងដោយសារតែការចំណាយខ្ពស់ និងរយៈពេលវែងចំណាកស្រុកបានត្រូវចែកជាពីរ គឺចំណាកស្រុកទៅក្រៅប្រទេសដោយស្របច្បាប់ និងចំណាកស្រុកទៅក្រៅប្រទេសដោយមិនស្របច្បាប់។

### ២.២.៣ ចំណាកស្រុកទៅក្រៅប្រទេសដោយស្របច្បាប់

ការធ្វើចំណាកស្រុកដោយស្របច្បាប់ គឺជាការធ្វើចំណាកស្រុកទៅក្រៅប្រទេសដោយមានការផ្តល់អាជ្ញាប័ណ្ណ ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬតាមរយៈការជ្រើសពលករដោយក្រុមហ៊ុនផ្សេងៗ។ ការធ្វើចំណាកស្រុកដោយស្របច្បាប់នេះ គឺមានសារៈប្រយោជន៍ខ្លាំងណាស់ក្នុងការពារសុវត្ថិភាព ការពារផលប្រយោជន៍ដល់ពលករពីការកេងប្រវ័ញ្ច ឬហានិភ័យផ្សេងៗដែលកើតមានឡើងចំពោះពលករចំណាកស្រុក។

ចំនួនពលករ និងពលការិនីដែលកំពុងស្នាក់នៅ និងធ្វើការនៅបរទេសដោយស្របច្បាប់ (គិតត្រឹម១០ខែ ឆ្នាំ២០១៨) មានចំនួនសរុប ១,២២០,៥៩៨នាក់ ដែលស្ថិតនៅក្នុង៧ប្រទេស ដូចជាប្រទេសជប៉ុនមានពលករចំនួន ៦,៧១៧នាក់ ប្រទេសម៉ាឡេស៊ីមានពលករចំនួន ៣០,០៦៣នាក់ ប្រទេសកូរ៉េមានពលករចំនួន ៤៨,៦៧០នាក់ ប្រទេសថៃមានពលករចំនួន ១,១៣៤,២៣២នាក់ ប្រទេសសឹង្ហបុរីមានពលករចំនួន ៨៥១នាក់ តំបន់រដ្ឋបាលពិសេសហុងកុងមានពលករចំនួន ៥០នាក់ និងប្រទេសអារ៉ាប់ប៊ីសាអូឌីតមានពលករចំនួន ១៥នាក់។[11]

### ២.២.៤ ចំណាកស្រុកទៅក្រៅប្រទេសដោយមិនស្របច្បាប់

ចំណាកស្រុករបស់ប្រជាជនជនបទ ជាបញ្ហាមួយដែលរដ្ឋពិបាកធ្វើការគ្រប់គ្រង ជាពិសេសចំណាកស្រុកទៅក្រៅប្រទេសដោយមិនស្របច្បាប់ ឬ គេហៅម្យ៉ាងទៀតថា ទេសន្តរប្រវេសន៍មិនស្របច្បាប់។ ចំណាកស្រុកទៅក្រៅប្រទេសដោយមិនស្របច្បាប់ ឬទេសន្តរប្រវេសន៍មិនស្របច្បាប់នេះត្រូវបានគេកំនត់និយមន័យយ៉ាងខ្លីថាជា ចលនាផ្លាស់ទីដោយខុសច្បាប់ដើម្បីទៅធ្វើការក្នុងប្រទេសមួយ ឬចលនាផ្លាស់ទីដោយមិនស្របច្បាប់ ឬលួចលាក់ដែលមិនមានការអនុញ្ញាតឲ្យធ្វើការ។ ប្រការនេះរួមមានករណីនៃប្រជាជនធ្វើទេសន្តរប្រវេសន៍ដោយស្របច្បាប់ ប៉ុន្តែក្រោយមកបានបាត់បង់ស្ថានភាពស្របច្បាប់របស់ខ្លួនដោយសារការស្នាក់នៅហួសកំនត់។ ជនទេសន្តរប្រវេសន៍ មិនស្របច្បាប់កម្ពុជាភាគច្រើនធ្វើដំណើរដោយពុំមានឯកសារស្របច្បាប់គ្រប់គ្រាន់ទេ។

[11]ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដកស្រង់ចេញពី "ទិន្នន័យប្រចាំឆ្នាំ២០១៨" ភ្នំពេញ ឆ្នាំ ២០១៨

ការជ្រើសរើសពលករចំណាកស្រុកដោយមិនស្របច្បាប់ ក៏ជាទម្រង់ពេញនិយមបំផុតនៃចលនាឆ្លងកាត់ព្រំដែនក្នុងចំណោមពលករកម្ពុជាដែលស្វែងរកការងារនៅក្រៅប្រទេស។ ទង្វើនេះកើតឡើងនៅក្រៅក្របខណ្ឌច្បាប់នៃប្រទេសបញ្ជូនប្រទេសឆ្លងកាត់ និងប្រទេសទទួលពលករ។ ការជ្រើសរើសពលករមិនស្របច្បាប់អាចចែកជាពីរប្រភេទគឺ

ប្រភេទទី ១៖ ទេសន្តរប្រវេសន៍ចម្ងាយជិតតាមបណ្ដោយព្រំដែនកម្ពុជា-ថៃហើយតាមធម្មតាដើម្បីទៅធ្វើការងារកសិកម្ម ដែលជនទេសន្តរប្រវេសន៍បានដឹងពីសាច់ញាតិជនទេសន្តរប្រវេសន៍ធ្លាប់ទៅមុនគេ មិត្តភក្តិ ឬអ្នកភូមិឯទៀត។ អ្នកធ្លាប់ទៅមុនទាំងនេះជួយសម្រួលការចូលធ្វើការ និងដើរតួជាបណ្ដាញតភ្ជាប់ជាមួយគ្រួសារធំនៅជនបទ និងទិសដៅនៅប្រទេសថៃ។ ជនទេសន្តរប្រវេសន៍ភាគច្រើន ចាត់ទុកវិធីនេះថាមាន សន្តិសុខគួរសម តម្លៃថោក ងាយស្រួល មិនបាច់ចំណាយពេលរង់ចាំ មិនត្រូវការឯកសារ និងមិនបាច់មាននីតិវិធី ជ្រើសរើសស្មុគស្មាញទេ។ សម្រាប់អ្នកទិញប័ណ្ណឆ្លងព្រំដែនរយៈពេលមួយសប្ដាហ៍ចំណាយដំបូងសម្រាប់ការធ្វើទេសន្តរប្រវេសន៍មានចំនួនពី ៣០០ ទៅ ៥៥០ដុល្លារអាមេរិក ក្នុងនេះមានថ្លៃតាក់ស៊ីពី ២៥០ទៅ៥០០ដុល្លារអាមេរិក និងថ្លៃបណ្ណ័ឆ្លងព្រំដែន ៥០ដុល្លា។ ជនទេសន្តរប្រវេសន៍ត្រូវធ្វើបណ្ណ័ថ្មីរាល់សប្ដាហ៍នៅព្រំដែន ឬក៏អាចទិញប័ណ្ណរយៈពេលដល់មួយឆ្នាំដែលមានតម្លៃ ២០ដុល្លា។

ប្រភេទទី ២៖ គឺទេសន្តរប្រវេសន៍ចង្ងាយឆ្ងាយ ទៅប្រទេសថៃ ឬម៉ាឡេស៊ី ដើម្បីធ្វើការលើទូកនេសាទ ឬធ្វើជាកម្មកររោងចក្រ ឬកម្មករសំណង់។ ក្នុងករណីភាគច្រើន ជនទេសន្តរប្រវេសន៍ធ្វើដំណើរជាក្រុមតូចៗដោយមានមេខ្យល់ម្នាក់ នាំពួកគេទៅកន្លែងធ្វើការនៅប្រទេសថៃ។ សេវាសំខាន់ៗដែលមេខ្យល់ផ្ដល់ឲ្យមាន ការដឹកជញ្ជូនទៅព្រំដែន និងជួយសុំបណ្ណ័ធ្វើការ និងការងារនៅប្រទេសទិសដៅ។ ជនទេសន្តរប្រវេសន៍ត្រូវបង់ថ្លៃសម្រួលការជាមុនពី ១០០ដល់២០០ដុល្លាអាមេរិក។ ក្នុងករណីខ្លះ ជនទេសន្តរប្រវេសន៍ធ្វើដំណើរជាក្រុមតូចៗ ដោយមានជំនួយពីអ្នកធ្លាប់ទៅពីមុនដែលដឹងអំពីស្ថានភាពការងារ និងមានទំនាក់ទំនងល្អជាមួយនិយោជក។ ប្រទេសថៃជាទិសដៅដ៏សំខាន់សម្រាប់ជនទេសន្តរប្រវេសន៍មិនស្របច្បាប់នៅកម្ពុជា។ អាចមានប្រជាជនកម្ពុជា មកពីខេត្តព្រៃវែង ស្វាយរៀង កំពង់ចាម បន្ទាយមានជ័យ បាត់ដំបង និងពោធិ៍សាត់ ដែលកំពុងធ្វើការដោយខុសច្បាប់នៅថៃ។[12]

[12] លោក សុខ ណាត "ការធ្វើចំណាកស្រុករបស់ប្រជាជនកម្ពុជា" ឆ្នាំ២០១៥

### ២.៣ ទំនាក់ទំនងសេដ្ឋកិច្ច និងចំណាកស្រុក

### ២.៣.១. ការកាត់បន្ថយភាពក្រីក្រ

#### ២.៣.១.១ តួនាទីនៃកម្រៃពលកម្មនៅក្នុងសេដ្ឋកិច្ច

ប្រាក់កម្រៃពលកម្ម គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រគ្រួសារនៅក្នុងការលក់ពលកម្មដែលជាប្រភពចំណូលសម្រាប់អ្នកមានជីវភាពសមរម្យ។ ប្រាក់ចំណូលពិតប្រាកដរបស់គ្រួសារមួយចំនួនជាមធ្យមបានមកពីការលក់កម្លាំងពលកម្ម និងការចំណាកស្រុកបានកើនឡើងយ៉ាងខ្លាំង។ ចំណាកស្រុកបានធ្វើឲ្យគ្រួសារមួយចំនួនផ្លាស់ប្តូរពីជីវភាពក្រីក្រទៅគ្រួសារដែលមានជីវភាពមធ្យម។

#### ២.៣.១.២ ប្រភពហិរញ្ញវត្ថុ

ដោយតាំងពីដើមរៀងមក គេតែងចាត់ទុកចំណាកស្រុកជាវិនិយោគមួយប្រភេទ។ នៅជនបទ ជាទូទៅគេប្រមូលដើមទុន ដើម្បីឲ្យសមាជិកគ្រួសារធ្វើចំណាកស្រុក។ ទាក់ទិននឹងប្រភពហិរញ្ញវត្ថុមួយភាគបីបានឆ្លើយថា បានមកពីប្រាក់សន្សំក្នុងគ្រួសារ។ ប្រភពខ្លះបានឆ្លើយប្រាប់ថាបានមកពី ប្រាក់សន្សំផ្ទាល់ខ្លួន និងមួយចំនួនបានមកពី ការលក់ទ្រព្យសម្បត្តិ និងមួយចំនួនបានមកពីប្រាក់កម្ចី ។

#### ២.៣.១.៣ ប្រាក់ផ្ញើត្រឡប់មកផ្ទះ

ដោយភាគច្រើននៃការសម្រេចចិត្តធ្វើចំណាកស្រុក គឺជាការសម្រេចចិត្តរបស់គ្រួសារច្រើនជាងការសម្រេចចិត្តរបស់ជនចំណាកស្រុកផ្ទាល់។ ដូច្នេះពលករចំណាកស្រុកចាកចេញទៅស្វែងរកប្រាក់ដើម្បីគ្រួសារ ច្រើនជាងដើម្បីផ្ទាល់ខ្លួន។

**ក. ការប្រើប្រាស់ប្រាក់ផ្ញើមកផ្ទះ**

ទំនាក់ទំនងរវាងភាពក្រីក្រ និងចំណាកស្រុកនៅតែមានភាពស្មុគស្មាញ។ ភាពក្រីក្រជាកត្តាសំខាន់ដែលនាំឲ្យមានចំណាកស្រុក ហើយចំណាកស្រុកក៏ជាកត្តាសំខាន់មួយដែលជួយកាត់បន្ថយភាពក្រីក្រី។ ការប្រើប្រាស់ប្រាក់ផ្ញើមកផ្ទះ សម្រាប់គោលដៅផលិតកម្ម និងគោលដៅផ្សេងទៀត។ គេប្រើប្រាស់ប្រាក់ផ្ញើ ជាសំខាន់ទី១ សម្រាប់ទិញម្ហូបអាហារ និងសម្រាប់ទិញទ្រព្យផលិតកម្ម ដូចជាគ្រាប់ពូជ ជី និងគោក្របីជាដើម ព្រមទាំងការចំណាយទៅលើមុខងារសង្គមដូចជាអាពាហ៍ពិពាហ៍ សាសនា និងចំនុចសំខាន់នោះគឺ ដើម្បីទ្រទ្រង់ជីវភាពគ្រួសារទាំងមូល។

**ខ. ច្រកផ្ញើប្រាក់ត្រឡប់មកផ្ទះ**

ពលករចំណាកស្រុក ផ្ញើប្រាក់មកផ្ទះជាទៀងទាត់ ដូចនេះការជ្រើសរើសច្រកផ្ញើដែលអាចជឿទុកចិត្តបាន គឺជាបញ្ហាសំខាន់សម្រាប់ពួកគេ។ ពលករចំណាកស្រុកភាគច្រើន ធ្វើការជ្រើសរើសការផ្ញើប្រាក់ត្រឡប់មកផ្ទះតាមរយៈសាច់ញាតិបងប្អូន មិត្តភក្តិ និងអ្នកភូមិជាដើម ឬតាមរយៈការ

មកលេងស្រុកកំណើតផ្ទាល់។ សម្រាប់មធ្យោបាយក្នុងស្រុកវិញភាគច្រើន គឺផ្ញើការផ្ញើតាមរយៈសាច់ញាតិ មិត្តភក្តិ ដូចគ្នា ប៉ុន្តែមធ្យោបាយមួយទៀតនោះគឺការផ្ញើតាមឡានតាក់ស៊ី។ ប៉ុន្តែប៉ុន្មានឆ្នាំចុងក្រោយនេះ យើងសង្កេតឃើញថាដោយសារមានការរីកចម្រើនខាងសេដ្ឋកិច្ចគួរអោយកត់សម្គាល់ នោះការផ្ញើប្រាក់របស់ពលករចំណាកស្រុកបានផ្ញើតាមរយៈ ក្រុមហ៊ុនផ្ញើប្រាក់មួយចំនួនដូចជា (វីងទ្រូម៉ាន់នី...........) ដែលដាក់ដំណើរការដើម្បីមានភាពងាយស្រួលក្នុងការផ្ញើប្រាក់របស់ពលករចំណាកស្រុក ដែលមិនមានការបំពេញឯកសារសាំញ៉ាំច្រើន។ ពលករដែលជ្រើសរើសការផ្ញើប្រាក់តាមសាច់ញាតិ បងប្អូន ព្រោះពួកគាត់ គិតថាជាមធ្យោបាយងាយស្រួល ដោយមិនចាំបាច់ត្រូវបំពេញឯកសារផ្សេងៗឡើយ។[13]

### ២.៣.១.៤ ឥទ្ធិពលនៃការធ្វើចំណាកស្រុក នៅក្នុងការអភិវឌ្ឍន៍សហគមន៍

នគរូបនីយកម្មកសិកម្ម បានពន្លឿនតាំងពីពាក់កណ្ដាលទសវត្សរ៍ឆ្នាំ ១៩៩០មកម្លេះ នៅពេលដែលប្រជាជនចាប់ផ្ដើមធ្វើចំណាកស្រុកឆ្លងដែន។ កសិករមួយចំនួនបានប្រើប្រាស់លុយដែលកូនរបស់ពួកគេផ្ញើមកដើម្បីទិញ ត្រាក់ទ័រ ម៉ាស៊ីនបូមទឹក ដើម្បីបង្កើនទិន្នផលស្រូវរបស់ពួកគេ។ ការរកចំណូលរបស់ពលករចំណាកស្រុកម្នាក់ ត្រូវបានគេចាត់ទុកថាស្មើទៅនឹងដីស្រែមួយហិចតានៅក្នុងបង្ករបង្កើនស្បៀងប្រចាំគ្រួសារ។

## ២.៤ សង្គម និងចំណាកស្រុក

ទ្រឹស្តីទំនាក់ទំនងបានកំណត់ថា ចំណាកស្រុកផុសចេញពីទំនាក់ទំនងផ្ទាល់ខ្លួន ទំនាក់ទំនងខាង វប្បធម៌ និងសង្គមផ្សេងទៀត។ សម្រាប់យុវជនដែលកំពុងរស់នៅក្នុងតំបន់ ឬប្រទេសរបស់ខ្លួន គេអាចទទួលព័ត៌មានស្ដីពីការងារ និងលក្ខខណ្ឌរស់នៅក្នុងតំបន់ប្រទេសគោលដៅចំណាកស្រុក តាមរយៈទំនាក់ទំនងផ្ទាល់ខ្លួន ដូចជាមិត្តភក្តិ និងអ្នកជិតខាងដែលបានធ្វើចំណាកស្រុក។

ការផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត ទោះបីទៅតាមរដូវ ឬទៅជាអចិន្ត្រៃយ៍ក្តី គឺមានហានិភ័យ និងមានបន្ទុកចំណាយខាងហិរញ្ញវត្ថុ និងសង្គម។ ព័ត៌មានទទួលបានត្រឹមត្រូវ និងគ្រប់គ្រាន់ អាចជួយកាត់បន្ថយហានិភ័យក្នុងការធ្វើចំណាកស្រុកបានច្រើន និងបង្កើនការទទួលបានជោគជ័យ។ ការសិក្សាបានបង្ហាញថា ប្រជាជនដែលធ្វើចំណាកស្រុកភាគច្រើន ទទួលបានព័ត៌មានតិចតួច ឬគ្មានសោះពីការងារ ការរស់នៅ និងបរិយាកាសការងារ។ ពួកគេពឹងផ្អែកលើព័ត៌មានក្រៅផ្លូវការ ហើយអ្វីដែលពួកគេទទួលបានមុនពេលសម្រេចចិត្តធ្វើចំណាកស្រុក គឺព័ត៌មានពាក់ព័ន្ធនឹងការងារមិនមែនព័ត៌មានពាក់ព័ន្ធនឹងលក្ខខណ្ឌការងារ និងលក្ខខណ្ឌនៃការរស់នៅនោះទេ។ ចំណុច

---

[13] កញ្ញា ស្រីមុំ ដកស្រង់ចេញពី "បទសម្ភាសន៍ផ្ទាល់ពីជនដែលធ្លាប់ធ្វើចំណាកស្រុក" ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩

នេះបានរំលេចពីទំនាក់ទំនងសង្គមរវាងកម្មករចំណាកស្រុក និងស្រុក ភូមិរបស់ពួកគេ។ ទំនាក់ទំនងអាចជាកត្តាចម្បងដែលកំណត់ជោគជ័យឲ្យកម្មករចំណាកស្រុក ពីព្រោះទំនាក់ទំនងល្អជួយបង្កើនឱកាសទទួលបានការងារមានសុវត្ថិភាព និងកាត់បន្ថយការបោកប្រាស់ ។[14]

### ២.៤.១ ចំណាកស្រុក និង ការកាត់បន្ថយភាពគ្មានការងារធ្វើក្នុងស្រុក

ការធ្វើចំណាកស្រុករបស់ប្រជាជនដែលមានជំនាញតិចតួច ឬគ្មានជំនាញមានផលប៉ះពាល់ជាអវិជ្ជមានយ៉ាងច្រើនចំពោះប្រទេសបញ្ជូនពលករចេញ។ ប្រទេសកម្ពុជាយើងមានកំណើនពលករចំនួលថ្មីប្រហែល៣០០,០០០នាក់ ចូលមកក្នុងទីផ្សារការងារជារៀងរាល់។ ពលករចំណូលថ្មីទាំងអស់នេះ ភាគច្រើនជាពលករមិនមានចំណេះ ឬដែលមានចំណេះតិចតួច និងមានចំណេះដឹងមិនគ្រប់គ្រាន់ទៅនឹងតំរូវការទីផ្សារការងារនាពេលបច្ចុប្បន្ននេះ។ កំណើននេះមានល្បឿនលឿនជាងកំណើនការងារនៅក្នុងស្រុក ដែលមានកំណើនយឺតជាពិសេសកំណើនការងារនៅក្នុងវិស័យកសិកម្ម។ ជាមួយនឹងកំណើនយឺតនេះ រួមផ្សំនឹងកត្តាជំរុញ និងកត្តាអូសទាញផងនោះប្រជាជននៅជនបទភាគច្រើន សម្រេចចិត្តធ្វើចំណាកស្រុកទៅរកការងារធ្វើទាំងនៅក្នុងស្រុក និងក្រៅស្រុក (ឆ្លងដែន)។ នៅក្នុងសេដ្ឋកិច្ចដែលមានកម្លាំងពលកម្មលើស ការធ្វើចំណាកស្រុកនេះ វាបានជួយបន្ធូរនូវសំពាធជាច្រើនដែលបណ្តាលមកពីការផ្គត់ផ្គង់ដ៏ច្រើននៃកម្លាំងពលកម្មគ្មានជំនាញ។ ជាមួយគ្នា នេះវាក៏បានជួយកាត់បន្ថយអ្នកគ្មានការងារធ្វើ និងអ្នកដែលមានការងារធ្វើមិនគ្រប់គ្រាន់ នៅក្នុងប្រទេសបញ្ជូនពលករចេញនោះ ។

### ២.៥ ផលប៉ះពាល់នៃការធ្វើចំណាកស្រុក

ផលប៉ះពាល់នៃការធ្វើចំណាកស្រុកមានទាំងចំណុចវិជ្ជមាន និងចំណុចអវិជ្ជមានអាស្រ័យលើប្រភេទនៃការធ្វើចំណាកស្រុក ជាពិសេសប្រភេទការងារដែលពលករធ្វើការ ទីតាំង និងស្ថានភាពផ្លូវច្បាប់របស់ពលករធ្វើចំណាកស្រុក លទ្ធផលផ្សេងគ្នាពីការជ្រើសរើសប្រភេទក្រុមហ៊ុនពលករដើម្បីនាំពួកគេទៅរកការងារធ្វើ ។

### ២.៥.១ ផលវិជ្ជមាន

ការធ្វើចំណាកស្រុក បានធ្វើអោយប្រសើរឡើងដល់សុខមាលភាពនៅក្នុងគ្រួសារធ្វើឲ្យជីវភាពមានការល្អប្រសើរ ជួយកាត់បន្ថយភាពក្រីក្រ បង្កើននូវកំណើនសេដ្ឋកិច្ចជាតិបានមួយកម្រិតផងដែរតាមរយៈការចេញទៅធ្វើការដែលមានប្រាក់ខែខ្ពស់។ ការធ្វើចំណាកស្រុកក៏មាន

[14] ព្រាភពពី https://soknath.blogspot.com ឆ្នាំ២០១៥

ទំនាក់ទំនងវិជ្ជមានជាមួយនឹងការសម្រេចបាននូវការអប់រំផងដែរតាមរយៈការចេញទៅបន្តការសិក្សានៅក្រៅប្រទេស និងតាមរយៈការចេញទៅបំពេញភារៈកិច្ចផ្សេងៗ។

ផលប្រយោជន៍នៃការធ្វើចំណាកស្រុករបរកសិកម្មជាប្រភពចំណូលដ៏សំខាន់របស់ប្រជាកសិករហើយបន្ទាប់ពីប្រមូលផលស្រូវ រួចពួកគេផ្លាស់ទីមកកាន់ទីក្រុងដើម្បីធ្វើការ។ ការធ្វើការនៅទីក្រុងផ្តល់ប្រាក់ចំណូលបន្ថែម សំរាប់ទ្រទ្រង់ជីវភាពគ្រួសារនៅទីជនបទ។ ម៉្យាងវិញទៀតចំពោះអ្នកដែលគ្មានការងារធ្វើអាចស្វែងរកការងារធ្វើនៅទីក្រុង ដែលអាចជៀសវាងការប្រព្រឹត្តិបទល្មើសផ្សេងៗ។ ជារៀងរាល់ឆ្នាំមានយុវជនកាន់តែច្រើនឡើងៗធ្វើចំណាកស្រុកមកកាន់ទីក្រុងដើម្បីបន្តការសិក្សាជំនាញ វិជ្ជាជីវៈ អេឡិចត្រូនិច និងបច្ចេកទេសផ្សេងៗ។ ការទទួលបានចំណេះដឹង ពីការសិក្សារៀនសូត្រនៅទីក្រុង គេអាចយកចំណេះដឹង ជំនាញបច្ចេកទេសទៅអភិវឌ្ឍន៍តំបន់ជនបទដែលជាស្រុកកំណើតរបស់ខ្លួន។ វិស័យកាត់ដេរនៅប្រទេសកម្ពុជាបានរួមចំណែកអភិវឌ្ឍន៍ប្រទេសដោយបានបង្កើតនូវការងារសំរាប់ប្រជាជន។ រោងចក្រកាត់ដេរភាគច្រើនប្រមូលផ្តុំនៅទីក្រុងភ្នំពេញដូច្នេះមាន ពលការនីជាច្រើនធ្វើបានចំណាកស្រុកមកទីក្រុង។ ពលករ និងពលការនីដែលបានមកធ្វើការងារតាមរោងចក្រនៅទីក្រុងទទួលបានប្រាក់ឈ្នួលសំរាប់ចិញ្ចឹមខ្លួនឯង និងសំរាប់ផ្ញើទៅក្រុមគ្រួសារនៅស្រុកកំណើតនៅឯជនបទ។ ចំពោះ ការធ្វើចំណាកស្រុកទៅក្រៅប្រទេសពលករខ្មែរអាចទទួលបានប្រាក់ចំណូល ឬប្រាក់ខែច្រើនជាងនៅក្នុង ស្រុកពីសំរាប់ផ្ញើមកក្រុមគ្រួសារនៅឯមាតុភូមិ។ ចំណូលដែលរកបានដោយពលករខ្មែរនៅក្រៅប្រទេសធ្វើអោយសេដ្ឋកិច្ចជាតិល្អតលាស់។ ម៉្យាងវិញទៀតនៅពេលដែលពលករត្រលប់មកស្រុកកំណើតវិញពួកគេអាចមានដើមទុនគ្រប់គ្រាន់សំរាប់ ចាប់ផ្តើមអាជីវកម្មធុនតូច ឬ មធ្យមបាន។

### ២.៥.២ . ផលអវិជ្ជមាន

ការធ្វើចំណាកស្រុកត្រូវបានគេមើលឃើញថាមានភាពងាយរងគ្រោះ ការរំលោភបំពាន និងការរស់នៅក្នុងស្ថានភាពយ៉ាប់យ៉ឺន ពលករចំណាកស្រុកភាគច្រើនចូលរួមនឹងការងារ៣ប្រភេទ គឺការងារកង្វក់ គ្រោះថ្នាក់ លំបាក។ ពលករចំណាកស្រុកដែលត្រូវបានគេរំលោភបំពាន គឺពលករចំណាកស្រុកខាង វិស័យនេសាទ ត្រូវបានរស់នៅក្នុងស្ថានភាពយ៉ាប់យ៉ឺន ទីកន្លែងតូចចង្អៀតគ្មានអនាម័យនិងត្រូវបានប្រឈមមុខនឹងអំពើហឹង្សា និងការប្រើប្រាស់គ្រឿងញៀន។ ពលករដែលគ្មានឯកសារ ពុំសូវទទួលបានសេវាសុខភាព ហើយពួកគេពួកគេព្យាយាមរត់ចេញពីការចាប់ខ្លួននិរទេស ហើយផលវិបាកមួយទៀត ពីការធ្វើចំណាកស្រុកគឺ បាត់បង់កំលាំងពលកម្ម រារាំងការធ្វើកសិកម្ម ឬសកម្មភាពសេដ្ឋកិច្ចដ៏ទៃទៀតនៅក្នុងសហគមន៍កំណើតរបស់គេ ។

### ២.៥.២.១ ផលប៉ះពាល់លើគ្រួសារ និងសហគមន៍ដែលមានសមាជិកធ្វើចំណាកស្រុក

ចំពោះអ្នកដែលធ្វើការចំណាកស្រុកនៅក្នុងគ្រួសារនៅពេលដែលបានចេញទៅធ្វើការ ហើយមានការភ្លើតភ្លើន និងភាពសប្បាយភ្លេចខ្លួននៅទីនោះ ដូចជាការមានដៃគូនារី ឬបុរសនៅពេលដែលគាត់ត្រលប់មកលេងស្រុកកំណើតម្តងៗគឺតែងនាំយកមកនូវជំងឺប្លែកៗចូលមកក្នុងគ្រួសារ។ ម្យ៉ាងវិញទៀតការធ្វើចំណាកស្រុកនេះមិនមានការអភិវឌ្ឍន៍ ឬអភិវឌ្ឍតិចតួចនៅក្នុងសហគមន៍ ជាពិសេសទៅលើកម្លាំងពលកម្មក្នុងការធ្វើកសិកម្ម និងបាត់បង់ធនធានមនុស្ស។ អ្នកធ្វើការចំណាកស្រុកភាគច្រើនមានអាយុចន្លោះពី ១៥ ទៅ ៣៩ឆ្នាំ ដែលមានកម្លាំងសកម្មនៅក្នុងវិស័យសេដ្ឋកិច្ច។ ពួកគាត់មិនមានចំណេះដឹងជ្រៅជ្រះ ដែលភាគច្រើនរៀនបានត្រឹមថ្នាក់អនុវិទ្យាល័យប៉ុណ្ណោះ។ ការធ្វើចំណាកស្រុកមានផលប៉ះពាល់យ៉ាងច្រើនដល់គ្រួសារ និងសហគមន៍ ។

### ២.៥.២.២ ផលប៉ះពាល់លើសុភមង្គលគ្រួសារ

ព្រោះតែជីវភាពរស់នៅប្រចាំនៅក្នុងគ្រួសារទើបត្រូវបង្ខំចិត្តចាកចេញពីស្រុកកំណើត។ ការធ្វើចំណាកស្រុកដើម្បីផ្គត់ផ្គង់ជីវភាពនៅក្នុងគ្រួសារជារឿងសំខាន់ តែការដែលបានរស់នៅជួបជុំគ្រួសារជារឿងសំខាន់សម្រាប់សុភមង្គលគ្រួសារ។ ប៉ុន្តែដោយសារតែបច្ចុប្បនមានការរីកចម្រើនផ្នែកបច្ចេកវិទ្យា ប្រជាជនអាចទំនាក់ទំនងមកកាន់គ្រួសារតាមរយៈប្រព័ន្ធទូរស័ព្ទ កុំព្យូទ័រ និងបណ្តាញសង្គមផ្សេងៗ បូករួម ទាំងតម្លៃសេវាកម្មទូគមនាគមន៍មានតម្លៃសមរម្យផងនោះ ប្រជាជនចំណាកស្រុកភាគច្រើនបានសម្រេចចិត្តធ្វើទំនាក់ទំនងជាមួយគ្រួសារតាមមធ្យោបាយទាំងអស់នោះជាញឹកញាប់ផងដែរ។ ប៉ុន្តែការឆ្លើយតបទាំងអស់នោះបានត្រឹមតែឃើញរូបភាព និងសម្លេងប៉ុណ្ណោះ តែភាពស្និទស្នាល និងភាពផ្អែមល្ហែមមិនគ្រប់គ្រាន់នោះឡើយ ។

### ២.៥.២.៣ ផលប៉ះពាល់លើកម្លាំងពលកម្មក្នុងគ្រួសារ

យើងបានដឹងហើយថាប្រទេសកម្ពុជា ជាប្រទេសដែលពឹងផ្អែកទៅលើវិស័យកសិកម្មជាចម្បង។ ហើយប្រជាជននៅតាមជនបទភាគច្រើនប្រកបរបរចិញ្ចឹមជីវិតដោយការធ្វើកសិកម្ម ស្រែ ចម្ការជាដើម។ ទោះជាការធ្វើកសិកម្មសព្វថ្ងៃមានការរីកចម្រើន ដោយសារមានគ្រឿងចក្រសម្រាប់ច្រូតកាត់យ៉ាងណាក្តី ក៏នៅតែទាមទារកម្លាំងមនុស្សរួមជាមួយផងដែរ។ ម្យ៉ាងទៀតការប្រើប្រាស់គ្រឿងយន្តនេះផងដែរក៏ត្រូវការកម្លាំងមនុស្ស និងសត្វជាចម្បងដដែល។ ដោយសារមានការធ្វើចំណាកស្រុករបស់សមាជិកក្នុងគ្រួសារ ទើបធ្វើឲ្យគ្រួសារមួយចំនួនប្រឈមនិងបញ្ហាខ្វះខាតកម្លាំងពលកម្មក្នុងការធ្វើកសិកម្ម។ ម្យ៉ាងទៀតដោយសារការធ្វើចំណាកស្រុកច្រើន ពួកគេចំណាកស្រុកទៅធ្វើការទទួលបានប្រាក់ខែដែលធ្វើឲ្យ អ្នកចំណាកស្រុកមួយចំនួនលែងចង់ធ្វើស្រែ ចម្ការព្រោះមិនចង់ប្រលាក់

ភក់ជ្រាំទៀត ដែលតម្រូវឲ្យ គ្រួសារជួលកម្លាំងពលកម្មគេជំនួសវិញ។ ហេតុនេះហើយទើបធ្វើឲ្យកម្លាំងក្នុងសហគមន៍ខ្វះខាតកម្លាំងពលកម្មដូចពីមុន ។

**២.៥.២.៤ ផលប៉ះពាល់នៃចំណាកស្រុកលើតំបន់ដែលគេចាកចេញ**

តាមរយៈការបកស្រាយខាងលើ យើងបានដឹងហើយថាការធ្វើចំណាកស្រុកពិតជាផ្តល់ផលប៉ះពាល់យ៉ាងច្រើននៅក្នុងគ្រួសារ ជាពិសេសទៅលើសហគមន៍ផងដែរ

- កម្លាំងពលកម្មឡើងថ្លៃ៖ នៅពេលដែលមានអ្នកធ្វើចំណាកស្រុកច្រើន ជាពិសេសអ្នកចំណាកស្រុកភាគច្រើនជាមនុស្សដែលមានវ័យចន្លោះពី ១៥ទៅ៣៩ឆ្នាំ ដែលពេញកម្លាំងផងនោះធ្វើឲ្យមានការឡើងថ្លៃនូវតម្លៃថ្លៃឈ្នួលពលកម្មសម្រាប់ការធ្វើស្រែ ចំការ ពីព្រោះនៅក្នុងគ្រួសារមានតែមនុស្សចាស់ និងកូនក្មេងតែប៉ុណ្ណោះ។ ដូច្នេះពេលរដូវធ្វើស្រែមកដល់ដើម្បីធ្វើស្រែឲ្យទាន់រដូវ ពិតណាស់គឺពួកគាត់ត្រូវតែជួលកម្លាំងមនុស្សដើម្បីធ្វើស្រែ ប៉ុន្តែការជួលគឺមានតម្លៃថ្លៃ ព្រោះមិនសូវមានអ្នកនៅធ្វើការងារនេះច្រើននោះទេ ព្រោះជាការងារប្រើកម្លាំងច្រើន និងទទួលបានប្រាក់កម្រៃទាប។
- ខ្វះខាតកម្លាំងសម្រាប់អភិវឌ្ឍភូមិ ឃុំ៖ ការអភិវឌ្ឍ គឺមានការពឹងផ្អែកលើប្រជាជន និងអ្វីដែលជាការចាំបាច់នៅក្នុងតំបន់ផងដែរ។ ដោយសារប្រជាជនធ្វើចំណាកស្រុកច្រើនទើបធ្វើឲ្យប្រជាជននៅក្នុងស្រុកមានចំនួនតិចខ្វះខាតនូវកម្លាំងពលកម្មខ្វះខាតនូវធានធានមនុស្សនិងកម្លាំងនៃការអភិវឌ្ឍ។ ម្យ៉ាងទៀតប្រជាជនចំណាកស្រុកចំនួនពុំបានវិលត្រឡប់មកស្រុកកំណើតវិញ។

**២.៥.២.៥ ផលប៉ះពាល់នៃការធ្វើចំណាកស្រុកមកលើកុមារ**

ប្រទេសកម្ពុជា គឺជាហត្ថលេខីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលមាត្រា ១២ ចែងថា គួរមានការពិចារណាលើទស្សនៈរបស់កុមារពាក់ព័ន្ធនឹងការសម្រេចចិត្ត ដែលប៉ះពាល់ដល់ជីវិត និងសុខមាលភាពរបស់ពួកគេ។ ការស្រាវជ្រាវភាគច្រើនគឺផ្តោតសំខាន់ទៅលើផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចដែលការធ្វើចំណាកស្រុកមានដោយផ្ទាល់លើសេដ្ឋកិច្ចរបស់គ្រួសារនីមួយៗ និងលើប្រទេសទាំងមូល។ ប៉ុន្តែក្រោយមកការស្រាវជ្រាវបានបង្ហាញថាការធ្វើចំណាកស្រុកមិនត្រឹមតែផ្តល់ផលប៉ះពាល់មកលើជនចំណាកស្រុកនោះទេ ប៉ុន្តែការធ្វើចំណាកស្រុកបានផ្តល់ប៉ះពាល់ដល់សមាជិកគ្រួសារជាពិសេសនោះគឺកុមារ ។[15]

[15] អនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែម មាត្រា១២ ទំព័រ ២២ (បោះពុម្ពខែមិថុនាឆ្នាំ២០០៩ ដោយ អង្គការ Unicef Cambodia)

**ក. ផលប៉ះពាល់លើកុមារដែលត្រូវទុកចោល**

អាយុរបស់កុមារជាកត្តាសំខាន់ក្នុងការសម្រេចចិត្តថាតើត្រូវយកកុមារទៅតាមឬអត់ នៅពេលដែលឪពុកម្តាយសម្រេចចិត្តធ្វើចំណាកស្រុក។ កុមារតូចៗច្រើនតែត្រូវបានទុកចោល ខណៈដែលកុមារដែលមានអាយុលើសពី១៥ឆ្នាំ ច្រើនតែធ្វើដំណើរទៅតាមឪពុកម្តាយ ឬសាច់ញាតិផ្សេងទៀត។ កុមារដែលត្រូវទុកចោលនោះ គឺជីដូនជីតាជាអ្នកផ្តល់ការថែទាំ។ ដោយជីដូនជីតាភាគច្រើនគឺមានបញ្ហាសុខភាពនិងជួបការលំបាករៀងរាល់ថ្ងៃដោយសារតែបន្ទុកមើលថែចៅៗ។ កុមារភាគច្រើនដែលរស់នៅជាមួយជីដូនជីតាគឺមិនត្រូវបានមើលថែដិតដល់ និងត្រឹមត្រូវនោះឡើយ ។

**ក.១ ការទទួលបានការអប់រំ**

ការសិក្សាស្រាវជ្រាវមួយដែលធ្វើឡើងដោយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា អំពីផលប៉ះពាល់នៃការធ្វើចំណាកស្រុកលើកុមារដែលត្រូវបានគេទុកចោលបានរកឃើញថា ការធ្វើចំណាកស្រុកចេញក្រៅរបស់មនុស្សពេញវ័យមានផលប៉ះពាល់អវិជ្ជមានលើការ រៀនសូត្ររបស់កុមារ។ កុមារក្នុងគ្រួសារចំណាកស្រុកច្រើនតែបោះបង់ចោលការសិក្សាជាពិសេសកុមារីដោយហេតុថា ពួកគេត្រូវរួមចំណែកធ្វើការងារផ្ទះ និងរកចំណូលជួយគ្រួសារ ឬអាចមានចំណាប់អារម្មណ៍តិចតួចបំផុតលើការរៀនសូត្រ ។

**ក.២ កិច្ចការពារកុមារ**

ទាំងកុមារដែលធ្វើចំណាកស្រុកតាមឪពុកម្តាយរបស់ពួកគេ រួមទាំងកុមារដែលឪពុកម្តាយធ្វើចំណាកស្រុកចោល សុទ្ធតែជួបប្រទះនឹងការគំរាមកំហែងចំពោះសុវត្ថិភាពរបស់គេ។ ការព្រួយបារម្ភដែលកើតមានជាទូទៅជាងគេសម្រាប់កុមារគឺរយៈពេលដែលកុមារចំណាយដោយពុំមានការឃុំគ្រងពីមនុស្សពេញវ័យ។ កុមារជាច្រើនត្រូវបានរំលោភបំពានផ្លូវភេទ និងផ្លូវកាយក្រោយពេលទុកជាមួយសាច់ញាតិនៅពេលដែលឪពុកម្តាយរបស់ពួកគេធ្វើចំណាកស្រុក ។

**ក.៣ សុខុមាលភាពផ្លូវអារម្មណ៍ និងផ្លូវចិត្ត**

កុមាររងការទទួលរងផលប៉ះពាល់អវិជ្ជមានខាងផ្លូវអារម្មណ៍ និងផ្លូវចិត្តជាច្រើន ដោយសារតែការធ្វើចំណាកស្រុក ដូចជាការរំខានដល់ទំនាក់ទំនងដល់រវាងឪពុកម្តាយ និងកូនជាដើម។ គ្រួសារភាគច្រើនមកលេងផ្ទះតែម្តងប៉ុណ្ណោះក្នុងមួយឆ្នាំ ដោយសារតែការចាយលើការធ្វើដំណើរ។ ជីដូនម្នាក់និយាយថាចៅស្រីរបស់គាត់រស់នៅជាមួយភាពក្រៀមក្រំរហូតដោយសារតែនាងនឹកឪពុកម្តាយ។

**ខ. ផលប៉ះពាល់លើកុមារដែលធ្វើចំណាកស្រុកជាមួយឪពុកម្តាយ**

កុមារអាយុច្រើន ច្រើនតែធ្វើចំណាកស្រុកទៅជាមួយឪពុកម្តាយ។ ផលប៉ះពាល់លើសុខុមាលភាពរបស់កុមារដែលធ្វើចំណាកស្រុកទៅជាមួយឪពុកម្តាយគឺខុសគ្នាពីកុមារដែលទុកនៅ

ផ្ទះ សម្រាប់កុមារដែលធ្វើចំណាកស្រុកជាមួយឪពុកម្តាយបញ្ហាធំជាងគេគឺរកឃើញក្នុងការបន្តការរៀនសូត្របញ្ហាការពារកុមារផងដែរ។

### ខ.១ ការទទួលបានការអប់រំ និងការបន្តការសិក្សា

ទំនាក់ទនង រវាងការសិក្សានិងកំពុងបានការទទួលយកចិត្តទុកដាក់ពិសេសក្នុងប្រទេសកម្ពុជា និងក្នុងប្រទេសផ្សេងទៀតក្នុងតំបន់ ដោយសារតែការកើនឡើងនូវនិន្នាការនៃកាធ្វើចំណាកស្រុក។ ការសិក្សាថ្មីមួយអំពីករណីបោះបង់ចោលការសិក្សានៅសាលាមធ្យមសិក្សាបឋមភូមិ (ក្រុមប្រឹក្សាជាតិដើម្បីកុមារឆ្នាំ២០១៥) បានលើកឡើងថាការធ្វើចំណាកស្រុកគឺជាមូលហេតុមួយក្នុងចំណោមមូលហេតុនានាដែលធ្វើឲ្យកុមារបោះបង់ចោលការសិក្សា។ បើទោះបីជាការអប់រំនៅបឋមសិក្សា និងមធ្យមសិក្សាផ្តល់ដោយមិនគិតថ្លៃក្នុងប្រទេសកម្ពុជាក៏ដោយ គ្រួសារអ្នកធ្វើចំណាកស្រុកនៅតែជួបនឹងបញ្ហាប្រឈមនៅពេល ដែលពួកគេចុះឈ្មោះកូនៗរបស់ពួកគេអោយចូលរៀននៅកន្លែងថ្មី។

ខណៈពេលដែលការចុះឈ្មោះចូលរៀនជាផ្លូវការបើក ទទួលកុមារនៅគ្រប់ទីតាំងទាំងអស់ក្នុងប្រទេសគេត្រូវការសំបុត្រកំណើតដើម្បីអាចចុះឈ្មោះបាន។ សំបុត្រកំណើតទំនងហាក់ដូចជាតម្រូវការដ៏តឹងរឹងសម្រាប់ការចុះឈ្មោះចូលរៀន។ តម្រូវការសំបុត្រកំណើតហាក់ដូជាមានសារៈសំខាន់២ ទី១ គឺសំដៅក្នុងការសំរេចចិត្តដាក់សិស្សអោយចូលកំរិតថ្នាក់ត្រូវតាមអាយុ ទី២ គឺដើម្បីជួយជំរុញការចុះសំបុត្រកំណើត។ ទោះជាយ៉ាងណាក៏ដោយក្នុងការអនុវត្តន៍ ជាក់ស្តែងតម្រូវការសំបុត្រកំណើតបានក្លាយជាឧបសគ្គសម្រាប់គ្រួសារធ្វើចំណាកស្រុកមួយចំនួនក្នុងការចុះឈ្មោះកូននៅសាលារៀន ។

បញ្ហាប្រឈមមិនរំពឹងទុកមួយទៀតដែលគ្រួសារក្រីក្រមួយចំនួនជួបប្រទះ ក្រោយពេលចុះឈ្មោះឲ្យកូនចូលរៀនក្នុងទីក្រុងភ្នំពេញគឺចំណាយខ្ពស់លើការបង់ថ្លៃសាលា។ ដោយឡែកកុមារដែលធ្វើការចំណាកស្រុកទៅក្រៅប្រទេសជាមួយឪពុកម្តាយ ដូចជាប្រទេសថៃ ក៏ជួបនឹងបញ្ហាប្រឈមមួយចំនួនក្នុងការទទួលបានការអប់រំ។ បញ្ហាប្រឈមទាំងនោះមានដូចជា កង្វះខាតឯកសារត្រឹមត្រូវភាពចាំបាច់ក្នុងការរកចំណូល និងការប្រែប្រួលរយៈពេលរស់នៅ។ ការបន្តការសិក្សាក្រោយពេលចំណាកស្រុកទៅតំបន់ ទីក្រុងក៏ជួបនឹងការលំបាកផងដែរ ជាពិសេសកុមារដែលមានអាយុចន្លោះពី១៥ទៅ១៨ឆ្នាំ។ ដោយសារ ក្នុងអាយុនេះគឺកុមារអាចធ្វើការដូចជាឪពុកម្តាយរបស់ពួកគេផងដែរ ជាពិសេសសម្រាប់កុមារដែលរស់នៅក្នុងគ្រួសារក្រីក្រ គឺបានបោះបង់ចោលឱកាសនេះព្រោះដោយសារមានការចំណាយខ្ពស់ទៅលើការសិក្សាផងដែរ។ ក្នុងបរិបទនេះ ឱកាសសេដ្ឋកិច្ច

ដែលមាននៅរាជធានីភ្នំពេញអាចមានឥទ្ធិពលដោយប្រយោលធ្វើឲ្យកុមារដែលមានអាយុចន្លោះ ១៥ ទៅ១៨ឆ្នាំ បោះបង់ចោលការសិក្សាដើម្បីធ្វើដំណើរមករកការងារធ្វើ ។

**ខ.២ ពលកម្មកុមារ និងសុវត្ថិភាពផ្លូវកាយ**

កុមារដែលមានអាយុច្រើនដែលធ្វើការជាកម្មករសំណង់ ត្រូវបានចាត់ទុកថាជាការងារគ្រោះថ្នាក់ ដោយសារកម្រិតហានិភ័យ និងសម្ភារដែលប្រើប្រាស់។ ការព្រួយបារម្ភមួយទៀតនោះ សុវត្ថិភាពកុមារដែលធ្វើចំណាកស្រុកតាមឪពុកម្តាយរបស់ពួកគេ។ ទាំងកុមារដែលធ្វើចំណាកស្រុកតាមឪពុកម្តាយ ឫធ្វើចំណាកស្រុកម្នាក់ឯង គឺត្រូវរស់នៅតាមការដ្ឋានសំណង់។ ដោយការរស់នៅតាមការដ្ឋានសំណង់នេះផងដែរគឺផ្តល់ផលប៉ះពាល់ដល់កុមារផងដែរ បរិស្ថានជុំវិញប្រកបដោយគ្រោះថ្នាក់។ ដោយឡែកកុមារដែលធ្វើចំណាកស្រុកទៅប្រទេសថៃមានការប្រឈមនឹងផលប៉ះពាល់អវិជ្ជមាន ខាងសុវត្ថិភាពខ្លាំងជាងកុមារដែលធ្វើចំណាកស្រុកនៅក្នុងប្រទេស ។

**២.៦ បញ្ហាប្រឈម**

ការធ្វើចំណាកស្រុកទោះបីជាបានផ្តល់ប្រយោជន៍ជាច្រើនដល់ប្រជាជនធ្វើអោយជីវភាពគ្រួសារ មានភាពល្អប្រសើរមួយក៏ដោយ ប៉ុន្តែប្រជាជនចំណាកស្រុកទាំងនោះត្រូវប្រឈម នឹងបញ្ហាផ្សេងៗជាច្រើន ជាពិសេសបញ្ហាដែលតែកើតមានជារឿយៗនោះ គឺការប្រឈមនឹងការជួញដូរមនុស្ស។

**២.៦.១ ការជួញដូរមនុស្ស**

ការជួញដូរមនុស្សធ្វើឲ្យព្រាត់ប្រាស់គ្រួសារ បំផ្លាញនីតិរដ្ឋ និង ជំរុញដល់សកម្មភាពការជួញដូរមនុស្សគឺជាបញ្ហាមួយក្នុងចំណោមបញ្ហាដ៏សោកសៅបំផុត ទាក់ទងនឹងសិទ្ធិមនុស្ស។ បទល្មើសជាអន្តរជាតិដទៃទៀត។ ការជួញដូរមនុស្សគំរាមគំហែង សុវត្ថិភាពសាធារណៈ និងសន្តិសុខសង្គមជាតិ។[16]អំពើរ ជួញដូរមនុស្ស កើតឡើងនៅពេលដែលមនុស្សម្នាក់ត្រូវបង្ខំឲ្យធ្វើការងារ ដែលស្ថិតនៅក្នុងស្ថានភាពកេងប្រវ័ញ្ច និងមិនអាចគេចចេញពីបានពីស្ថានភាពនោះ។ តាមធម្មតាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជាជនក្រីក្រ ហើយធ្វើចំណាកស្រុកដើម្បីស្វែងរកការងារធ្វើ ទាំងនៅក្នុងប្រទេស និងឆ្លងដែនទៅក្រៅប្រទេសដើម្បីរកប្រាកចំណូលជួយផ្គត់ផ្គង់ជីវភាពគ្រួសារ។ ដោយសារតែមានជំនាញតិចតួច ហើយត្រូវការប្រាក់កម្រៃនោះបង្ខំចិត្តដើម្បីទៅស្វែងរកការងារធ្វើ។ ប្រជាជនដែលធ្វើចំណាកស្រុកភាគច្រើនស្វែងរកការងារជាកម្មករសំណង់ អ្នកបំរើតាមផ្ទះ ឫបុគ្គលិកធ្វើការតាមកន្លែងកំសាន្តនានា ដោយទទួលបានកម្រៃតិចតួច មានករណីខ្លះមិនបានទទួល

[16] របាយការណ៍ប្រចាំឆ្នាំ ២០១៧ ការជួញដូរមនុស្ស របស់ ស្ថានទូត សហរដ្ឋអាមេរិក ប្រចាំព្រះរាជាណាចក្រកម្ពុជា

ប្រាក់កម្រៃអ្វីទាល់តែសោះ ព្រមទាំងត្រូវបានកេងប្រវ័ញ្ចទៀតផង។ ដោយប្រជាជនមួយចំនួនអាចធ្លាក់ជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

កម្ពុជាគឺជាប្រទេសដែលជាប្រភពប្រទេសផ្សេងទៀតធ្វើការឆ្លងកាត់ និងជាប្រទេសគោលដៅសំរាប់បុរស ស្ត្រី និងកុមារ ដែលរងគ្រោះដោយការបង្ខំអោយធ្វើពលកម្ម និងការជួញដូរផ្លូវភេទ។ ស្ត្រី និង កុមារកម្ពុជាធ្វើបំលាស់ទីទៅកាន់បណ្តាប្រទេសនៅក្នុងតំបន់ ជាពិសេសប្រទេសថៃនិងប្រទេសម៉ាឡេស៊ី ដើម្បីរកការងារធ្វើ ហើយមានច្រើននាក់ត្រូវរងគ្រោះដោយការជួញដូរផ្លូវភេទ ទាសភាពនៅផ្ទះ ទាសភាពបំណុលដោះមិនរួច ឬស្ថានភាពត្រូវបានគេបង្ខំអោយធ្វើពលកម្មធ្ងន់ធ្ងរ ក្នុងទូកនេសាទ សំណង់ និងកសិឧស្សាហកម្ម។ ការមិនយល់ពីកាតព្វកិច្ច ការមិនចេះអានកិច្ចព្រមព្រៀង ឬគ្មានលុយបង់ថ្លៃក្រដាសស្នាម បានធ្វើអោយអ្នកធ្វើការចំណាកស្រុកកម្ពុជាខ្លះងាយរងនឹងការបង្ខំអោយធ្វើពលកម្ម និងបំណុលទាសភាព ពិសេសនៅប្រទេសម៉ាឡេស៊ី។ អ្នកធ្វើការទាំងនេះបាននិយាយពីការដែលថៅកែក្នុងប្រទេសដែលគេទៅដល់នោះ ដកហូតសំណៅនៃកិច្ចសន្យាការងារ ឬដកហូតលិខិតឆ្លងដែន។ យោងតាមអង្គការពលកម្មពិភពលោក មានកុមារធ្វើពលកម្មក្នុងទំរង់ធ្ងន់ធ្ងរបំផុតដទៃទៀតដែលរួមមានការងារផ្នែកកសិកម្ម ការធ្វើឥដ្ឋ ក្បឿង ការដើរលក់តាមផ្លូវ និងការដើរសុំទាន។ កុមារទាំងនេះងាយរងគ្រោះនឹងការជួញដូរមនុស្សណាស់។ ម៉្យាងទៀតការជួញដូមនុស្សនៅក្រៅប្រទេសកម្ពុជាតែងតែកើតឡើងនូវទម្រង់នៃការជួញដូរមនុស្សតាមរយៈអាពាហ៍ពិពាហ៍ ពលកម្មដោយបង្ខំលើនាវានេសាទ និង ការងារតាមផ្ទះ និងការបង្ខំអោយសុំទាន។[17]

**២.៦.១.១ ការជួញដូរតាមរយៈការរៀបអាពាហ៍ពិពាហ៍**

ការជួញដូរតាមរយៈការរៀបអាពាហ៍ពិពាហ៍បានកើតឡើងក្នុងចំណោមស្ត្រីខ្មែរមួយចំនួនដែលបានរៀបអាពាហ៍ពិពាហ៍តាមរយៈឈ្មួញកណ្តាលជាមួយបុរសជនជាតិចិន កូរ៉េ និងតៃវ៉ាន់។ ស្ត្រីទាំងនេះ ស្វែងរកជីវិតដ៏ល្អប្រសើរ ដោយការរៀបការជាមួយបុរសបរទេស ប៉ុន្តែចុងក្រោយបានក្លាយជាមនុស្ស ដែលត្រូវបានគេរំលោភបំពានដោយស្វាមី ឬសាច់ញាតិរបស់ស្វាមីពួកគេ និងនៅក្នុងលក្ខខណ្ឌអាក្រក់បំផុតពួកគេត្រូវបានបង្ខំអោយធ្វើជាស្រីពេស្យា។ ស្ត្រីខ្លះត្រូវបានគេសន្យាថានឹងទទួលបានការងារនៅ រោងចក្រប៉ុន្តែពួកគេត្រូវបានបោកបញ្ឆោត និងបង្ខំអោយរៀបការ។ នៅឆ្នាំ២០១៦អាជ្ញាធរចិនបានរាយការណ៍ថាស្ត្រីកម្ពុជាចំនួន ៧០០០នាក់ បានរៀបការជាមួយជនជាតិចិនប៉ុន្តែមានតែ១០ នាក់ប៉ុណ្ណោះដែលបានរៀបការស្របច្បាប់។

[17] វិទ្យាស្ថានសភាកម្ពុជា "ការធ្វើចំណាកស្រុក ការទប់ស្កាត់ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ" ភ្នំពេញ ខែកក្កដា ឆ្នាំ ២០១៧

**២.៦.១.២ ពលកម្មដោយបង្ខំលើនាវានេសាទ**

ការងារដោយបង្ខំកាន់តែធ្ងន់ធ្ងរទៅៗ ក្នុងចំណោមពលករចំណាកស្រុកដែលធ្វើការនៅក្នុងឧស្សាហកម្មនេសាទនៅក្នុងប្រទេសដូចជា ប្រទេសថៃ ម៉ាឡេស៊ី ជាដើម។ ករណីពលករចំណាកស្រុកទាំងនេះត្រូវបានគេបង្ខំអោយធ្វើការចាប់ពី ១៦ម៉ោង ទៅ១៨ម៉ោង ក្នុងមួយថ្ងៃលើនាវានេសាទ ដោយគ្មានមធ្យោបាយគេចខ្លួន។ ក្រៅពីធ្វើការយូរ ពលករគ្មានថ្ងៃឈប់សម្រាកទេ មិនទទួលបានអាហារ និងប្រាក់ខែគ្រប់គ្រាន់ ។

**២.៦.១.៣ ពលកម្មដោយបង្ខំតាមរយៈការងារតាមផ្ទះ**

ពលកម្មដោយបង្ខំក្នុងការងារផ្ទះគឺជាបទឧក្រិដ្ឋមួយផ្សេងទៀត។ ពលករកម្ពុជាត្រូវបានគេរាយការណ៍ថាត្រូវបានគេជួញដូរទៅប្រទេសម៉ាឡេស៊ី ដើម្បីបម្រើការងារតាមផ្ទះ ធ្វើការជាអ្នកថែទាំកុមារ និងថែទាំមនុស្សចាស់ ឬអ្នកជំងឺ។ ទោះបីជាទទួលបានប្រាក់ខែខ្ពស់ ប៉ុន្តែពលករចំណាកស្រុកទាំងនោះទទួលការរំលោភបំពានធ្ងន់ធ្ងរ ហើយត្រូវបានគេរាយការណ៍ញឹកញាប់ថាមានបញ្ហាផ្លូវចិត្តនៅពេលត្រឡប់មកផ្ទះវិញ។

**២.៦.១.៤ ការបង្ខំអោយសុំទាន**

កុមារកម្ពុជាត្រូវបានរាយការណ៍ថាត្រូវបានគេជួញដូរសម្រាប់ឲ្យសុំទាន នៅប្រទេសជិតខាងដូចជា ប្រទេសថៃ ជាដើម។ ដោយនៅក្នុងឆ្នាំ២០១៤ ប្រហែលជា៨០%នៃកុមារសុំទាននៅប្រទេសថៃជាជនជាតិខ្មែរ ។

## ២.៧ ផលប្រយោជន៍នៃការធ្វើចំណាកស្រុក

របរកសិកម្មជាប្រភពចំណូលដ៏សំខាន់របស់ប្រជាកសិករហើយបន្ទាប់ពីប្រមូលផលស្រូវ រួចពួកគេផ្លាស់ទីមកកាន់ទីក្រុងដើម្បីធ្វើការ។ ការធ្វើការនៅទីក្រុងផ្តល់ប្រាក់ចំណូលបន្ថែមសំរាប់ទ្រទ្រង់ជីវភាពគ្រួសារនៅទីជនបទ។ ម៉្យាងវិញទៀតចំពោះអ្នកដែលគ្មានការងារធ្វើ អាចស្វែងរកការងារធ្វើនៅទីក្រុងដែលអាចជៀសវាងការប្រព្រឹត្តបទល្មើសផ្សេងៗ។

ជារៀងរាល់ឆ្នាំមានយុវជនកាន់តែច្រើនឡើងៗធ្វើចំណាកស្រុកមកកាន់ទីក្រុងដើម្បីបន្តការសិក្សាជំនាញ វិជ្ជាជីវៈ អេឡិចត្រូនិច និង បច្ចេកទេសផ្សេងៗ។ ការទទួលបានចំនេះដឹង ពីការសិក្សារៀនសូត្រនៅទីក្រុងគេអាចយកចំនេះដឹងជំនាញបច្ចេកទេសទៅអភិវឌ្ឍន៍តំបន់ជនបទដែលជាស្រុកកំណើត។ វិស័យកាត់ដេរនៅប្រទេសកម្ពុជាបានរួមចំណែកអភិវឌ្ឍន៍ប្រទេសដោយបានបង្កើតនូវ ការងារសំរាប់ប្រជាជន។ រោងចក្រកាត់ដេភាគច្រើនប្រមូលផ្តុំនៅទីក្រុងភ្នំពេញដូច្នេះមាន ពលការនីជាច្រើនធ្វើបានចំណាកស្រុកមកទីក្រុង។ ពលករ និងពលការនី ដែលបានមក ធ្វើ

ការងារតាមរោងចក្រនៅទីក្រុងទទួលបានប្រាក់ឈ្នួលសំរាប់ចិញ្ចឹមខ្លួនឯង និងសំរាប់ផ្ញើទៅក្រុមគ្រួសារនៅស្រុកកំណើតនៅឯជនបទ។

ចំពោះការធ្វើចំណាកស្រុកទៅក្រៅប្រទេសពលករខ្មែរអាចទទួលបានប្រាក់ចំណូលឬ ប្រាក់ខែច្រើនជាងនៅក្នុងស្រុកពីសំរាប់ផ្ញើមកក្រុមគ្រួសារនៅឯមាតុភូមិ។ ចំណូលដែល រកបានដោយពលករខ្មែរនៅក្រៅប្រទេសធ្វើអោយសេដ្ឋកិច្ចជាតិលូតលាស់។ ម្យ៉ាងវិញទៀត ពេលពលករត្រលប់មកស្រុកកំណើតវិញពួកគេអាចមានដើមទុនគ្រប់គ្រាន់សំរាប់ ចាប់ផ្ដើមអាជីវកម្មធុនតូច ឬ មធ្យម។

ប្រជាជនដែលផ្លាស់ទីទៅកាន់បរទេសដើម្បីទទួលបានសិក្សាការអប់រំជាធនធានមនុស្ស សំរាប់ការអភិវឌ្ឍន៍ប្រទេសព្រោះពួកគេទទួលបានចំនេះដឹងបទពិសោធន៍ផ្សេងៗពីខាងក្រៅប្រទេសចូលមកប្រទេសជាតិខ្លួន។ ដូចនេះ ការធ្វើចំណាកស្រុកដោយស្របច្បាប់ និងមានសុវត្ថិភាពពិតជាផ្តល់នូវអត្ថប្រយោជន៍ដល់ពលករផ្ទាល់ និងប្រទេសជាតិទាំងមូលផងដែរ។[18]

## ២.៨ ផលវិបាកនៃការធ្វើចំណាកស្រុក

ជាការពិតណាស់ការធ្វើចំណាកស្រុកទាំងពីរប្រភេទនេះ សុទ្ធតែផ្តល់នូវផលវិបាកជាច្រើនដល់ពលករដែលធ្វើចំណាកស្រុក ក្រុមគ្រួសាររបស់ពួកគេ ក៏ដូចជាប្រទេសជាតិផងដែរ។ យ៉ាងណាមិញ ពលករដែលធ្វើចំណាកស្រុកទៅក្រៅប្រទេសដោយស្របច្បាប់គឺមិនសូវជាមានបញ្ហាច្រើនទេ ប៉ុន្តែផ្ទុយទៅវិញពលករដែលធ្វើចំណាកស្រុកទៅក្រៅប្រទេសដោយមិនស្របច្បាប់គឺពិតជាទទួលរងនូវបញ្ហាជាច្រើន ។

### ២.៨.១ ផលវិបាកនៃការធ្វើចំណាកស្រុកពីជនបទកាន់ទីក្រុង

ការធ្វើចំណាកស្រុកពីជនបទមកកាន់ទីក្រុងរបស់ប្រជាជនកម្ពុជា ដែលជាកន្លែងឃ្លាតឆ្ងាយពីស្រុកកំណើតនិងសាច់ញាតិបងប្អូនមិត្តភ័ក្តិហើយរស់នៅក្នុងបរិយាកាសថ្មីមួយ អាចប្រឈមមុខនឹង បញ្ហាផ្សេងៗដូចជា៖

- ប្រឈមមុខទៅនឹងការជួញដូរមនុស្ស
- ការកេងប្រវញ្ច័ផ្លូវភេទ
- គ្មានផ្ទះសំបែង
- ការកេងប្រវញ្ច័កំលាំងពលកម្ម
- កើតមានអំពើហឹង្សា
- ឆ្លងជំងឺផ្សេងៗ និងមិនអាចទៅរកសេវាសុខភាព

[18] លោក យឹម ឌីលុច្ស "កិច្ចការស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ច" ថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០១១

- ត្រូវបានបង្ខំឲ្យប្រើប្រាស់គ្រឿងញៀន
- មិនបានទទួលការគាំពារពីគ្រួសារ មិត្តភ័ក្តិ និងអ្នកជិតខាង
- រស់នៅតាមថ្នល់
- គ្មានអាហារ គ្មានប្រាក់ និងគ្មានការងារ
- កកស្ទះចរាចរណ៍
- កើតអំពើរលួច ឆក់ ប្លន់
- ប្រឈមមុខទៅនឹងការរើសអើង។

ការធ្វើចំណាកស្រុកបាននាំមកនូវការបាត់បង់ពិតប្រាកដនៃសង្វាក់ផលិតកម្មជនបទ ពីព្រោះថាពលរដ្ឋខ្មែរពឹងផ្អែកលើវិស័យកសិកម្ម ហើយប្រសិនបើមនុស្សដែលជាកម្លាំងនៃការផលិតនោះ រត់ទៅនៅទីក្រុងអស់នោះធ្វើឲ្យកម្លាំងផលិតចុះខ្សោយដូចគ្នា។ ម្យ៉ាងវិញទៀត ការធ្វើចំណាកស្រុកមកកាន់រាជធានីមានគុណសម្បត្តិ តិចតួចណាស់ហើយជាការខាតបង់មួយទៅវិញទេ។ ផ្ទុយទៅវិញគេត្រូវចេះប្រើប្រាស់កម្លាំងពិតប្រាកដឲ្យចំទិសដៅក្នុងការអភិវឌ្ឍ។ ជាមួយគ្នានេះ នៅពេលដែលមនុស្សហូរចូលទីក្រុងកាន់តែច្រើន គេក៏ត្រូវតែបន្ថែមការសាងសង់ដើម្បីបំពេញទៅតាមតម្រូវការទាំងនោះដែរក៏ប៉ុន្តែ សម្រាប់កម្ពុជា ការពង្រីកទីក្រុងហាក់ដូចជាមិនទាន់ឆ្លើយតបតាមស្ថានភាព ពលរដ្ឋជាក់ស្តែងនាពេលបច្ចុប្បន្ននៅឡើយទេ។ ការធ្វើចំណាកស្រុកនាំមកនូវការតាំងទីលំនៅមិនរៀបរយនៅក្នុងទីក្រុង។ នៅក្រុងភ្នំពេញជាក់ស្តែងគេអាចមើលឃើញថាសំណង់អនាធិបតេយ្យជាច្រើនកើតឡើង បណ្តាលមកពីការទិញលក់ថោកៗដោយអ្នកមកពីបណ្តាខេត្តផ្សេងគ្នាហើយអ្នកខ្លះបាន ប្រមូលផ្តុំគ្នារស់នៅតាមច្រកផ្លូវចេញចូល និងមុខផ្ទះអ្នកដទៃជាដើម។ កត្តាទាំងនេះជាបញ្ហា ដែលធ្វើឲ្យមានការបណ្តេញចេញពីទីក្រុងនៅពេលណាគេត្រូវការកែលម្អសោភ័ណ្ឌភាពនិងអភិវឌ្ឍន៍តំបន់ទាំងនោះ។ ការធ្វើចំណាកស្រុកកើតឡើងស្ទើរគ្រប់ក្រុមគ្រួសារដែលពួកគេបានផ្លាស់ទីទៅរស់នៅទីក្រុង។ ជាមួយគ្នានេះ អ្នកដែលរងការចាញ់បោកដោយសារការធ្វើចំណាកស្រុកកើតឡើងជាបន្តបន្ទាប់ ឧទាហរណ៍ជាក់ស្តែងក្មេងស្រីបានលះបង់ការសិក្សាទៅធ្វើការស៊ីឈ្នួលនៅភ្នំពេញអ្នកខ្លះធ្វើជាកម្មករកាត់ដេរនិងជាអ្នកបម្រើតាមភោជនីយដ្ឋានជាដើម។ អង្គការក្រៅរដ្ឋាភិបាលដែលធ្វើការពាក់ព័ន្ធ និងការធ្វើចំណាកស្រុកបានអោយដឹងពីមូលហេតុនៃការធ្វើចំណាកស្រុកពីជនបទមកកាន់ទីក្រុងដូចជា ការធ្វើចំណាកស្រុកប្រឈមមុខនឹងការប្រថុយប្រថាន

ច្រើនណាស់ការធ្វើចំណាកស្រុកងាយធ្វើឲ្យមានការកើនឡើងនៃការរាលដាលប្រភេទជំងឺឆ្លងផ្សេងៗ ហើយងាយប្រឈមមុខនឹងការជួញដូរ[19]។

### ២.៨.២ ផលវិបាកនៃការធ្វើចំណាកស្រុកនៅក្រៅប្រទេស

ការចាកចេញទៅធ្វើការងារនៅបរទេសពលករអាចប្រឈមនឹងបញ្ហា មួយចំនួនដូចជា មិនយល់ ឬមិនចេះ ភាសាបរទេសហើយត្រូវសំរបខ្លួនទៅនឹងវប្បធម៌ប្រពៃណីថ្មី។ ការធ្វើចំណាកស្រុកស្របច្បាប់ ពលករមិនសូវជាជួបការលំបាកប៉ុន្មានទេព្រោះមានក្រុមហ៊ុនជាអ្នកទទួលខុសត្រូវតាមច្បាប់ ប៉ុន្តែចំពោះ ការធ្វើចំណាកស្រុកខុសច្បាប់ពលករអាចប្រឈមមុខ នឹងបញ្ហាលំបាកច្រើនជាងការធ្វើចំណាកស្រុកស្របច្បាប់។ មានពលករខ្មែរជាច្រើនម៉ឺននាក់ត្រូវបានបញ្ជូនឲ្យទៅធ្វើការជាអ្នកបម្រើតាមផ្ទះ និងតាមហាងនានានៅក្នុងប្រទេសម៉ាឡេស៊ី ខណៈពេលប្រទេសនោះមានតម្រូវការខ្ពស់ខាងអ្នកអ្នកបម្រើតាមផ្ទះ។ តម្រូវការខ្ពស់ខាងអ្នកបម្រើតាមផ្ទះនេះគឺដោយសារប្រទេសឥណ្ឌូនេស៊ីដែលធ្លាប់តែបញ្ជូនពលកររបស់ខ្លួនទៅធ្វើការនៅប្រទេស ម៉ាឡេស៊ីនោះបានឈប់បញ្ជូនពលកររបស់ខ្លួនឲ្យទៅធ្វើការនៅទីនោះទៀត បន្ទាប់ពីមានរបាយការជាហូរហែអំពីស្ថានភាពការងារមិនល្អនៅទីនោះ។ ការបញ្ជូនពលករខ្មែរឲ្យទៅ ធ្វើការនៅក្នុងប្រទេសម៉ាឡេស៊ីគឺធ្វើឡើងតាមរយៈក្រុមហ៊ុនជ្រើសរើសពលករទាំងស្របច្បាប់ និងមិនស្របច្បាប់។ មានករណីជាច្រើនដែល មេខ្យល់ ឬឈ្មួញកណ្តាលនៅតាមភូមិស្រុកគឺជាអ្នកដើរជ្រើសរើស ពលករដោយផ្ទាល់ ដោយសន្យាផ្តល់ការងារដែលទទួលបានប្រាក់ខែខ្ពស់ដល់ពួកគេ និងផ្តល់លុយកាក់ ព្រមទាំងសម្ភារៈមួយចំនួនដល់ឪពុកម្តាយរបស់ពលករនោះជាមុន ហើយថែមទាំងសន្យាជួយរត់ការ លិខិត ស្នាមផ្លូវច្បាប់ផ្សេងៗដើម្បីជានាថាពលករទាំងនោះនឹងមានសុវត្ថិភាពនៅពេលធ្វើការនៅក្នុងប្រទេសម៉ាឡេស៊ីនោះ និងមួយករណីទៀតគឺពលករទៅធ្វើការនៅក្នុងប្រទេសថៃមួយចំនួនត្រូវបានគេបង្ខំឲ្យធ្វើការហួសកំណត់ជាមួយនឹងប្រាក់ខែស្ដួចស្តើងបំផុត។ ប៉ុន្តែនៅក្នុងពេល ថ្មីៗនេះមានរបាយការណ៍ជាបន្តបន្ទាប់អំពីការរំលោភបំពានផ្សេងៗទៅលើពលករខ្មែរនៅ ក្នុងប្រទេសម៉ាឡេស៊ី និងការលួចរត់ចេញរបស់ពលករពីមណ្ឌលបណ្តុះបណ្តាលរបស់ក្រុមហ៊ុនជ្រើសរើសពលករមួយចំនួនទៀតផង។ កន្លងមកពលករមួយចំនួនដែលបានចាញ់បោកមេខ្យល់ត្រូវបានគេកេងប្រវ័ញ្ចគ្រប់រូបភាព នៅក្នុងប្រទេសទទួលពលករ។[20]

[19] លោក យឹម ឌីលុច្ស "កិច្ចការស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ច" ថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០១១

[20] លោក យឹម ឌីលុច្ស "កិច្ចការស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ច" ថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០១១

# ជំពូកទី៣
# វិធានការ និងដំណោះស្រាយនៃការធ្វើចំណាកស្រុក

## ៣.១ ការគ្រប់គ្រងការងាររបស់ជនចំណាកស្រុក

បើទោះបីជាមានការប្រឈមនឹងកង្វះព័ត៌មានយ៉ាងណាក្តី ចំពោះការគ្រប់គ្រងការងាររបស់ជនចំណាកស្រុក រាជរដ្ឋាភិបាល ជាពិសេសក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានធ្វើការយ៉ាងសកម្ម ដោយបានធ្វើការអភិវឌ្ឍមុខរបរទាំងក្នុង និងក្រៅប្រទេស ធ្វើការអភិវឌ្ឍន៍ និងបទបញ្ញាផ្សេងៗ ព្រមទាំងបានធ្វើកិច្ចសហប្រតិបត្តិការទ្វេភាគី និង កិច្ចសហប្រតិបត្តិការអន្តរជាតិ។

### ៣.១.១ ការអភិវឌ្ឍមុខរបរនៅក្នុងប្រទេស

ការអភិវឌ្ឍនេះ បានចូលរួមចំណែកដូចជា៖

- បង្កើតការងារដើម្បីបង្កើនប្រាក់ចំណូលជូនប្រជាពលរដ្ឋ
- កាត់បន្ថយការធ្វើចំណាកស្រុក
- កាត់បន្ថយភាពក្រីក្រ
- បង្កើតផលិតផលក្នុងស្រុក
- គ្រប់គ្រងការប្រើប្រាស់ហត្ថពលកម្មនៅក្នុងប្រទេស រួមមានកម្មករនិយោជិតខ្មែរ និងបរទេសដែលមកធ្វើការនៅកម្ពុជា
- គ្រប់គ្រងអំពីព័ត៌មានតម្រូវការហត្ថពលកម្ម និងព័ត៌មានអំពីតម្រូវការទីផ្សារការងារ។

### ៣.១.២ ការអភិវឌ្ឍមុខរបរនៅខាងក្រៅប្រទេស

ការអភិវឌ្ឍនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានផ្តោតលើការគ្រប់គ្រងការបញ្ជូនពលករទៅធ្វើការនៅបរទេស។ នៅក្នុងការអនុវត្តការងារនេះ ក្រុមហ៊ុនដែលជាភ្នាក់ងារស្របច្បាប់របស់ក្រសួងមានចំនួន ៣២ក្រុមហ៊ុន។ [21] ជាមួយគ្នានេះដែរប្រទេសកម្ពុជាយើងបានបញ្ជូនពលករចេញ ទៅក្រៅប្រទេសជាច្រើននាក់ មិនតែប៉ុណ្ណោះក្រុមការងារអន្តរក្រសួង បានកំណត់អត្តសញ្ញាណ និងចេញលិខិតសំគាល់ខ្លួនជូនដល់ពលករកម្ពុជាយើងយ៉ាងត្រឹមត្រូវ និងស្របច្បាប់ផងដែរ ។

[21] ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ "ការគ្រប់គ្រង ការបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស" ឆ្នាំ ២០១៨

### ៣.១.៣ ការអភិវឌ្ឍន៍ និងបទបញ្ជាផ្សេងៗ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានធ្វើការយ៉ាងសកម្មដោយបានសហការជាមួយអង្គការ ILO-Japan IOM UNIFEM។ ហេតុនេះ អគ្គនាយកដ្ឋានការងារបានកសាងគោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសំរាប់កម្ពុជា កិច្ចសន្យាសេវារកការងារឲ្យធ្វើនៅបរទេស ឯកសារបង្រៀនស្តីពី ការណែនាំតម្រង់ទិសមុនពេលពលករចេញដំណើរ ឯកសារណែនាំស្តីពីរៀបចំ និងការកសាងមជ្ឈមណ្ឌល ណែនាំតម្រង់ទិស ឯកសារណែនាំឲ្យប្រើប្រាស់សៀវភៅបន្ទុកសម្រាប់ភ្នាក់ងារជ្រើសរើសនិងក្រុមការងារចុះត្រួតពិនិត្យ និងណែនាំផ្នាក់ងារក្រុមហ៊ុន និងការកសាងអនុក្រឹត្យថ្មីស្តីពីការបញ្ជូនពលករទៅបរទេស ។

## ៣.២ ការធ្វើកិច្ចសហប្រតិបត្តិការ

ការធ្វើកិច្ចសហប្រតិបត្តិការ ចែកចេញជាពីរប្រភេទគឺ កិច្ចសហប្រតិបត្តិការទ្វេរភាគី និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ការធ្វើកិច្ចសហប្រតិបត្តិការទាំងពីរនេះធ្វើឡើងក្នុងគោលបំណងគ្រប់គ្រង ការពារផលប្រយោជន៍ពលករ ធានាសុត្ថិភាព និងសម្របសម្រួល ដើម្បីឲ្យមានការប្រសើរឡើងនៃការធ្វើចំណាកស្រុកទៅក្រៅប្រទេស ។

### ៣.២.១ កិច្ចសហប្រតិបត្តិការទ្វេរភាគី

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជាយើង បានប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ និងថ្នាក់រដ្ឋមន្ត្រី ស្តីពីការអនុវត្តអនុស្សរណៈយោគយល់គ្នាលើកម្លាំងពលកម្មរវាងកម្ពុជា និងថៃក្នុងនោះកម្ពុជាសម្រេចបាន ការបន្តផ្តល់លិខិតសំគាល់ខ្លួនជូនប្រជាពលរដ្ឋដែល ធ្វើការនៅក្រៅប្រទេស និងបញ្ចប់ជាស្ថាពរ។ យើងក៏បានស្នើសុំភាគីថៃធ្វើវិសោធនកម្មប្រការ៩ នៃអានុស្សរណៈយោគយល់គ្នានេះផងដែរ។ ឯកភាពគ្នាចាត់ក្រុមការងារបច្ចេកទេសដើម្បីប្រជុំរៀបចំឯកសារប័ណ្ណឆ្លងដែន ធ្វើការព្រឹក-វិលល្ងាច និងតាមរដូវ និងនីតិវិធីនៃការអនុវត្ត និងការចាប់បញ្ជូនពលករខ្មែរ ដែលទៅធ្វើការដោយខុសច្បាប់នៅប្រទេសថៃដោយឈរលើគោលការណ៍គោរពសិទ្ធិមនុស្ស និងមនុស្សធម៌។ មិនតែប៉ុណ្ណោះក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានប្រជុំក្រុមការងារបច្ចេកទេស នៅខេត្តឈៀងម៉ៃ ប្រទេសថៃ ក្នុងនោះភាគីទាំងពីរបានឯកភាពរៀបចំសេចក្តីព្រាង និងស្នើសុំភាគីថៃលើកលែងទិដ្ឋាការសម្រាប់ចូលធ្វើការព្រឹកវិលល្ងាច តាមរដូវ ទិដ្ឋាការចេញចូលច្រើនដង និងការស្នើសុំផ្លាស់ប្តូរនិយោជក។[22]

[22] លោក សុខ ណាត "ការធ្វើចំណាកស្រុករបស់ប្រជាជនកម្ពុជា" ឆ្នាំ២០១៥

### ៣.២.២ កិច្ចសហប្រតិបត្តិការអន្តរជាតិ

អគ្គនាយកដ្ឋានការងារមានកិច្ចសហប្រតិបត្តិការជាច្រើនជាមួយនឹងអង្គការអន្តរជាតិ ដើម្បីសាងនូវឯកសារមួយចំនួនសំដៅគ្រប់គ្រងពលករទេសន្តរប្រវេសន៍កម្ពុជាឲ្យទទួលបាននូវសុវត្ថិភាព និងប្រាក់ចំណូល។ ជាក់ស្តែងអគ្គនាយកដ្ឋានការងារបានសហការជាមួយអង្គការពលកម្មអន្តរជាតិខាងការងារ ដើម្បីកសាងគម្រោងការងារសមរម្យនៅកម្ពុជា កសាងគោលនយោបាយទេសន្តរប្រវេសន៍ការងារ និងផ្សព្វផ្សាយការធ្វើដំណើរ និងធ្វើការងារដោយភាពឆ្លាតវៃ។ មិនតែប៉ុណ្ណោះយើងក៏ធ្វើការសហការជាមួយនឹងអង្គការអន្តរជាតិមួយចំនួនទៀតដូចជាអង្គកាIOM ដើម្បីអភិវឌ្ឍន៍ឯកសារតម្រង់ និង អង្គការ UNIFEM ជាដើម។[23]

## ៣.៣ វិធានការទប់ស្កាត់

ការបង្កើតវិធានការដើម្បីទប់ស្កាត់ និងកាត់បន្ថយបញ្ហាចំណាកស្រុក គឺមានភាពលំបាកខ្លាំងណាស់ក្នុងការដោះស្រាយ ក៏ដូចជារិះរកវិធីដោះស្រាយ ប៉ុន្តែទោះបីជាយ៉ាងណាក៏រាជរដ្ឋាភិបាលបានបង្កើតនូវគោលនយោបាយ និងវិធានការជាច្រើនដើម្បីទប់ស្កាត់បញ្ហាចំណាកស្រុកទាំងក្នុងស្រុក និងក្រៅប្រទេសផងដែរ ។

### ៣.៣.១ គោលនយោបាយរាជរដ្ឋាភិបាល

រដ្ឋាភិបាលកម្ពុជា កាត់បន្ថយការធ្វើចំណាកស្រុករបស់ពលរដ្ឋ ដោយបង្កើត ការងារនៅក្នុងស្រុកតាមរយៈការជំរុញកំណើនវិនិយោគលើវិស័យកសិកម្មដូចជា បង្កើតរោងចក្រកែច្នៃ ការបណ្តុះបណ្តាលឲ្យពលរដ្ឋមានចំណេះដឹងលើបច្ចេកទេសកសិកម្ម និងកែប្រែប្រព័ន្ធធារាសាស្ត្រឲ្យមានលក្ខណៈទំនើបជាដើម។ ការបង្កើនការងារដាំដុះឡើងវិញ នឹងជួយធ្វើឲ្យប្រទេសកម្ពុជាក្លាយជាប្រទេសបៃតង និងមានផលិតផលកសិកម្មចម្រុះ ដើម្បីបម្រើសេចក្តីត្រូវការនៅក្នុងស្រុក និងធ្វើការនាំចេញទៅលក់លើទីផ្សារអន្តរជាតិ។ លើសពីនេះ វិស័យនេះ មិនត្រឹមតែបង្កើតការងារដល់ពលរដ្ឋ និងកាត់បន្ថយចលនាចំណាកស្រុកនោះទេ ប៉ុន្តែថែមទាំងកាត់បន្ថយភាពក្រីក្រ នៅក្នុងប្រទេស និងបង្កើនការនាំចេញផលិតផលកសិកម្មនឹងជួយលើកកម្ពស់កំណើនសេដ្ឋកិច្ចជាតិបានមួយចំណែកធំផងដែរ។

### ៣.៣.២ គោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥

កាលពីពេលប៉ុន្មានឆ្នាំកន្លងទៅមុននៅថ្ងៃទី ២២ តុលា ឆ្នាំ ២០០៥ រដ្ឋាភិបាលបានអនុម័តគោលនយោបាយរយៈពេល ១០ ស្តីពីមុខរបរ និងការងារឆ្នាំ ២០១៥-២០២៥កំណត់ចេញសសរ

[23] ព្រភពពី https://soknath.blogspot.com ឆ្នាំ២០១៥

ស្តម្ភចំនួនបី ដែលផ្តោតទៅលើឱកាសការងារសមរម្យ និងមានផលិតភាពការងារខ្ពស់ ការជម្រុញអភិវឌ្ឍជំនាញ និងធនធានមនុស្ស និងការពង្រឹងអភិបាលកិច្ចការងារទីផ្សារការងារ។ គោលនយោបាយជាតិស្តីពីមុខរបរ និងការងារលើកដំបូងរបស់រដ្ឋាភិបាលនេះ និងជួយកាត់បន្ថយការចំណាកស្រុកតាមរយៈការជួយបង្កើនជំនាញបច្ចេកទេសដល់អ្នកនៅតាមជនបទ។ គោលនយោបាយជាតិរយៈពេល ១០ឆ្នាំនេះរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយមួយចំនួន ដើម្បីសម្រេចនូវសសរស្តម្ភទាំងបីរបស់ខ្លួន វិធានការទាំងនោះរួមមាន ការអភិវឌ្ឍវិស័យសហគ្រាស និងការផ្តល់ការគាំទ្រដល់សហគ្រាសខ្នាតតូច និងមធ្យមទាំងនៅក្នុងក្រុង និងនៅជនបទ។ លើសពីនេះបើតាមគោលនយោបាយរបស់រដ្ឋាភិបាលបានផ្តល់ការលើទឹកចិត្តដល់វិស័យធុរៈកិច្ច ដោយជម្រុញអោយសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលជាសកម្មភាពសេដ្ឋកិច្ចបែបគ្រួសារ និងមិនបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់អោយទៅជាសេដ្ឋកិច្ចក្នុងប្រព័ន្ធ។ ដើម្បីធានាថាកម្ពុជាមានកំលាំងពលកម្មជំនាញគ្រប់គ្រាន់ គោលនយោបាយនេះធានាថា ពង្រឹងគុណភាព និងបង្កើនចំនួនគ្រិះស្ថានអប់រំ និងគ្រិះស្ថានបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដោយលើកកំពស់ស្តង់ដាសមត្ថភាពតាមរយៈការធ្វើតេស្តបញ្ជាក់សមត្ថភាពដោយយកស្តង់ដាអាស៊ានជាគោល។

ទោះជារដ្ឋាភិបាលបានដាក់គោលនយោបាយយ៉ាងណាក៏ដោយក៏នៅមានប្រជាពលរដ្ឋច្រើនម៉ឺននាក់ធ្វើការចំណាកស្រុកទៅធ្វើការក្រៅប្រទេស ហើយចលនាចំណាកស្រុកពីជនបទមកទីក្រុងក៏កើនឡើងច្រើន។ ប្រជាជនចំណាកស្រុកទាំងនោះបានអះអាងថាការធ្វើការនៅក្រៅស្រុកបានទទួល កំរៃច្រើនជាងធ្វើការនៅក្នុងស្រុក បើទោះជាពួកគេប្រឈមនឹងការងារគ្រោះថ្នាក់ក៏ដោយ ។

គោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥ បានបង្ហាញថា សមិទ្ធផលសេដ្ឋកិច្ច សង្គមដែលសម្រេចបានក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះសម្រេចបាននូវកំណើនសេដ្ឋកិច្ច ប្រចាំឆ្នាំជា មធ្យម៧,៧% ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយ បានធ្វើឲ្យកម្ពុជាក្លាយជាប្រទេសមានកំណើនសេដ្ឋកិច្ច លឿនបំផុតលំដាប់ទី៦ នៅលើពិភពលោក។ ផលទុនជាតិឬទំហំសេដ្ឋកិច្ចដែលវាស់វែងដោយផលិតផលក្នុងស្រុក (ផ. ស. ស) ប្រមាណពី ២៤៨០លានដុល្លារអាម៉េរិក ឆ្នាំ ១៩៩៣ បានកើនឡើងដល់ ១៦ ៧០៩ លាន ដុល្លារអាមេរិក នៅឆ្នាំ២០១៤ (កើនឡើងប្រមាណជាង៦ដង)។ ប្រាក់ចំណូលឬផលិតផលក្នុងស្រុកសរុប (ផ.ស.ស) សម្រាប់ប្រជាជនម្នាក់ ចំនួន២២៩ ដុល្លារអាមេរិក ក្នុងម្នាក់ៗ ក្នុងមួយឆ្នាំ នៅឆ្នាំ១៩៩៣ បានកើន ឡើងដល់ប្រមាណជា១១២៣ដុល្លារអាមេរិក ក្នុងម្នាក់ៗក្នុងមួយឆ្នាំនៅឆ្នាំ២០១៤។ ចំណូលចរន្តនៃថវិកាជាតិដែលមានទំហំ១០៣លាន

ដុល្លារអាមេរិកក្នុងឆ្នាំ១៩៩៣ បានកើនឡើងទៅដល់ ប្រមាណ ២.៧៧៩លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០១៤ (កើនឡើងជិត២៩ដង)។

សម្តេចតេជោមានប្រសាសន៍ថា ក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងទៅនេះ យើងមិនត្រឹមតែរក្សាបានយ៉ាង រឹងមាំនូវស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានធ្វើឲ្យមានការរីក ចម្រើនគួរជាទីមោទនៈលើគ្រប់វិស័យទាំងវិស័យនយោបាយ សេដ្ឋកិច្ច និងសង្គមទៀតផង។ ក្នុងនោះការបែងចែកផលនៃកំណើនបានដល់ប្រជាជនគ្រប់រូប ជាពិសេសលទ្ធភាពនៃការទទួលបាននូវការងារធ្វើហេដ្ឋារចនាសម្ព័ន្ធគ្រប់ប្រភេទ និងចំណូលកាន់តែប្រសើរឡើង បានរួមចំណែកយ៉ាងច្រើនក្នុងការ កាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ ជាមួយនេះ តាមរយៈការខិតខំពុះពារនិងផ្តល់អាទិភាពវិនិយោគលើ ធនធានមនុស្ស ដែលជាមូលដ្ឋានគ្រឹះសម្រាប់ការចាប់ផ្តើមអភិវឌ្ឍសង្គម-សេដ្ឋកិច្ចយើងអាចបង្កើនឱកាសការងារសម្រាប់កម្លាំងពលកម្មដែលបានកើនឡើងប្រមាណជាង ២០ម៉ឺននាក់ក្នុងមួយឆ្នាំ។ ឈរលើមូលដ្ឋាននេះអត្រាគ្មានការងារធ្វើត្រូវបានកាត់បន្ថយមកត្រឹមក្រោម១%។ ក្នុងនោះ ស្ត្រី យុវជន ជនពិការ និងជនងាយរងគ្រោះ ត្រូវបានផ្តល់ឱកាសកាន់តែប្រសើរក្នុងការចូលរួមក្នុងទីផ្សារការងារ។ លើសពីនេះ ដើម្បីជំរុញលើក កម្ពស់លក្ខខណ្ឌការងារស្របតាមបទដ្ឋានការងារអន្តរជាតិយើងបានឈានមុខគេ ក្នុងតំបន់ក្នុងការផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិខាង ការងារចំនួន១៣ រួមទាំងអនុសញ្ញាស្នូលទាំង៨ ហើយក៏បានអនុវត្តន៍ គោលនយោបាយ ពាណិជ្ជកម្មផ្សារភ្ជាប់លក្ខខណ្ឌការងារតាមរយៈកម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជា។

ព្រមជាមួយនេះ ក្នុងស្មារតីធានាការពារជីវភាពរបស់កម្មករនិយោជិត ព្រមទាំងបង្កើត យន្តការចរចាប្រកបដោយតម្លាភាព និងឈរលើមូលដ្ឋានវិទ្យាសាស្ត្ររាជរដ្ឋាភិបាលបានដឹក នាំសម្របសម្រួលក្រោមយន្តការត្រីភាគី បង្កើតឡើងនូវគោលការណ៍ និងរូមន្តគណនា ប្រាក់ឈ្នួលអប្បបរមាឈរលើបទដ្ឋានអន្តរជាតិ និងទទួលយកដោយគ្រប់ភាគី។ លើមូលដ្ឋាននេះ ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែក វាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៦ ត្រូវបានដំឡើងពី ១២៨ដុល្លារ ទៅ ១៤០ ដុល្លារក្នុងមួយខែ។ បើគិតរួមទាំងអត្ថប្រយោជន៍ផ្សេងដែលមានស្រាប់ ជាមធ្យមកម្មករនិយោជិតម្នាក់ៗ ទទួលបានប្រាក់ចំណូលយ៉ាងតិចពី ១៥៧ដុល្លារ ដល់ ១៦៨ ដុល្លារអាមេរិកក្នុងមួយខែ។

ដើម្បីឲ្យការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារឲ្យកាន់តែសកម្ម និងមានប្រសិទ្ធភាព សម្តេចតេជោនាយករដ្ឋមន្ត្រីបានណែនាំឲ្យក្រសួងកាងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយក្រសួង ស្ថាប័ន ពាក់ព័ន្ធត្រូវធ្វើការតាមដាន និងវិភាគជាទៀងទាត់ រៀង

រាល់មួយឆ្នាំម្តងអំពីដំណើរការម៉ាក្រូសេដ្ឋកិច្ច ដោយផ្តោតសំខាន់លើការបង្កើតឱកាសការងារសមរម្យ និងមានផលិតភាពខ្ពស់ដល់ពលរដ្ឋកម្ពុជា។

ក្នុងនោះត្រូវរៀបចំឲ្យមានកិច្ចសន្ទនាគោលនយោបាយ វេទិកាអន្តរក្រសួងអំពីវឌ្ឍភាព នៃការបង្កើតឱកាសការងារសមរម្យ និងមានផលិតភាព។ ពិធីនេះប្រកាសផ្សព្វផ្សាយ និងដាក់ឲ្យអនុវត្តន៍គោលនយោបាយជាតិ ស្តីពីមុខរបរនិងការងារឆ្នាំ២០១៥ ត្រូវបានប្រារព្ធធ្វើឡើងកាលពីរសៀលថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ នៅវិមានសន្តិភាពក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងមានការចូលរួមរបស់លោក Maurizio Bussiនាយកការិយាល័យអង្គការ អន្តរជាតិខាងការងារប្រចាំប្រទេសកម្ពុជា ឡាវ និងថៃ អង្គទូតនៃបណ្តាប្រទេសជាមិត្តប្រចាំកម្ពុជា និងមន្ត្រី មកពីក្រសួង ស្ថាប័នពាក់ព័ន្ធជាច្រើនរូបទៀត។[24]

## ៣.៤ ដំណោះស្រាយ

### ៣.៤.១ ដំណោះស្រាយបញ្ហាចំណាកស្រុក

ដើម្បីដោះស្រាយបញ្ហាចំណាកស្រុក និងដើម្បីលើកកំពស់លទ្ធផលជាវិជ្ជមានទាមទាឲ្យមានការយល់ដឹងស្មុគស្មាញអំពីបញ្ហានេះ ការសម្របសម្រួលរវាងភាគីពាក់ព័ន្ធ និងស្ថាប័នដែលធ្វើការទាក់ទងនឹងបញ្ហាចំណាកស្រុក គឺធ្វើយ៉ាងណាឲ្យការអនុវត្តការងារឲ្យបានប្រសិទ្ធភាព។ ដើម្បីបញ្ចៀស ក៏ដូចជាទប់ស្កាត់ទាក់ទងនឹងកាធ្វើចំណាកស្រុកយើងត្រូវមានវិធានការមួយចំនួនដូចជាៈ

- កិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បីផ្សព្វផ្សាយព័ត៌មានស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព តាមរយៈការធ្វើយុទ្ធនាការអប់រំនៅតាមសហគបន៍ព្រោះវារួមចំណែកដល់ការបង្កើនការយល់ដឹងពីហានិភ័យនៃការធ្វើចំណាកស្រុកខុសច្បាប់ និងដើម្បីបង្កើនកិច្ចការពារ ។
- ជួយកាត់បន្ថយទៅលើការរៀបចំឯកសារសម្រាប់ជនចំណាកស្រុកក្រីក្រនិងមានឥទ្ធិពលវិជ្ជាមានទៅលើពួកគេ និងជួយលើកកំពស់ការធ្វើចំណាកស្រុកស្របច្បាប់ អាចជួយផ្តល់ឱកាសដល់ពួកគេក្នុងការទទួលបាននូវលក្ខខណ្ឌការងារល្អ និងប្រាក់ខែច្រើន ហើយសំខាន់បំផុតគឺទទួលបានការការពារផ្នែកច្បាប់និងសេវាកម្មសង្គម ។

---

[24] ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ "គោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥" ភ្នំពេញ ថ្ងៃទី ៤ ខែកញ្ញា ឆ្នាំ២០១៥

- ទាក់ទាញអ្នកវិនិយោគទាំងក្នុង និងក្រៅប្រទេសអោយធ្វើការវិនិយោគនៅក្នុងប្រទេសឲ្យបានច្រើនដើម្បីឲ្យប្រជាពលរដ្ឋមានការងារធ្វើគ្រប់គ្រាន់ និងប្រាក់ខែគ្រប់គ្រាន់ ដើម្បីបញ្ចៀសការធ្វើចំណាកស្រុកក្រៅប្រទេស ។

### ៣.៤.២ ចំណុចសំខាន់ៗគួរយល់ដឹងមុនពេលធ្វើចំណាកស្រុក

ដើម្បីជៀសវាងនូវការធ្វើចំណាកស្រុកដោយខុសច្បាប់យើងត្រូវយល់ដឹងអំពីចំណុចសំខាន់ៗទាំងនេះជាមុនសិនៈ

- ពិភាក្សា ផ្តល់ព័ត៌មានដល់គ្រួសារ មិត្តភ័ក្រ្ត
- ផ្តល់ដំណឹងដល់អាជ្ញាធរមុនពេលចាកចេញពីសហគមន៍
- រៀបចំផែនការ ទៅកន្លែងណា ដោយរបៀបណា និងដើម្បីអ្វី
- មានឯកសារពាក់ព័ន្ធ អត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារនិងលិខិតឆ្លងដែន
- ត្រូវយល់ដឹងអំពីការប្រកាសជ្រើសរើសបុគ្គលិក
- ត្រូវដឹងអំពីកន្លែងការងារ ឈ្មោះរោងចក្រ និងឈ្មោះក្រុមហ៊ុនដែលនឹងធ្វើការ
- ត្រូវមានជំនាញពាក់ព័ន្ធទៅនឹងតំរូវការជ្រើសរើសនោះ
- ត្រូវធ្វើដំណើរទៅជាក្រុម និងជាមួយនឹងក្រុមគ្រួសារ
- ត្រូវស្គាល់លេខទូរស័ព្ទទំនាក់ទំនងប៉ូលិស និងអ្នកជិតខាង
- ត្រូវមានប្រាក់ជាប់នឹងខ្លួន
- ត្រូវស្គាល់កន្លែងដែលត្រូវស្នាក់នៅ។

### ៣.៤.៣ សុវត្ថិភាពក្នុងការធ្វើចំណាកស្រុក

យើងអាចជៀសផុតពីការជួញដូរតាមចំនុចដូចខាងក្រោមៈ

- កុំឆាប់ជឿគេងាយពេក
- ត្រូវសុំជំនួយពេលជួបជាមួយនឹងអ្នកជួញដូរ
- ត្រូវប្រាប់ដល់ឪពុកម្តាយពេលជួប ឬ ឃើញករណីជួញដូរ
- មិនត្រូវព្យាយាមលាក់បាំងព័ត៌មានឡើយ
- ផ្តល់ព័ត៌មានដល់អ្នកផ្សេងៗទៀតមុនពេលអ្នកចាកចេញ
- សួរសំណួរដល់ជនបោកប្រាស់
- មិនត្រូវផ្តល់ព័ត៌មានផ្សេងៗដល់ជនបោកប្រាស់ឡើយ
- មើល និងស្តាប់ព័ត៌មាន
- ប្រាប់ដល់ប៉ូលិសពេលជួបនឹងជនបោកប្រាស់

- ត្រូវក្លាហានបដិសេធ នៅពេលដែលសង្ស័យថាគេជាជនបោកប្រាស់ ។

### ៣.៤.៤ ការងារដែលប្រជាជនអាចធ្វើបាននៅក្នុងសហគមន៍របស់ខ្លួន

មិនមែនមានតែការធ្វើចំណាកស្រុកទើបអាចគេចផុតពីភាពក្រីក្រ ឬភាពគ្មានការងារធ្វើនោះទេ ប៉ុន្តែយើងមានដំណោះស្រាយមួយចំនួនដូចជាៈ

- ជួយធ្វើការងារឪពុកម្តាយ និងក្រុមគ្រួសាររបស់ខ្លួន
- ដាំបន្លែលក់
- កាត់ដេរ និងវគ្គបណ្តុះបណ្តាលជំនាញផ្សេងៗ
- ផលិតរបស់របរធ្វើនៅផ្ទះ
- ចិញ្ចឹមមាន់ ទា ជ្រូក គោ ជាដើម
- ប្រកបរបរកសិកម្ម
- ធ្វើការជាចុងភៅនៅភោជនីយដ្ឋាន និងនៅតាមពិធីផ្សេងៗ
- បើកហាងលក់គ្រឿងទេស លក់ទឹកអំពៅនៅផ្ទះ និងតាមសាលារៀន ជាដើម។

### ៣.៥ ករណីសិក្សា

ការធ្វើចំណាកស្រុករបស់ពលករខ្មែរទៅធ្វើការនៅក្រៅប្រទេស ធ្វើឡើងទាំងស្របច្បាប់ និងខុសច្បាប់។ ការធ្វើចំណាកស្រុកដោយស្របច្បាប់ ធ្វើឡើងតាមរយៈការបញ្ជូនពលករចេញរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវ តាមរយៈក្រុមហ៊ុនបញ្ជូនពលករដែលមានច្បាប់ត្រឹមត្រូវ។

របាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចេញកាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ បង្ហាញថា រដ្ឋាភិបាលបានផ្តល់សេវាស្វែងរកការងារធ្វើនៅក្រៅប្រទេសសម្រាប់ពលរដ្ឋចំនួន១,២លាននាក់។ រដ្ឋាភិបាលកម្ពុជាបានតម្លើងប្រាក់ឈ្នួលអប្បបរមាជូនកម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើង ពី ១៥៣ ដុល្លា កាលពីឆ្នាំ ២០១៧ ដល់ចំនួន ១៨២ដុល្លា ក្នុងឆ្នាំ២០១៩។ បើទោះបីជារដ្ឋាភិបាលកម្ពុជាបានសម្រេចចិត្តតម្លើងប្រាក់ឈ្នួលគោលជារៀងរាល់ឆ្នាំក្តី ប៉ុន្តែគេសង្កេតឃើញថា ថ្លៃឈ្នួលផ្ទះ ក៏ដូចជាថ្លៃទំនិញផ្សេងៗនៅលើទីផ្សារ ក៏តែងតែឡើងថ្លៃទៅតាមនោះផងដែរ ។

ចំនួនប្រជាជនកាន់តែថយចុះនៅក្នុងស្រុកនេះ ដោយប្រជាជនវ័យក្មេងធ្វើចំណាកស្រុកទៅប្រទេសថៃដើម្បីរកការងារធ្វើ។ រដ្ឋាភិបាលក៏ប្រកាសពីកង្វះកម្លាំងពលកម្មក្នុងប្រទេសតែបែរជាមានពលករទាំងស្របនិងមិនស្របច្បាប់សម្រុកទៅរកការងារធ្វើនៅក្រៅប្រទេស។ ចំពោះមូលហេតុនេះគឺមាន២គឺៈ

កត្តាទី១៖ ជាក់ស្តែងមកពីបញ្ហាគោលនយោបាយប្រទេសថៃផ្តល់ប្រាក់ឈ្នួលក្នុងមួយថ្ងៃ ៣០០បាត ដែលនេះបានអូសទាញកម្លាំងពលកម្មពីប្រទេសកម្ពុជា ឡាវនិងភូមា។ ពីមុនមានតែ៧ ខេត្តក្រុងទេ ដោយបានថ្លៃឈ្នួល ចំនួនប្រហែល ៣០០បាត ក្នុងមួយថ្ងៃ តែក្នុងឆ្នាំ២០១៣ រដ្ឋាភិបាលថៃបានអនុញ្ញាតទូទាំងប្រទេស ។

កត្តាទី២៖ ដោយថ្លៃពលកម្មស្រុកគេខ្ពស់ ឯកសិកម្មក្នុងស្រុកជួបបញ្ហាថ្លៃដើមខ្ពស់តែតម្លៃលក់ថោក គ្មានទីផ្សារ ឯប្រជាពលរដ្ឋខ្វះការទទួលព័ត៌មាន ទាំងនេះជាបញ្ហា ។

តាមរយៈការលើកឡើងរបស់កញ្ញា សុខ ហេង ធ្វើការនៅរោងចក្រមួយកន្លែងក្នុងប្រទេសថៃបាននិយាយថា នៅក្នុងប្រទេសថៃ គេមិនឡើងតំលៃទំនិញ ដូចប្រទេសយើងទេ ដូចជាប្រទេសថៃនៅពេលដែលប្រាក់ខែឡើងថ្លៃ គឺទំនិញមិនឡើងថ្លៃទេ ដែលខុសពីស្រុកយើងនៅពេលដែលប្រាក់ខែឡើងថ្លៃ គឺទំនិញក៏ឡើងថ្លៃដែលធ្វើអោយការចំណាយខ្ពស់ទៅ តាមនោះដែរ ដូចជាថ្លៃផ្ទះ ទំនិញផ្សេងៗ។ កញ្ញាបានបន្តថា បើសិនជាលក្ខខណ្ឌការងារនៅក្នុងប្រទេសកម្ពុជាល្អជាង ឬប្រហាក់ប្រហែលនឹងស្រុកគេ កញ្ញានឹងត្រឡប់មកប្រទេសកំណើតរបស់ខ្លួនវិញ ព្រោះកញ្ញាមិនចង់រស់នៅឆ្ងាយពីក្រុមគ្រួសារនោះឡើយ។ កញ្ញាបានបន្ថែមថាគ្មាននរណាម្នាក់ចង់រស់នៅឆ្ងាយពីក្រុមគ្រួសារឡើយ តែដើម្បីជីវភាពក៏ត្រូវតែអត់ធ្មត់ ការដែលរស់នៅឆ្ងាយពីផ្ទះធ្វើឲ្យកញ្ញាមានអារម្មណ៍ថាខ្លួនឯងត្រូវតែរៀនរស់នៅម្នាក់ឯង កញ្ញាត្រូវអត់ធ្មត់ជាមួយការងារ ជាពិសេសអត់ធ្មត់ជាមួយនឹងអារម្មណ៍នឹករលឹកដល់ឪពុកម្តាយដែលនៅស្រុកកំណើត ។[25]

ដោយឡែកការលើកឡើងមួយផ្សេងទៀត របស់កញ្ញា ស្រីមុំ មានអាយុ ៣២ឆ្នាំ មានស្រុកកំណើតនៅភូមិស្រែចាមលើ ឃុំអូជ្រៅ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ បានប្រាប់ថា មូលហេតុដែលជំរុញឲ្យកញ្ញា ធ្វើការចំណាកស្រុកទៅធ្វើការនៅប្រទេសថៃដោយសារតែជីវភាពក្នុងគ្រួសារបន្ទាប់ពីម្តាយរបស់កញ្ញាបានលាចាកលោកទៅ ជីវភាពនៅក្នុងគ្រួសារកាន់តែធ្លាក់ចុះ។ កញ្ញាបានចេញទៅរស់នៅជាមួយនឹងគ្រួសារបងស្រីដែលរស់នៅព្រំដែនជិតប្រទេសថៃ បងស្រីរបស់កញ្ញា ក៏ធ្វើការចំណាកស្រុកទៅប្រទេសថៃដូចគ្នានោះ ទើបធ្វើឲ្យកញ្ញាសម្រេចចិត្តធ្វើការចំណាកស្រុកទៅធ្វើកានៅប្រទេសថៃ។ កញ្ញាបានបន្តលើកឡើងថាដោយសារតែគ្មានជម្រើស ទើបត្រូវចាកចេញពីគ្រួសារនិងស្រុកកំណើតអស់រយៈពេលជិត១០ឆ្នាំ ផលលំបាកដែលកញ្ញាជួបនៅឯប្រទេសថៃគឺមានច្រើន កញ្ញាត្រូវធ្វើការតស៊ូនឹងជីវិតដែលត្រូវរស់នៅឆ្ងាយពីគ្រួសារ ការងារមានការលំបាក ត្រូវធ្វើការច្រើនមុខពេលខ្លះត្រូវធ្វើការហាលខ្យល់ ភ្លៀង ព្យុះជាដើម។ ដោយឡែកមូលហេតុដែលកញ្ញា ស្រីមុំវិល

[25]Khmer.voanews.com ដកស្រង់ចេញពី "បទសម្ភាសន៍ វិទ្យុវីអូអេ ចំពោះ កញ្ញា សុខ ហេង" ថ្ងៃទី សីហា ២០១៨

ត្រឡប់មកស្រុកកំណើតវិញ ដោយសារតែឪពុកកញ្ញាមានវ័យជរា ទើបគាត់សម្រេចចិត្តត្រឡប់មកដើម្បីមើលថែឪពុករបស់គាត់វិញ ។ ម្យ៉ាងវិញទៀត បន្ទាប់ពីកញ្ញាបានធ្វើការនៅប្រទេសថៃអស់រយៈពេលជាច្រើនឆ្នាំ ទើបអាចសន្សំបានប្រាក់មួយចំនួនដើម្បីយកមកធ្វើជាដើមទុន ក្នុងការប្រកបមុខរបរនៅឯស្រុកកំណើតវិញ។ [26]

[26] កញ្ញា ស្រីមុំ ដកស្រង់ចេញពី "បទសម្ភាសន៍ផ្ទាល់ពីជនដែលធ្លាប់ធ្វើចំណាកស្រុក" ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩

# សេចក្ដីសន្និដ្ឋាន

យោងតាមរយៈការសិក្សាស្រាវជ្រាវរួចមកយើងអាចធ្វើការសន្និដ្ឋានបានថា ការធ្វើចំណាកស្រុករបស់ប្រជាជកម្ពុជាបានផ្តល់ទាំងផលប្រយោជន៍ និងផលវិបាកដល់ប្រទេសជាតិ ពលករខ្លួនឯងផ្ទាល់ ក៏ដូចជាក្រុមគ្រួសាររបស់ពលករផងដែរ មូលហេតុនៃការធ្វើចំណាកស្រុកនេះបង្ករឡើងដោយរូបភាពផ្សេងៗ ប៉ុន្តែទោះជាយ៉ាងណាក៏មានវិធានការ និងដំណោះស្រាយយ៉ាងសកម្ម និងយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាបាលរួមសហការជាមួយស្ថាប័ន អង្គការជាតិ និងអន្តរជាតិនានា។

ការធ្វើចំណាកស្រុក បង្ករឡើងមកពីកត្តាសំខាន់ៗពីរ គឺកត្តាជុំរុញ និងកត្តាទាក់ទាញ។ កត្តាជំរុញបណ្តាលមកពីភាពក្រីក្រ ភាពគ្មានដីធ្លី បំណុល គ្រោះធម្មជាតិ ការហិនហោចធនធានធម្មជាតិ ចំណែកឯកត្តាទាក់ទាញបណ្តាលមកពី ឧស្សាហកម្ម និងឱកាសការងារដែលមានច្រើន។ កត្តានៃមូលហេតុទាំងនេះបានធ្វើប្រជាជនសម្រេចចិត្តធ្វើចំណាកស្រុក ហើយការធ្វើចំណាកស្រុកមានការកើនឡើងគួរឲ្យកត់សម្គាល់។

ជាការពិតណាស់ការធ្វើចំណាកស្រុកពិតជាបានផ្តល់នូវផលប្រយោជន៍ដល់សេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចគ្រួសារពិតមែនបើទោះបីជាតិចតួចយ៉ាងណាក៏ដោយ ការធ្វើចំណាកស្រុករបស់ប្រជាជនខ្មែរទាំងក្នុងស្រុក និងទៅក្រៅប្រទេសភាគច្រើនគឺដើម្បីដោះស្រាយបញ្ហាសេដ្ឋកិច្ច ដូច្នេះការធ្វើចំណាកស្រុកបានធ្វើឲ្យសេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចគ្រួសារមានភាពប្រសើរឡើង និងកាត់បន្ថយភាពគ្មានការងារធ្វើ ក៏ដូចជាកាត់បន្ថយភាពក្រីក្របានមួយផ្នែកធំផងដែរ ។

យើងបានដឹងហើយថា ការធ្វើចំណាកស្រុកគឺជាបញ្ហាសកល ហើយបញ្ហានេះនៅតែជាបញ្ហាសម្រាប់ប្រទេសកម្ពុជាដែលមានតាំងពីយូរ និងបន្តរហូតមកដល់បច្ចុប្បន្ននេះ បញ្ហាចំណាកស្រុកនេះបានផ្តល់នូវផលវិបាកជាច្រើនដល់ប្រទេស ពលករដែលបានធ្វើចំណាកស្រុក និងគ្រួសាររបស់ពួកគេដូចជា ការជួញដូរមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការបែកបាក់គ្រួសារដែលធ្វើឲ្យកុមារទទួលរងនូវផលប៉ះពាល់ដល់ការសិក្សា ឬអាចក្លាយជាក្មេងកំព្រាដែលគ្មានអ្នកមើលថែ។ យ៉ាងណាមិញដើម្បីដោះស្រាយបញ្ហាចំណាកស្រុកទាំងនៅក្នុងស្រុក និងទៅក្រៅប្រទសប្រកបដោយប្រសិទ្ធិភាពដែលមានការធ្វើអន្តរាគមន៍ពីសំណាក់រាជរដ្ឋាភិបាល បណ្តាអង្គការនានា ទាំងអង្គការជាតិ និងអន្តរជាតិ ព្រមទាំងក្រសួង និងស្ថាប័នពាក់ពាន់ ជាពិសេសនោះគឺប្រជាពលរដ្ឋខ្លួនឯងផ្ទាល់តែម្តង។

# អនុសាសន៍

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវនូវប្រធានបទការធ្វើចំណាកស្រុកដូចដែលបានរៀបរាប់ខាងលើ ក្រុមស្រាវជ្រាវយើងខ្ញុំយល់ឃើញថា៖

➢ ប្រជាពលរដ្ឋគួរតែ៖

- យល់ដឹងពីព័ត៌មានឲបានច្បាស់មុននឹងធ្វើចំណាកស្រុក ហើយធ្វើចំណាកស្រុកដោយស្របច្បាប់
- ជៀសវាងការធ្វើចំណាកស្រុកដោយស្វែងរកចំណេះដឹង វិជ្ជាជីវៈឬការងារផ្សេងៗនៅក្នុងប្រទេស

➢ រាជរដ្ឋាភិបាលគួរតែ៖

- កាត់បន្ថយការជ្រើសរើសពលករ និងការបញ្ជូនពលករទៅក្រៅប្រទេស
- កាត់បន្ថយការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋដោយបង្កើតការងារនៅក្នុងស្រុក ព្រមទាំងបង្កើនតម្លៃការងារ ក៏ដូចជាតំឡើងប្រាក់ឈ្នួល
- លើកកម្ពស់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងការវិនិយោគទុន ដើម្បីបង្កើតឱកាសការងារ ឲ្យកាន់តែច្រើនតែច្រើនក្នុងខេត្តដែលមានប្រជាជនច្រើន មានចំណាកស្រុកខ្ពស់
- ជួយសម្របសម្រួលផ្តល់ដំណឹង តម្លាភាព និងការធ្វើចំណាកស្រុកសមរម្យ និងសុវត្ថិភាព
- ត្រួតពិនិត្យសកម្មភាពការងារនានារបស់ទីភ្នាក់ងារជ្រើសរើសពលករឯកជន រួមទាំងការរកការងារឲ្យពលករធ្វើតម្លៃពលកម្ម ការហ្វឹកហ្វឺនពលករមុនពេលចាកចេញទៅធ្វើការក្រៅប្រទេស និងព័ត៌មានដែលផ្តល់ឲ្យដោយកម្មករនិយោជិតចំពោះប្រាក់ខែ និងលក្ខខណ្ឌការងារ និងការលុបបំបាត់នូវអាជ្ញាប័ណ្ណក្នុងករណីមានការប្រព្រឹត្តខុស ។

# ឯកសារយោង

## លិខិតគតិយុត្ត

- អនុក្រឹត្យស្តីពី ការបង្កើតក្រុមប្រឹក្សាភិបាលបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស
- អនុក្រឹត្យលេខ៥៧ ស្តីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស
- គោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥
- គោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥
- ស្តីពីការផ្តល់លិខិតឆ្លងដែនធម្មតា ជូនពលករ ពលការនី និស្សិតខ្មែរ
- គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧ - ២០១៨

## របាយការណ៍

- របាយការណ៍ស្រាវជ្រាវពីសមាគមធាងត្នោតៈ ផលប៉ះពាល់ដល់សេដ្ឋកិច្ចសង្គម នៃការធ្វើចំណាកស្រុកពីជនបទមកកាន់ទីក្រុង
- របាយការណ៍ផលប៉ះពាល់ដល់កុមារ : អង្គការ Unicef

## សៀវភៅ

- ឯកសារស្រាវជ្រាវនៃ វិទ្យាស្ថានសភាកម្ពុជាៈ ការធ្វើចំណាកស្រុក ការទប់ស្កាត់ ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ
- ឯកសារស្រាវជ្រាវនៃ វិទ្យាស្ថានសភាកម្ពុជាៈ សីលធម៌ និងលក្ខន្តិកៈចាំបាច់ផ្នែកសេដ្ឋកិច្ចដើម្បីធានាឲ្យការធ្វើចំណាកស្រុកមានលក្ខណៈយុត្តិធម៌ វៃឆ្លាត និងមនុស្សធម៌ជាងមុន
- ឯកសារស្រាវជ្រាវផ្សេងៗរបស់ CDRI
- ឯកសារស្រាវជ្រាវនៃអង្គការ Unicef : ចំណាកស្រុកដើម្បីការងាររបស់យុវជនប្រទេសខ្មែរ

## ទិន្នន័យ

- ទិន្នន័យពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## ទស្សនាវដ្តី

- ទស្សនាវដ្តីប្រជាជន Pracheachun Magazine
- ទស្សនាវដ្តីកម្ពុជា

## បទសម្ភាសន៍

- កិច្ចសម្ភាសន៍ជាមួយជនដែលធ្លាប់ធ្វើចំណាកស្រុក

# គេហទំព័រ


- គេហទំព័រ thmeythmey.com
- គេហទំព័រ Klahan9.com.kh
- គេហទំព័រ Postkhmer.com
- គេហទំព័រ www.interconrooster.com
- ប្រភពពត៌មាន khmer.voanews.com
- Migration and Human Trafficking : HEINRICH BOTL STIFTUNG

# ឧបសម្ព័ន្ធ

## បញ្ជីរាយឈ្មោះឯកសារក្នុងឧបសម្ព័ន្ធ

១. អនុក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាភិបាលបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស ។

២. អនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែមខែមិថុនា ឆ្នាំ២០០៩ ។

៣. អនុក្រឹត្យលេខ៥៧ ស្តីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស ១៩៩៥ ។

៤. អនុក្រឹត្យស្តីពីការផ្តល់លិខិតឆ្លងដែនធម្មតា ជូនពលករ ពលការនី និស្សិតខ្មែរ ។

# អនុក្រឹត្យស្តីពី
# ការបង្កើតក្រុមប្រឹក្សាភិបាលបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧០ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតក្រុមប្រឹក្សាភិបាលបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា ១.-**

បង្កើតក្រុមប្រឹក្សាភិបាលបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស (Manpower. Training and Oversea Sending Board; MTOSB) ដែលជាស្ថាប័នសាធារណៈ (រដ្ឋ) សម្រាប់ជ្រើសរើស បណ្តុះបណ្តាល

បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅបរទេស។ ក្រុមប្រឹក្សាភិបាលនេះ មានទីតាំងស្ថិតនៅក្នុងវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា (National Polytechnic Institute of Cambodia; NPIC) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា ២.-**

ក្រុមប្រឹក្សាភិបាលនេះមានភារកិច្ចដូចខាងក្រោម :

- ទំនាក់ទំនងជាមួយប្រទេសដែលទទួលពលករដើម្បីក្តាប់ព័ត៌មាន និងតម្រូវការទីផ្សារការងារ ហើយដោះស្រាយឱ្យបានទាន់ពេលវេលា
- សម្របសម្រួលឱ្យបានជិតស្និទ្ធជាមួយស្ថាប័នពាក់ព័ន្ធក្នុងប្រទេស ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការជ្រើសរើស បណ្តុះបណ្តាល បញ្ជូននិងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅបរទេស
- កសាងបទដ្ឋាន លក្ខណៈវិនិច្ឆ័យ និងនីតិវិធីឱ្យបានគ្រប់ជ្រុងជ្រោយក្នុងការជ្រើសរើស និងអប់រំបណ្តុះបណ្តាល ដើម្បីបំពេញសំណូមពរ និងលក្ខខណ្ឌរបស់ប្រទេសជាដៃគូប្រកបដោយតម្លាភាព
- រៀបចំ និងចាត់ចែងបែបបទបញ្ជូន និងគ្រប់គ្រងពលករដែលទៅធ្វើការនៅក្រៅប្រទេសរហូតដល់ក្រឡប់មកមាតុប្រទេសវិញ។

**មាត្រា ៣.-**

ក្រុមប្រឹក្សាភិបាលនេះមានសមាសភាពដូចតទៅ :

| | |
|---|---|
| - រដ្ឋលេខាធិការទទួលបន្ទុកការងារ មុខរបរ និងហត្ថពលកម្ម និងជាប្រធានក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា | ប្រធាន |
| - អនុរដ្ឋលេខាធិការទទួលបន្ទុកការងារ មុខរបរ និងហត្ថពលកម្ម | អនុប្រធាន |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | សមាជិក |

សមាសភាពនៃក្រុមប្រឹក្សានេះ ត្រូវតែងតាំងដោយអនុក្រឹត្យ។

**មាត្រា ៤.-**

- ក្រុមប្រឹក្សាភិបាលនេះមានអង្គភាពបីស្ថិតនៅក្រោមចំណុះ :
  - អង្គភាពរដ្ឋបាល និងហិរញ្ញវត្ថុ
  - អង្គភាពជ្រើសរើស និងបណ្តុះបណ្តាល
  - អង្គភាពបញ្ជូន និងគ្រប់គ្រងពលករ
- ក្រុមប្រឹក្សាភិបាលនេះអាចបង្កើតអង្គភាពផ្សេងៗទៀតក្រោមចំណុះបានតាមការចាំបាច់

- អង្គភាពនីមួយៗដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់
- រចនាសម្ព័ន្ធ ការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពចំណុះក្រុមប្រឹក្សាភិបាលបណ្ដុះបណ្ដាល និងបញ្ជូនពលករទៅបរទេស ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល :*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *ឯកសារ-កាលប្បវត្តិ*

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ [illegible] ឆ្នាំ ២០០៦

អង្គការលេខរបស់ក្រុមប្រឹក្សាភិបាលបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស



# អនុសញ្ញាស្ដីពី
# សិទ្ធិកុមារ និងពិធីសារបន្ថែម
# ខែមិថុនា ឆ្នាំ២០០៩

# អនុសញ្ញា

## ស្តីពី

# សិទ្ធិកុមារ និងពិធីសារបន្ថែម

ខែមិថុនា ឆ្នាំ២០០៩

រូបភាពក្រុបដោយ ថៅ វ៉ាសូកា - យូនីសេហ្វនៅកម្ពុជា

នេះគឺជាការបោះពុម្ពផ្សាយរួមគ្នា ដោយមូលនិធិសហប្រជាជាតិដើម្បីកុមារ
(យូនីសេហ្វ) និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួល
បន្ទុកសិទ្ធិមនុស្ស

# មាតិកា

១- សេចក្តីផ្តើមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារ
បន្ថែម....................................ទំព័រ៧

២- អនុសញ្ញាស្តីពីសិទ្ធិកុមារ.................ទំព័រ១៤

៣- ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ
ពាក់ព័ន្ធនឹងការចូលរួមរបស់កុមារក្នុងជម្លោះ
ប្រដាប់អាវុធ ..............................ទំព័រ៥៣

៤- ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ពាក់ព័ន្ធ
នឹងការលក់កុមារ ការធ្វើពេស្យាកម្មកុមារ និងរូប
ភាពឬសម្ភារៈអាសអាភាសកុមារ..........ទំព័រ

# អនុសញ្ញាស្តីពីសិទ្ធិកុមារ
# និងពិធីសារបន្ថែម

## សេចក្តីផ្តើម

អនុសញ្ញាស្តីពីសិទ្ធិកុមារគឺជាសន្ធិសញ្ញាអន្តរជាតិដែលមានចែងពីបទដ្ឋាន អប្បបរមាជាសកល និងពីគោលការណ៍សីលធម៌សំរាប់ការប្រព្រឹត្តលើកុមារ នៅក្នុងសង្គម។ អនុសញ្ញានេះ គឺជាសេចក្តីថ្លែងលំអិតមួយពីសិទ្ធិទាំងឡាយ ដែលកុមារគ្រប់ទិសទីត្រូវទទួលបាន ហើយរួមបញ្ចូលសិទ្ធិពលរដ្ឋ នយោបាយ សង្គម សេដ្ឋកិច្ច និងវប្បធម៌ដែលពាក់ព័ន្ធនឹងកុមារ ។

នៅក្នុងអតីតកាល កុមារត្រូវបានគេចាត់ទុកគ្រាន់តែជាអ្នករងអំពើ ឬកម្ម វត្ថុដែលគេប្រព្រឹត្តទៅលើប៉ុណ្ណោះ។ ប៉ុន្តែឥឡូវនេះ អនុសញ្ញាស្តីពីសិទ្ធិកុមារ ទទួលស្គាល់កុមារថាជាមនុស្សដែលមានសិទ្ធិរបស់គេផ្ទាល់ គឺជាសិទ្ធិដែលគេ ទទួលបានអាស្រ័យដោយគេកើតជាមនុស្ស។ កុមារអាចទាមទារសិទ្ធិរបស់ខ្លួន ពីអ្នកមានភារកិច្ចនានា ដូចជាឪពុក-ម្តាយ និងរដ្ឋ ជាពិសេសមន្ត្រីនគរបាល និង តុលាការដែលមានភារកិច្ចគោរព ការពារ និងបំពេញតាមសិទ្ធិរបស់កុមារ ។

ដូចសិទ្ធិមនុស្សទាំងអស់ដែរ សិទ្ធិកុមារដែលមានចែងក្នុងអនុសញ្ញាស្តីពី សិទ្ធិកុមារមិនអាចបំបែកចេញពីគ្នាបានទេ។ នេះមានន័យថាសិទ្ធិទាំងអស់មាន ទំនាក់ទំនងគ្នា ហើយពុំមានសិទ្ធិណាមួយសំខាន់ជាងសិទ្ធិណាមួយឡើយ។ ទោះ យ៉ាងណាក៏ដោយ អនុសញ្ញាស្តីពីសិទ្ធិកុមារ យកចិត្តទុកដាក់ចំពោះភាពខុសគ្នា

នៃវប្បធម៌ នយោបាយនិងស្ថានភាពពិតខាងផ្នែកសំភារៈក្នុងចំណោមរដ្ឋនានា។ អ្វីដែលត្រូវយកមកពិចារណាជាចំបងបំផុតនោះគឺឧត្តមប្រយោជន៍របស់កុមារ។

អនុសញ្ញាស្តីពីសិទ្ធិកុមារត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិកាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩ គឺជាថ្ងៃដែលប្រារព្ធដោយសហប្រជាជាតិធ្វើជាទិវាកុមារសកល។*

ព្រះរាជាណាចក្រកម្ពុជា បានចូលជារដ្ឋភាគីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារនៅឆ្នាំ១៩៩២ ។ តាមរយៈការចូលជាភាគីនេះ ព្រះរាជាណាចក្រកម្ពុជា ប្តេជ្ញាខ្លួន ការពារ និងបំពេញតាមសិទ្ធិនានារបស់កុមារទាំងអស់នៅកម្ពុជា ។

## ហេតុអ្វីបានជាកុមារត្រូវការសិទ្ធិពិសេស ?

កុមារមានសិទ្ធិឱ្យគេប្រព្រឹត្តទៅលើ ដូចមនុស្សពេញវ័យដទៃទៀតដែរ ដើម្បីរស់នៅក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ សមភាព និងសុវត្ថិភាព។ ក្នុងពេលជាមួយគ្នានេះដែរ កុមារក៏មានសិទ្ធិពិសេសបន្ថែម ដោយសារតែពួកគេមានវ័យក្មេង និងងាយរងគ្រោះ។ កុមារនឹងមិនអាចរស់រាន និងឈានដល់សក្តានុពលពេញលេញ បើគ្មានជំនួយ និងការសហការពីមនុស្សពេញវ័យ ។ គោលបំណងរបស់អនុសញ្ញាស្តីពីសិទ្ធិកុមារ គឺបង្កើតជាបទដ្ឋានសំរាប់ការពារកុមារប្រឆាំងនឹងការទុកចោលមិនយកចិត្តទុកដាក់ ការរំលោភបំពាន ការកេងប្រវ័ញ្ច និងការរើសអើងដែលខ្លួនជួបប្រទះ ក្នុងកិរិតផ្សេងៗ ជារៀងរាល់ថ្ងៃនៅគ្រប់ប្រទេស ។

* មហាសន្និបាតអង្គការសហប្រជាជាតិបានចាត់ទុកថ្ងៃ២០ វិច្ឆិកា ថាជាទិវាកុមារសកល នៅឆ្នាំ១៩៥៤។ សេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ក៏ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃ២០ វិច្ឆិកាដែរ តែក្នុងឆ្នាំ១៩៥៩។ នៅកម្ពុជា ទិវាកុមារអន្តរជាតិ គឺប្រារព្ធធ្វើនៅរៀងរាល់ថ្ងៃ១ មិថុនា។

**កុមារជានរណា ?**

កុមារត្រូវគេទទួលស្គាល់ជាមនុស្សមានអាយុក្រោម ១៨ឆ្នាំ លើកលែងតែច្បាប់របស់ប្រទេស ចែងពីអាយុពេញវ័យដែលគេសន្មត់រហ័សជាង ។

**តើគោលការណ៍អ្វីខ្លះដែលនាំសំរាប់ការអនុវត្តន៍អនុសញ្ញា ?**

អនុសញ្ញាស្តីពីសិទ្ធិកុមារមានចែងគោលការណ៍ណែនាំ៤ ហើយតាមរយៈនេះ សិទ្ធិកុមារត្រូវទទួលបានការការពារ ។ គោលការណ៍ទាំងនេះ រួមមាន:

**១-ឧត្តមប្រយោជន៍កុមារ (មាត្រា៣)**

គ្រប់សកម្មភាពពាក់ព័ន្ធនឹងកុមារ ត្រូវយកឧត្តមប្រយោជន៍របស់កុមារមកពិចារណាជាចំបង ។

**២-ការមិនរើសអើង (មាត្រា២)**

កុមារគ្រប់រូបត្រូវទទួលបានសិទ្ធិទាំងអស់របស់ខ្លួន ដោយមិនមានការរើសអើងនៃប្រភេទណាមួយទេ។ កុមារមិនអាចត្រូវបានគេបដិសេធសិទ្ធិរបស់ខ្លួនដោយសារតែជាតិសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ទស្សនៈនយោបាយ ឬទស្សនៈផ្សេងៗ ជាតិ ប្រភពជនជាតិ ឬឋានៈក្នុងសង្គម ទ្រព្យសម្បត្តិ ពិការភាព កំណើត ឋានៈ ឬស្ថានភាពផ្សេងៗទៀតរបស់កុមារ ឬឪពុក-ម្តាយរបស់កុមារនោះទេ ។

**៣-សិទ្ធិមានជីវិត សិទ្ធិរស់រានមានជីវិត និងសិទ្ធិអភិវឌ្ឍន៍ (មាត្រា ៦)**

កុមារគ្រប់រូប មានសិទ្ធិមានជីវិតតាំងពីកំណើត។ រដ្ឋត្រូវធានាពីការរស់រានមានជីវិត និងការអភិវឌ្ឍន៍របស់កុមារ ឱ្យមានកំរិតអតិបរមាតាមដែលអាចធ្វើបាន។

**៤-ការគោរពទស្សនៈកុមារ (មាត្រា១២)**

កុមារដែលមានសមត្ថភាពបង្កើតទស្សនៈផ្ទាល់ខ្លួន មានសិទ្ធិបញ្ចេញមតិរបស់គេ ដោយសេរី ក្នុងគ្រប់បញ្ហាពាក់ព័ន្ធនឹងខ្លួនគេ។ ទស្សនៈកុមារត្រូវតែបានគេយកទៅពិចារណាថ្លឹងថ្លែង ឱ្យបានសមស្របទៅតាមអាយុ និងការយល់ដឹង (ភាពចាស់ចិត្តចាស់គំនិត) របស់កុមារ ។

## តើសិទ្ធិជាគំលាត់អ្វីខ្លះដែលមានចែងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ?

អនុសញ្ញាមានចែងជាបួនប្រភេទធំៗនៃសិទ្ធិកុមារៈ

**១-សិទ្ធិរស់រានមានជីវិតៈ** សិទ្ធិនេះរួមបញ្ចូល សិទ្ធិមានជីវិត និងសិទ្ធិទទួលបានការថែទាំសុខភាព និងវេជ្ជសាស្ត្រក្នុងកំរិតខ្ពស់បំផុត ។

**២-សិទ្ធិអភិវឌ្ឍន៍ៈ** សិទ្ធិទាំងនេះរួមបញ្ចូលអ្វីទាំងអស់ដែលកុមារត្រូវការដើម្បីលូតលាស់ក្នុងកំរិតខ្ពស់បំផុត និងដើម្បីឱ្យក្លាយទៅជាសមាជិកដែលទទួលខុសត្រូវរបស់សង្គម ។ សិទ្ធិនេះ រួមមានការអប់រំគ្រប់ប្រភេទ និងសិទ្ធិទទួលបានជីវភាពរស់នៅគ្រប់គ្រាន់ សំរាប់ការលូតលាស់របស់កុមារ ផ្នែករាងកាយ សតិអារម្មណ៍ ស្មារតី សីលធម៌ និងសង្គម ។

**៣-សិទ្ធិទទួលបាននូវការការពារៈ** សិទ្ធិនេះចង់សំដៅយ៉ាងទូលាយដល់សិទ្ធិដែលត្រូវបានទទួលការការពារ រួចផុតពីអំពើ និងការប្រព្រឹត្តផ្សេងៗដែលបង្កអន្តរាយដល់កុមារ ។ សិទ្ធិនេះ រួមមានការការពារពីការរើសអើង ពីការរំលោភបំពាន ការទុកចោលមិនយកចិត្តទុកដាក់ និងការកេងប្រវ័ញ្ច ការការពារកុមារដែលគ្មានគ្រួសារ និងការការពារកុមារជាជនភៀសខ្លួន ។

**៤-សិទ្ធិចូលរួមៈ** សិទ្ធិទាំងនេះ គ្របដណ្តប់លើសិទ្ធិរបស់កុមារក្នុងការចូលរួមបញ្ចេញមតិរបស់ខ្លួនក្នុងគ្រប់បញ្ហា និងត្រូវបានគេទទួលស្តាប់ក្នុងគ្រប់សេចក្តីសំរេចដែលប៉ះពាល់ដល់អាយុជីវិតរបស់កុមារ ។ នៅពេលសមត្ថភាពរបស់កុមារវិវត្តឡើង កុមារគួរតែមានឱកាសកាន់តែច្រើនជាងមុន ក្នុងការចូលរួមសកម្មភាពរបស់សង្គម ដើម្បីជាការរៀបចំសំរាប់ជីវិតជាមនុស្សពេញវ័យ។

**តើអនុសញ្ញាស្តីពីសិទ្ធិកុមារដាក់ភារកិច្ចអ្វីខ្លះដល់រដ្ឋាភិបាល ?**

រដ្ឋភាគីនីមួយៗនៃអនុសញ្ញាសិទ្ធិកុមារត្រូវបំពេញកាតព្វកិច្ចដូចខាងក្រោមៈ

- អនុម័តច្បាប់ គោលនយោបាយ និងកម្មវិធីផ្សេងៗ ដើម្បីធានាការអនុវត្តន៍ និងការទទួលបានសិទ្ធិដែលមានចែងក្នុងអនុសញ្ញាសិទ្ធិកុមារ (មាត្រា៤)
- ចាត់វិធានការច្បាប់ រដ្ឋបាល និងវិធានការដទៃទៀតឱ្យបានសមស្របទៅនឹងកំរិតអតិបរមា នៃធនធានដែលមាន របស់ប្រទេសខ្លួន និងតាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិ ។ នេះមានន័យថាកំណត់អាទិភាព និងទុកកុមារជាចំបង (មាត្រា៤)
- លើកកំពស់ការយល់ដឹង ពីអនុសញ្ញាស្តីពីសិទ្ធិកុមារ (មាត្រា៤២)
- បញ្ជូនរបាយការណ៍ស្តីពីស្ថានភាពបច្ចុប្បន្នរបស់កុមារ និងភាពរីកចំរើននៃការអនុវត្តន៍ អនុសញ្ញាស្តីពីសិទ្ធិកុមារ ទៅឱ្យគណៈកម្មាធិការសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិពីរឆ្នាំក្រោយពីការផ្តល់សច្ចាប័នលើអនុសញ្ញានេះ និងរៀងរាល់ ៥ឆ្នាំម្តង បន្តបន្ទាប់មកទៀត (មាត្រា៤៤)

**តើពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារមានអ្វីខ្លះ ?**

ពិធីសារបន្ថែម គឺជាឯកសារបន្ថែមលើសន្ធិសញ្ញាគោលដែលរដ្ឋនីមួយៗ

អាចជ្រើសរើសដើម្បីចូលជាសមាជិកប្រសិនបើរដ្ឋនោះយល់ព្រមទទួលកាតព្វកិច្ចបន្ថែមតាមពិធីសារនោះដោយមិនគិតដល់អនុសញ្ញាដើមឡើយ។

អនុសញ្ញាស្តីពីសិទ្ធិកុមារ មានពិធីសារបន្ថែមចំនួនពីរដែលត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិកាលពីខែឧសភា ឆ្នាំ២០០០ដូចគ្នា។ ពិធីសារមួយគឺសំដៅប្រឆាំងនឹងការជួញដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ ឯពិធីសារបន្ថែមមួយទៀត គឺសំដៅដល់ការការពារកុមារពីការពាក់ព័ន្ធនៅក្នុងជំលោះប្រដាប់អាវុធ ដោយធ្វើការដាក់កំហិត និងបញ្ញាត្តិពីការប្រើប្រាស់ទាហានក្រោមអាយុ១៨ឆ្នាំ។

## តើអនុសញ្ញានេះអនុវត្តយ៉ាងដូចម្តេចនៅកម្ពុជា?

កម្ពុជាបានក្លាយជារដ្ឋភាគីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារនៅថ្ងៃទី១៥ វិច្ឆិកា ១៩៩២ ជារដ្ឋភាគីនៃពិធីសារបន្ថែមប្រឆាំងនឹងការជួញដូរកុមារ នៅថ្ងៃទី៣០ មិថុនា ឆ្នាំ២០០២ និងជារដ្ឋភាគីនៃពិធីសារបន្ថែមស្តីពីការពាក់ព័ន្ធកុមារនៅក្នុងជំលោះប្រដាប់អាវុធនៅថ្ងៃទី១៦ សីហា ២០០៦ ។

មាត្រា៣១នៃរដ្ឋធម្មនុញ្ញធានាការពារអនុសញ្ញានេះ ជាមួយនឹងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដទៃទៀតថាជាផ្នែកមួយនៃច្បាប់កម្ពុជា។ មាត្រា៤៨ គូសបញ្ជាក់បន្ថែមទៀតថា "រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណលើកុមារ។"

នៅក្នុងសេចក្តីសំរេចរបស់ខ្លួនកាលពីថ្ងៃទី១០-កក្កដា-២០០៧ ក្រុមប្រឹក្សាធម្មនុញ្ញ ដែលជាស្ថាប័នមួយបង្កើតឡើង ដើម្បីការពាររដ្ឋធម្មនុញ្ញ បានគូស

បញ្ជាក់ជាថ្មី ពីការអនុវត្តន៍សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ នៅក្នុងច្បាប់កម្ពុជា និងធ្វើការរំលឹកដល់ចៅក្រម ក្នុងការសំរេចក្តី និងធ្វើការបកស្រាយច្បាប់ ថាចៅក្រមត្រូវប្រកាន់ឱ្យបានខ្ជាប់ខ្ជួនដល់បទបញ្ញាត្តិនៃសន្ធិសញ្ញាដែលកម្ពុជាបានទទួលស្គាល់ រួមទាំងអនុសញ្ញាស្តីពីសិទ្ធិកុមារផង ។

## គណៈកម្មាធិការសិទ្ធិកុមារ

ដោយបានក្លាយខ្លួនជារដ្ឋភាគីនៃអនុសញ្ញា រដ្ឋនោះត្រូវធ្វើការប្តេជ្ញាចិត្ត ដោយភ្ជាប់កាតព្វកិច្ចផ្លូវច្បាប់ចំពោះប្រជាពលរដ្ឋរបស់ខ្លួន ជាពិសេសដល់កុមារ ព្រមទាំងសហគមន៍អន្តរជាតិ ពីការអនុវត្តបទបញ្ញាត្តទាំងឡាយនៃអនុសញ្ញានេះ ដើម្បីលើកស្ទួយ និងការពារសិទ្ធិកុមារ។

យោងតាមអនុសញ្ញានេះ គណៈកម្មាធិការអន្តរជាតិមួយ ដែលមានអ្នកជំនាញការឯករាជ្យ ហើយដែលគេស្គាល់ជាទូទៅថាគណៈកម្មាធិការសិទ្ធិកុមារ ត្រូវបានបង្កើតឡើង ដើម្បីតាមដានការវិវត្តន៍របស់រដ្ឋភាគី ក្នុងការបំពេញតាមការប្តេជ្ញាចិត្តរបស់ខ្លួន។ គ្រប់រដ្ឋភាគី តំរូវឱ្យធ្វើរបាយការណ៍ជាទៀងទាត់តាមកាលកំណត់ជូនគណៈកម្មាធិការ ពីវិធានការដែលខ្លួនប្រកាន់យកដើម្បីអនុវត្តអនុសញ្ញានេះ។

កម្ពុជាបានធ្វើរបាយការណ៍ចំនួនពីរលើករួចមកហើយជូនគណៈកម្មាធិការ។ រាជរដ្ឋាភិបាលកម្ពុជា បានដាក់របាយការណ៍តាមកាលកំណត់លើកទីពីររបស់ខ្លួនជូនគណៈកម្មាធិការ កាលពីខែកុម្ភៈ ឆ្នាំ២០០៩ ហើយគណៈកម្មាធិការនឹងពិនិត្យរបាយការណ៍នេះ នៅពេលណាមួយក្នុងឆ្នាំ២០១០ ឬ២០១១។

# អនុសញ្ញាស្តីពីសិទ្ធិកុមារ

ត្រូវបានអនុម័ត និងបើកឱ្យចុះហត្ថលេខា ឱ្យសច្ចាប័ន និងឱ្យសុំចូលជាសមាជិក
តាមសេចក្តីសម្រេចចិត្តលេខ៤៤/២៥ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩
របស់មហាសន្និបាតអង្គការសហប្រជាជាតិ
ចូលជាធរមាននៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩០ ស្របតាមមាត្រា៤៩

## បុព្វកថា

*រដ្ឋភាគីទាំងអស់នៃអនុសញ្ញានេះ*

*យល់ឃើញថា* យោងតាមគោលការណ៍នានាដែលប្រកាសក្នុងធម្មនុញ្ញសហប្រជាជាតិ ការទទួលស្គាល់សេចក្តីថ្លៃថ្នូរជាប់ពីកំណើត និងសិទ្ធិស្មើភាព និងមិនអាចលក់ ដូរ ផ្ទេរ ឬដកហូតបាន របស់សមាជិកទាំងអស់នៃគ្រួសារមនុស្ស ជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពក្នុងពិភពលោក។

*ចងចាំថា* ប្រជាជាតិនៃសហប្រជាជាតិបានប្រកាសបញ្ជាក់សារជាថ្មីក្នុងធម្មនុញ្ញសហប្រជាជាតិ នូវជំនឿរបស់ខ្លួន ទៅលើសិទ្ធិមូលដ្ឋានរបស់មនុស្ស លើសេចក្តីថ្លៃថ្នូរ និងតម្លៃរបស់មនុស្ស ហើយប្តេជ្ញាលើកស្ទួយវឌ្ឍនភាពសង្គម និងកម្រិតជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើង ក្នុងសេរីភាពកាន់តែទូលំទូលាយ ។

*ទទួលស្គាល់ថា* ក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិនានាស្តីពីសិទ្ធិមនុស្ស សហប្រជាជាតិបានប្រកាស និងយល់ស្របថា មនុស្សគ្រប់រូបត្រូវមានសិទ្ធិ និងសេរីភាពទាំងអស់ ដូចមានចែងនៅ

ក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស ដោយគ្មានការប្រកាន់បែងចែកបែបណាមួយ មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយឬមតិផ្សេងទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពផ្សេងទៀតឡើយ។

*រំលឹកឡើងវិញថា* ក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស សហប្រជាជាតិបានប្រកាសថា កុមារមានសិទ្ធិទទួលជំនួយ និងការថែទាំពិសេស។

*ជឿជាក់ថា* គ្រួសារជាអង្គភាពគ្រឹះនៃសង្គម និងជាមជ្ឈដ្ឋានធម្មជាតិសម្រាប់ការរីកលូតលាស់ និងសុខុមាលភាពនៃសមាជិកទាំងអស់របស់សង្គម និងជាពិសេស កុមារត្រូវទទួលនូវការការពារ និងជំនួយឧបត្ថម្ភចាំបាច់ ដើម្បីឱ្យគ្រួសារអាចរ៉ាប់រងការទទួលខុសត្រូវរបស់ខ្លួនពេញលេញនៅក្នុងសហគមន៍។

*ទទួលស្គាល់ថា* ដើម្បីឱ្យមានការអភិវឌ្ឍន៍ពេញលេញ និងសមស្របតាមបុគ្គលិកលក្ខណៈរបស់កុមារ កុមារត្រូវធំលូតលាស់ក្នុងមជ្ឈដ្ឋានគ្រួសារ ក្នុងបរិយាកាសសុភមង្គល សេចក្តីស្រឡាញ់ និងការយោគយល់។

*យល់ឃើញថា* កុមារ គួរត្រូវបានគេរៀបចំឱ្យមានជីវភាពជាឯកត្តជនក្នុងសង្គម និងធំលូតលាស់ក្នុងស្មារតីនៃឧត្តមគតិ ដូចមានចែងក្នុងធម្មនុញ្ញសហប្រជាជាតិ និងជាពិសេស ក្នុងស្មារតីនៃសន្តិភាព សេចក្តីថ្លៃថ្នូរ ការអត់ឱនឱ្យគ្នា សេរីភាព សមភាព និងសាមគ្គីភាព ។

*ចងចាំថា* ភាពចាំបាច់ដើម្បីផ្តល់ការការពារពិសេសដល់កុមារ ត្រូវបានថ្លែងក្នុងសេចក្តីប្រកាស នាទីក្រុងហ្សឺណែវ ឆ្នាំ១៩២៤ ស្តីពីសិទ្ធិកុមារ និងក្នុងសេចក្តីប្រកាសស្តីពីសិទ្ធិកុមារដែលបានអនុម័តដោយមហាសន្និបាតអង្គការ

សហប្រជាជាតិនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៥៩ ហើយភាពចាំបាច់នេះត្រូវបានទទួលស្គាល់ នៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ជាពិសេសក្នុងមាត្រា២៣ និងមាត្រា២៤) ក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ជាពិសេសក្នុងមាត្រា១០) និងក្នុងលក្ខន្តិកៈ និងលិខិតុបករណ៍ពាក់ព័ន្ធនានារបស់ស្ថាប័នឯកទេស និងអង្គការអន្តរជាតិ ដែលមានកិច្ចការទាក់ទិននឹងសុខុមាលភាពរបស់កុមារ ។

*ចងចាំថា* ដូចបានបញ្ជាក់ក្នុងសេចក្តីប្រកាសស្តីពីសិទ្ធិកុមារ "ដោយសារភាពខ្វះខាងផ្នែករាងកាយ និងសតិបញ្ញា កុមារត្រូវការនូវកិច្ចការពារ និងការថែទាំជាពិសេសរួមទាំងការការពារសមស្របតាមផ្លូវច្បាប់ទាំងមុននិងបន្ទាប់ពីកំណើត"

*រំលឹកឡើងវិញថា* បទប្បញ្ញត្តិនៃសេចក្តីប្រកាសស្តីពីគោលការណ៍ខាងសង្គមកិច្ច និងខាងផ្លូវច្បាប់ទាក់ទងនឹងកិច្ចការពារ និងសុខុមាលភាពរបស់កុមារ សំដៅជាពិសេសទៅរកការទុកដាក់ជាមួយឪពុក-ម្តាយធម៌ និងសុំកូនក្នុងប្រទេស និងអន្តរជាតិ វិធានជាបទដ្ឋានអប្បបរមារបស់សហប្រជាជាតិដើម្បីគ្រប់គ្រងវិស័យយុត្តិធម៌សម្រាប់កុមារ (វិធានក្រុងប៉េកាំង) និងសេចក្តីប្រកាសស្តីពីការការពារស្ត្រី និងកុមារក្នុងពេលមានអាសន្ន និងជម្លោះប្រដាប់អាវុធ។

*ទទួលស្គាល់ថា* នៅក្នុងប្រទេសទាំងអស់លើពិភពលោកមានកុមារកំពុងរស់នៅក្នុងស្ថានភាពដ៏សែនលំបាក ហើយកុមារទាំងនោះ ត្រូវការនូវការយកចិត្តទុកដាក់ពិសេស ។

*យកមកគិតនូវ* សារសំខាន់នៃប្រពៃណី និងតម្លៃវប្បធម៌របស់ប្រជាជាតិនីមួយៗក្នុងការការពារ និងការរីកចម្រើនដោយសុខដុមរបស់កុមារ។

*ទទួលស្គាល់* សារសំខាន់នៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីលើកកំពស់ល័ក្ខខ័ណ្ឌជីវភាពរបស់កុមារនៅគ្រប់ប្រទេស ជាពិសេស ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។

*បានព្រមព្រៀងគ្នាដូចតទៅ :*

## *ផ្នែកទី ១*

### មាត្រា ១

សម្រាប់គោលបំណងនៃអនុសញ្ញានេះ កុមារគឺជាមនុស្សមានអាយុក្រោម ១៨ឆ្នាំ លើកលែងតែក្រោមច្បាប់ដែលត្រូវអនុវត្តចំពោះកុមារ និតិភាពត្រូវបានកំណត់ទាបជាងនេះ ។

### មាត្រា ២

១. រដ្ឋភាគី ត្រូវគោរព និងធានាសិទ្ធិដូចចែងក្នុងអនុសញ្ញានេះដល់កុមារដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយគ្មានការរើសអើងណាមួយ ដោយឥតគិតពីពូជសាសន៍ ពណ៌សម្បុរ ភេទ សាសនា មតិនយោបាយ ឬមតិផ្សេងទៀត ដើមកំណើតជាតិ ដើមកំណើតជនជាតិ ឬសង្គម ទ្រព្យសម្បត្តិ អសមត្ថភាព កំណើត ឬស្ថានភាពផ្សេងទៀតរបស់កុមារ របស់ឪពុក-ម្តាយកុមារ ឬអ្នកអាណាព្យាបាលស្របច្បាប់របស់កុមារ ។

២. រដ្ឋភាគីត្រូវចាត់វិធានការសមស្របទាំងឡាយ ដើម្បីធានាឱ្យកុមារបានទទួលនូវការការពារប្រឆាំងនឹងរាល់ទម្រង់នៃការរើសអើង ឬទណ្ឌកម្មដែលផ្អែក

លើមូលដ្ឋានស្ថានភាព សកម្មភាព ការបញ្ចេញមតិ ឬជំនឿរបស់ឪពុក-ម្តាយ របស់អ្នកអាណាព្យាបាលស្របច្បាប់ ឬសមាជិកគ្រួសាររបស់កុមារ។

មាត្រា ៣

១. នៅក្នុងវិធានការទាំងអស់ដែលពាក់ព័ន្ធនឹងកុមារ ទោះធ្វើឡើងដោយស្ថាប័នឯកជនឬសាធារណៈទទួលភារៈខាងសុខុមាលភាពសង្គមឬដោយតុលាការ ឬអាជ្ញាធររដ្ឋបាល ឬអង្គការនីតិបញ្ញត្តិក៏ដោយ ឧត្តមប្រយោជន៍របស់កុមារ ត្រូវតែយកចិត្តទុកដាក់ជាចម្បង ។

២. រដ្ឋភាគីសន្យាធានាដល់កុមារនូវការការពារ និងការថែទាំចាំបាច់ដើម្បីសុខុមាលភាពរបស់កុមារ ដោយយកមកគិតនូវ សិទ្ធិ និងករណីយកិច្ចរបស់ឪពុក-ម្តាយ អ្នកអាណាព្យាបាល ឬបុគ្គលផ្សេងទៀតដែលទទួលខុសត្រូវតាមផ្លូវច្បាប់ចំពោះកុមារ និងដើម្បីសម្រេចទិសដៅនេះ រដ្ឋភាគីត្រូវចាត់វិធានការខាងនីតិបញ្ញត្តិ និងរដ្ឋបាលដែលសមស្របទាំងអស់ ។

៣. រដ្ឋភាគីត្រូវធានាថា ស្ថាប័ន សេវាកម្ម និងគ្រឹះស្ថានដែលមានបន្ទុកថែទាំ ឬការពារកុមារ ត្រូវធ្វើតាមបទដ្ឋានកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ចជាពិសេសនៅក្នុងវិស័យនៃសុវត្ថិភាព សុខភាព អំពីចំនួន និងភាពសមស្របនៃបុគ្គលិក ព្រមទាំងសមត្ថកិច្ចគ្រប់គ្រង ។

មាត្រា ៤

រដ្ឋភាគីសន្យាចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាលនិងវិធានការផ្សេងទៀត ដើម្បីអនុវត្តសិទ្ធិទាំងឡាយដែលទទួលស្គាល់ក្នុងអនុសញ្ញានេះ។ ចំពោះសិទ្ធិខាងសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ រដ្ឋភាគី ត្រូវចាត់វិធានការក្នុងកម្រិត

អតិបរមានៃធនធានដែលខ្លួនមាន និងបើចាំបាច់ ក្នុងក្របខ័ណ្ឌនៃសហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ៥

រដ្ឋភាគី ត្រូវគោរពតួនាទី សិទ្ធិ និងករណីយកិច្ចរបស់ឪពុកម្ដាយ ឬបើសមស្រប ត្រូវគោរពតួនាទី សិទ្ធិ និងករណីយកិច្ចរបស់សមាជិកគ្រួសារជាសាខាញាតិឬសហគមន៍ អាស្រ័យតាមទំនៀមទម្លាប់នៅមូលដ្ឋាន អ្នកអាណាព្យាបាលស្របច្បាប់ ឬជនផ្សេងទៀតដែលមាននាទីតាមផ្លូវច្បាប់លើកុមារ ក្នុងការតម្រង់ទិស និងការណែនាំសមស្របតាមសមត្ថភាពរបស់កុមារ ដើម្បីឱ្យកុមារប្រើប្រាស់សិទ្ធិទាំងឡាយដែលទទួលស្គាល់ក្នុងអនុសញ្ញានេះ ។

មាត្រា ៦

១. រដ្ឋភាគីទទួលស្គាល់ថា កុមារគ្រប់រូប មានសិទ្ធិមានជីវិតជាប់ពីកំណើត។

២. រដ្ឋភាគី ត្រូវធានាក្នុងកម្រិតអតិបរមា តាមដែលអាចធ្វើទៅបាន ចំពោះការរស់រាន និងការលូតលាស់របស់កុមារ ។

មាត្រា ៧

១. កុមារត្រូវបានចុះក្នុងសៀវភៅអត្រានុកូលដ្ឋានភ្លាម បន្ទាប់ពីពេលកើត និងត្រូវមានសិទ្ធិមានឈ្មោះមួយ ពីពេលកើតមក មានសិទ្ធិទទួលបានសញ្ជាតិមួយ និងតាមដែលអាចធ្វើទៅបាន កុមារត្រូវមានសិទ្ធិស្គាល់ឪពុក-ម្ដាយ និងទទួលការថែទាំពីឪពុក-ម្ដាយ ។

២. រដ្ឋភាគីត្រូវធានាការអនុវត្តសិទ្ធិទាំងនេះ ស្របតាមច្បាប់ជាតិ និងកាតព្វកិច្ចក្រោមលិខិតុបករណ៍អន្តរជាតិក្នុងវិស័យនេះ ពិសេសក្នុងករណីដែលកុមារនឹងក្លាយជាជនឥតស្រុកទេស បើគ្មានការអនុវត្តនោះទេ ។

## មាត្រា ៨

១. រដ្ឋភាគីសន្យាគោរពសិទ្ធិរក្សាអត្តសញ្ញាណរបស់កុមារ រួមមានសញ្ជាតិ ឈ្មោះ និងទំនាក់ទំនងគ្រួសារផង ដូចបានទទួលស្គាល់ក្នុងច្បាប់ ដោយគ្មានការជ្រៀតជ្រែកដោយខុសច្បាប់ឡើយ ។

២. បើកុមារម្នាក់ត្រូវរងការដកហូតដោយខុសច្បាប់ នូវធាតុមួយចំនួន ឬទាំងអស់នៃអត្តសញ្ញាណរបស់ខ្លួននោះ រដ្ឋភាគី ត្រូវផ្តល់ជំនួយ និងការការពារសមស្រប ដើម្បីស្តារអត្តសញ្ញាណរបស់កុមារឡើងវិញឱ្យបានឆាប់រហ័ស ។

## មាត្រា ៩

១. រដ្ឋភាគីត្រូវធានាថា កុមារមិនត្រូវបានបំបែកចេញពីឪពុក-ម្តាយ ផ្ទុយពីឆន្ទៈរបស់កុមារឡើយ លើកលែងតែអាជ្ញាធរមានសមត្ថកិច្ច ដែលស្ថិតក្រោមការពិនិត្យរបស់តុលាការសម្រេចស្របតាមច្បាប់ និងនីតិវិធី ថាការបំបែកនេះគឺចាំបាច់សម្រាប់ឧត្តមប្រយោជន៍របស់កុមារ។ សេចក្តីសម្រេចនេះអាចចាំបាច់តែក្នុងករណីពិសេស មានជាអាទិ៍ ឪពុក-ម្តាយធ្វើបាប ឬទុកចោលមិនយកចិត្តទុកដាក់ ឬឪពុក-ម្តាយមិនរស់នៅជាមួយគ្នា ហើយសេចក្តីសម្រេចនេះ ត្រូវធ្វើដោយគិតពីកន្លែងស្នាក់នៅរបស់កុមារ ។

២. នៅគ្រប់នីតិវិធីស្របតាមកថាខណ្ឌ១ នៃមាត្រានេះ ភាគីពាក់ព័ន្ធទាំងអស់ ត្រូវបានផ្តល់ឱកាសឱ្យចូលរួមក្នុងនីតិវិធីទាំងនោះ និងឱ្យបង្ហាញពីទស្សនៈរបស់ខ្លួន។

៣. រដ្ឋភាគី ត្រូវគោរពសិទ្ធិរបស់កុមារដែលត្រូវបំបែកពីឪពុក ឬម្តាយ ឬឪពុក-ម្តាយទាំងពីរ ក្នុងការរក្សាជាទៀងទាត់ នូវទំនាក់ទំនងផ្ទាល់ខ្លួន និងការ

ទាក់ទងដោយផ្ទាល់ជាមួយឪពុក-ម្ដាយ លើកលែងតែប្រការនេះផ្ទុយនឹងឧត្ដម ប្រយោជន៍របស់កុមារ ។

៤. បើការរស់នៅបែកគ្នាបណ្ដាលមកពីវិធានការណាមួយផ្ដើមដោយរដ្ឋភាគី មានជាអាទិ៍ ការឃាត់ឬការឃុំខ្លួន ការដាក់ពន្ធនាគារ ការនិរទេស ការបំបរបង់ ឬមរណភាព (រួមទាំងមរណភាពបណ្ដាលមកពីបុព្វហេតុណាមួយក្នុងខណៈពេលដែលបុគ្គលនោះត្រូវបានឃាត់ ឬឃុំខ្លួនដោយរដ្ឋ) ឪពុកឬ ម្ដាយ ឬឪពុក-ម្ដាយទាំងពីរ ឬកុមារ នោះរដ្ឋភាគី ដោយយោងតាមការស្នើសុំ ត្រូវជូនដំណឹងទៅឪពុក-ម្ដាយ ឬកុមារ ឬបើសមស្រប ត្រូវជូនដំណឹងទៅសមាជិកគ្រួសារណាម្នាក់ផ្សេងទៀត នូវព័ត៌មានសំខាន់អំពីទីកន្លែងនៃសមាជិកគ្រួសារណាម្នាក់ ឬច្រើននាក់ដែលអវត្តមាន លើកលែងតែការជូនដំណឹងនេះ ប៉ះពាល់ដល់ផាសុខភាពរបស់កុមារ។ ម៉្យាងទៀត រដ្ឋភាគីត្រូវធានាថា ការដាក់សេចក្ដីស្នើសុំមួយបែបនេះ នឹងមិននាំឱ្យមានផលជាអវិជ្ជមានសម្រាប់បុគ្គលពាក់ព័ន្ធឡើយ ។

**មាត្រា ១០**

១. ស្របតាមកាតព្វកិច្ចរបស់រដ្ឋភាគី ក្រោមមាត្រា៩ កថាខណ្ឌ១ គ្រប់សេចក្ដីស្នើសុំរបស់កុមារ ឬឪពុក ឬម្ដាយរបស់កុមារ ដើម្បីចូល ឬចាកចេញពីរដ្ឋភាគី ក្នុងគោលបំណងជួបជុំគ្រួសារ ត្រូវតែដោះស្រាយក្នុងស្មារតីវិជ្ជមាន មនុស្សធម៌ និងឱ្យបានឆាប់រហ័ស ។ ក្រៅពីនេះ រដ្ឋភាគីត្រូវធានាថា ការដាក់សេចក្ដីស្នើសុំនេះនឹងមិនបង្កឱ្យមានផលអវិជ្ជមានដល់អ្នកសុំ និងដល់សមាជិកគ្រួសាររបស់អ្នកសុំឡើយ ។

២. កុមារដែលមានឪពុក-ម្ដាយរស់នៅក្នុងរដ្ឋផ្សេង មានសិទ្ធិរក្សាជា

ទៀងទាត់នូវទំនាក់ទំនងផ្ទាល់ និងការទាក់ទងដោយផ្ទាល់ ជាមួយឪពុក-ម្តាយទាំងពីរ លើកលែងតែក្នុងកាលៈទេសៈពិសេស។ ក្នុងទិសដៅនេះ និងស្របតាមកាតព្វកិច្ចរបស់រដ្ឋភាគី ក្រោមមាត្រា៩ កថាខណ្ឌ១ រដ្ឋភាគីត្រូវគោរពសិទ្ធិរបស់កុមារ និងសិទ្ធិឪពុក-ម្តាយរបស់កុមារក្នុងការចាកចេញពីប្រទេស រួមមានប្រទេសរបស់ខ្លួនផង និងវិលចូលមកក្នុងប្រទេសរបស់ខ្លួនវិញ។ សិទ្ធិចាកចេញពីប្រទេសណាមួយ អាចស្ថិតក្រោមការរិតត្បិតបាន លុះត្រាតែការរិតត្បិតនោះ បញ្ញត្តិដោយច្បាប់ និងចាំបាច់ដើម្បីការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាព ឬសីលធម៌សាធារណៈ ឬសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ ហើយស្របនឹងសិទ្ធិផ្សេងទៀតដែលទទួលស្គាល់ដោយអនុសញ្ញានេះ។

### មាត្រា ១១

១. រដ្ឋភាគី ត្រូវចាត់វិធានការប្រយុទ្ធប្រឆាំងនឹងការផ្ទេរកុមារចេញក្រៅប្រទេស ដោយខុសច្បាប់ និងការមិនប្រគល់កុមារពីក្រៅប្រទេសមកវិញ ។

២. ក្នុងទិសដៅនេះ រដ្ឋភាគី ត្រូវសម្រួលដល់ការចុះកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគី ឬចូលជាសមាជិកក្នុងកិច្ចព្រមព្រៀងដែលមានស្រាប់ ។

### មាត្រា ១២

១. រដ្ឋភាគីត្រូវធានាអះអាងដល់កុមារដែលមានសមត្ថភាពបង្កើតទស្សនៈផ្ទាល់ខ្លួន នូវសិទ្ធិបញ្ចេញទស្សនៈទាំងនោះដោយសេរី លើគ្រប់បញ្ហាពាក់ព័ន្ធនឹងកុមារ។ ទស្សនៈទាំងនេះរបស់កុមារ ត្រូវបានយកទៅពិចារណាថ្លឹងថ្លែងដោយគិតទៅតាមវ័យ និងភាពចាស់ទុំរបស់កុមារ ។

២. ក្នុងទិសដៅនេះ កុមារត្រូវបានផ្តល់ជាពិសេស នូវឱកាសត្រូវបានគេ

ស្តាប់នៅក្នុងនីតិវិធីតុលាការ និងរដ្ឋបាលដែលពាក់ព័ន្ធនឹងកុមារ ទោះដោយផ្ទាល់ ឬតាមរយៈអ្នកតំណាង ឬស្ថាប័នសមស្របណាមួយ ស្របតាមបទប្បញ្ញត្តិនីតិវិធីនៃច្បាប់ជាតិ ។

### មាត្រា ១៣

១. កុមារមានសិទ្ធិសម្តែងមតិដោយសេរី។ សិទ្ធិនេះ រាប់បញ្ចូលទាំងសេរីភាព ស្រាវជ្រាវ ទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតគ្រប់ប្រភេទ ដោយគ្មានគិតពីព្រំដែន ទោះជាតាមទម្រង់ផ្ទាល់មាត់ សរសេរ ឬបោះពុម្ព ទម្រង់សិល្បៈ ឬតាមគ្រប់គ្រឿងផ្សព្វផ្សាយព័ត៌មានផ្សេងទៀត តាមការជ្រើសរើសរបស់កុមារ។

២. ការប្រើប្រាស់សិទ្ធិនេះ អាចស្ថិតក្រោមការរិតត្បិតខ្លះបាន លុះត្រាតែការរិតត្បិតទាំងនេះ ត្រូវបានអនុញ្ញាតដោយច្បាប់ និងមានលក្ខណៈចាំបាច់ដូចខាងក្រោម:

(ក) ដើម្បីគោរពសិទ្ធិនិងកិត្តិនាមរបស់អ្នកដទៃ ឬ

(ខ) ដើម្បីការពារសន្តិសុខជាតិ ឬសណ្តាប់ធ្នាប់ សុខភាព ឬសីលធម៌សាធារណៈ ។

### មាត្រា ១៤

១. រដ្ឋភាគី ត្រូវគោរពសិទ្ធិកុមារក្នុងការមានសេរីភាពគិតគូរ សេរីភាពខាងសតិសម្បជញ្ញៈ និងសេរីភាពខាងសាសនា ។

២. រដ្ឋភាគីត្រូវគោរពសិទ្ធិ និងករណីយកិច្ចរបស់ឪពុក-ម្តាយ និងបើសមស្រប អ្នកអាណាព្យាបាលស្របច្បាប់របស់កុមារ ក្នុងការនាំផ្លូវកុមារឱ្យប្រើប្រាស់សិទ្ធិកុមារ ស្របតាមសមត្ថភាពវិវត្តទៅមុខរបស់កុមារ។

៣. សេរីភាពសម្តែងសាសនា ឬជំនឿរបស់កុមារ អាចស្ថិតក្រោមការរិតត្បិតបាន ដរាបណាមានបញ្ញត្តិដោយច្បាប់ និងចាំបាច់ដើម្បីការពារសុវត្ថិភាព សណ្តាប់ធ្នាប់ សុខភាព និងសីលធម៌សាធារណៈ ឬសិទ្ធិ និងសេរីភាពមូលដ្ឋានរបស់អ្នកដទៃ ។

មាត្រា ១៥

១. រដ្ឋភាគី ទទួលស្គាល់សិទ្ធិកុមារមានសេរីភាពខាងសមាគម និងមានសេរីភាពប្រជុំដោយសន្តិវិធី ។

២. ការប្រើប្រាស់សិទ្ធិទាំងនេះ អាចស្ថិតក្រោមការរិតត្បិតបាន លុះត្រាតែមានបញ្ញត្តិដោយច្បាប់ និងចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ ដើម្បីអត្ថប្រយោជន៍នៃសន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ ឬសណ្តាប់ធ្នាប់សាធារណៈ ឬដើម្បីការពារសុខភាព ឬសីលធម៌សាធារណៈ ឬដើម្បីការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ ។

មាត្រា ១៦

១. គ្មានកុមារណាម្នាក់ត្រូវស្ថិតក្រោមការជ្រៀតជ្រែកតាមអំពើចិត្ត ឬដោយខុសច្បាប់ក្នុងជីវិតឯកជន គ្រួសារ លំនៅដ្ឋាន ឬការឆ្លើយឆ្លងរបស់កុមារ និងគ្មានកុមារណាម្នាក់ ត្រូវស្ថិតក្រោមការបំពារបំពានដោយខុសច្បាប់លើកិត្តិយស និងកិត្តិនាមរបស់ខ្លួនឡើយ ។

២. កុមារមានសិទ្ធិទទួលបានការការពារដោយច្បាប់ ប្រឆាំងនឹងការជ្រៀតជ្រែក ឬការបំពារបំពានទាំងនេះ ។

មាត្រា ១៧

រដ្ឋភាគីទទួលស្គាល់សារសំខាន់នៃមុខងារផ្សព្វផ្សាយតាមប្រព័ន្ធឃោសនា

និងត្រូវធានាឱ្យកុមារមានសិទ្ធិទទួលបានព័ត៌មាន និងឯកសារឬសម្ភារៈពីប្រភពផ្សេងៗរបស់ជាតិ និងអន្តរជាតិ ជាពិសេស ព័ត៌មាន និងទិន្នន័យដែលសំដៅលើកស្ទួយសុខុមាលភាព ខាងសង្គម ស្មារតី និងសីលធម៌របស់កុមារ ព្រមទាំងសុខភាពផ្នែករាងកាយនិងសតិបញ្ញារបស់កុមារ។ ក្នុងទិសដៅនេះរដ្ឋភាគីត្រូវៈ

(ក) ជំរុញប្រព័ន្ធឃោសនា ឱ្យផ្សព្វផ្សាយព័ត៌មាន និងឯកសារ ឬសម្ភារៈ បង្ហាញពីអត្ថប្រយោជន៍ខាងសង្គម និងវប្បធម៌ដល់កុមារ និងស្របតាមស្មារតីនៃមាត្រា២៩ ។

(ខ) ជំរុញសហប្រតិបត្តិការអន្តរជាតិ ដើម្បីផលិត ផ្លាស់ប្តូរ និងផ្សាយព័ត៌មាន និងឯកសារឬសម្ភារៈដែលចេញមកពីប្រភពប្លែកៗគ្នាខាងវប្បធម៌ជាតិ និងអន្តរជាតិ។

(គ) ជំរុញការផលិត និងការផ្សព្វផ្សាយសៀវភៅសម្រាប់កុមារ ។

(ឃ) ជំរុញប្រព័ន្ធឃោសនា ឱ្យគិតគូរជាពិសេសដល់សេចក្តីត្រូវការផ្នែកភាសារបស់កុមារ ដែលជាសមាជិកក្រុមជនជាតិភាគតិច ឬជាសមាជិកជនអន្តោប្រវេសន៍ ។

(ង) ជំរុញការកសាងគោលការណ៍ដឹកនាំសមស្រប សំដៅការពារកុមារឱ្យផុតពីព័ត៌មាន និងឯកសារ ឬសម្ភារៈដែលបំផ្លាញសុខុមាលភាពកុមារ ដោយយោងទៅលើបទប្បញ្ញត្តិនៃមាត្រា១៣ និងមាត្រា១៨ ។

## មាត្រា ១៨

១. រដ្ឋភាគីត្រូវប្រឹងប្រែងឱ្យអស់ពីលទ្ធភាព ដើម្បីធានាការទទួលស្គាល់គោលការណ៍ដែលថា ឪពុក-ម្តាយទាំងពីរមានការទទួលខុសត្រូវរួមក្នុងការចិញ្ចឹមបីបាច់ និងធ្វើឱ្យកុមារមានការអភិវឌ្ឍន៍។ ការទទួលខុសត្រូវបឋមក្នុងការចិញ្ចឹម

បីបាច់កុមារ និងធ្វើឱ្យកុមារមានការអភិវឌ្ឍន៍ ត្រូវស្ថិតនៅលើឪពុក-ម្ដាយ ឬបើពុំនោះទេ អ្នកអាណាព្យាបាលស្របច្បាប់របស់កុមារ។ ពួកគេនេះ ត្រូវគិតមុនបង្អស់ដល់ឧត្ដមប្រយោជន៍របស់កុមារ ។

២. ដើម្បីធានា និងលើកស្ទួយសិទ្ធិដូចចែងក្នុងអនុសញ្ញានេះ រដ្ឋភាគីត្រូវផ្ដល់ជំនួយសមស្របដល់ឪពុក-ម្ដាយ និងអ្នកអាណាព្យាបាលស្របច្បាប់របស់កុមារ ដើម្បីបំពេញតួនាទីចិញ្ចឹមអប់រំកុមារ និងធានាដល់ការបង្កើតឱ្យមានស្ថាប័ន គ្រឹះស្ថាន និងសេវាកម្មទទួលបន្ទុកថែទាំកុមារ ។

៣. រដ្ឋភាគីត្រូវចាត់វិធានការសមស្របទាំងអស់ ធានាដល់កុមារដែលមានឪពុក-ម្ដាយជាអ្នកធ្វើការ នូវសិទ្ធិទទួលអត្ថប្រយោជន៍ពីសេវាកម្ម និងគ្រឹះស្ថានគាំពារកុមារ ដែលកុមារមានលក្ខណៈសម្បត្តិអាចទទួលបាន ។

# អនុក្រឹត្យលេខ៥៧
# ស្តីពីការបញ្ជូនពលករខ្មែរទៅធ្វើ
# ការនៅបរទេស១៩៩៥

00001

ព្រះរាជាណាចក្រ កម្ពុជា

Kingdom of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

ាភិបាល កម្ពុជា

l Government of Cambodia

ខ: ៥៧ អនក្រ-បក

# អនុក្រឹត្យ

ស្តីពី

## ការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស

---

រាជរដ្ឋាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ការងារដែលប្រកាសអោយប្រើដោយក្រឹត្យលេខ៩៩ក្រ ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ១៩៩២

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តមសីហនុវរ្ម័នព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តមសីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា

-តាមសំណើរបស់រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ។

### សំ រេ ច :

<u>មាត្រា១</u> : ដើម្បីដោះស្រាយជីវភាព និងបង្កើនមុខជំនាញវិជ្ជាជីវៈ រាជរដ្ឋាភិបាលអនុញ្ញាតអោយបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស នៅពេលដែលទីផ្សារការងារក្នុងប្រទេសមិនទាន់មានលទ្ធភាពទទួលយកអ្នកគ្មានការងារធ្វើ និងអ្នកដែលមានការងារធ្វើមិនពេញលេញបានអស់ និង រកប្រាក់ចំណូលចូលថវិកាជាតិ ។

<u>មាត្រា២</u> : ការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស និងការគ្រប់គ្រងពលករទាំងនេះជាសមត្ថកិច្ចរបស់ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ។

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន អាចអនុញ្ញាតតាមប្រកាសរបស់ក្រសួងឲ្យក្រុមហ៊ុនណាមួយបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសបាន ។

ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ត្រូវចេញសារាចរណែនាំនីតិវិធីបន្ថែមទៀតក្នុងករណីចាំបាច់ ។

ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ត្រូវសហការជាមួយក្រសួងមហាផ្ទៃ ក្នុងការធ្វើទំរង់បែបបទដូចជាលិខិតឆ្លងដែនជាដើម ដើម្បីបញ្ជូនពលករទៅបរទេស ហើយត្រូវសហការជាមួយក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិក្នុងការគ្រប់គ្រងពលករខ្មែរដែលធ្វើការនៅបរទេស ។

មាត្រា ៣ : ត្រូវបានចាត់ទុកជាបេក្ខជនសំរាប់ជ្រើសរើសបញ្ជូនឲ្យទៅធ្វើការនៅបរទេស ពលករខ្មែរទាំងពីរភេទមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ ដែលបានដាក់ពាក្យសុំរកការងារធ្វើនៅក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ។

មាត្រា ៤ : ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ហៅថាភាគីផ្តល់ពលករ ។ ក្រុមហ៊ុនដែលជ្រើសរើសពលករ ហៅថាភាគីទទួលពលករ ។

មាត្រា ៥ : ពាក្យសុំរបស់ភាគីទទួលពលករ ត្រូវបញ្ជាក់ឲ្យច្បាស់លាស់អំពីល័ក្ខខ័ណ្ឌសំខាន់ៗដូចតទៅ

- កាលបរិច្ឆេទចាប់ផ្តើមអនុវត្ត និង បញ្ចប់ការងារ
- ប្រភេទការងារ
- ទីកន្លែងទៅធ្វើការងារ
- ចំនួន និងមុខជំនាញរបស់ពលករ
- ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗ ដោយគិតទាំងការស្នាក់នៅ ហូបចុក សៀកពាក់ ព្យាបាល ព្រមទាំងបញ្ហាផ្សេងៗទៀតក្នុងជីវភាពប្រចាំថ្ងៃ
- ការដឹកជញ្ជូនពលករទៅ និងមក ។

ក្រោយពីបានទទួលសំណើ ភាគីផ្តល់ពលករត្រូវឆ្លើយទៅភាគីទទួលពលករវិញយ៉ាងយូរបំផុត ៤៥ថ្ងៃដោយត្រូវបញ្ជាក់ថា តើអាចផ្តល់ពលករបានតាមសំណើ ឬមិនបាន ឬត្រូវពិភាក្សាគ្នាបន្ថែមទៀត ។

ភាគីទទួលពលករ ត្រូវឆ្លើយមកភាគីផ្តល់ពលករវិញយ៉ាងយូរ៣០ថ្ងៃ ថាតើត្រូវការពលករទាំងអស់នោះឬទេ ឬត្រូវការតែកំរិតណាមួយនោះដោយត្រូវចូលមកពិភាក្សានៅពេលជាមួយគ្នានេះដែរ ។ ហួសរយៈពេល៣០ថ្ងៃ ហើយបើគ្មានចម្លើយ និងមិនឃើញចូលមកពិភាក្សាទេភាគីផ្តល់ពលករកំណត់ថាភាគីទទួលពលករមិនត្រូវការពលករទាំងនោះទេ ។

<u>មាត្រា៦</u> : ការបញ្ជូនពលករទៅបរទេសអាចអនុវត្តបាន លុះត្រាតែមានការអនុញ្ញាតពីភាគីផ្តល់ពលករនិងត្រូវមានកិច្ចសន្យាការងាររវាងពលករ ជាមួយភាគីទទួលពលករ ។

<u>មាត្រា៧</u> : ក្រោយពេលទទួលការអនុញ្ញាតជាផ្លូវការរយៈពេល៧ថ្ងៃយ៉ាងយូរ ភាគីទទួលពលករត្រូវតំកល់ប្រាក់ធានាចំនួនមួយរយពាន់ដុល្លារអាមេរិកនៅក្នុងគណនីរបស់ភាគីផ្តល់ពលករ ។ បើភាគីទទួលពលករមិនបានបង់ប្រាក់ធានានេះទេ ការអនុញ្ញាតនេះនឹងត្រូវចាត់ទុកជាមោឃៈ ។

ប្រាក់តំកល់នេះ សំរាប់ឲ្យភាគីផ្តល់ពលករបើកឲ្យពលករជំនួសភាគីទទួលពលករ ក្នុងករណីដែលភាគីនោះមិនបានគោរពល័ក្ខខ័ណ្ឌណាមួយដែលមានចែងក្នុងកិច្ចសន្យាការងារ ។

ក្នុងពេលអនុវត្តកិច្ចសន្យាការងារ បើប្រាក់តំកល់នេះត្រូវបានដកខ្លះ ដើម្បីឲ្យពលករ ភាគីទទួលពលករត្រូវបង់បំពេញឲ្យបានគ្រប់ចំនួនឡើងវិញ ។

ភាគីទទួលពលករអាចដកប្រាក់តំកល់នេះមកវិញបាននៅពេលចប់កិច្ចសន្យាការងារជាស្ថាពរជាមួយពលករទាំងអស់ ។

ប្រាក់តំកល់ក្នុងមាត្រានេះ អាចបន្ធូរបន្ថយបានចំពោះនិយោជក ដែលត្រូវការជ្រើសរើសពលករខ្មែរ តែបន្តិចបន្តួចដោយផ្ទាល់ដើម្បីយក [illegible] ធ្វើការក្នុងរោងចក្រ ឬរោងសិប្បកម្មរបស់ខ្លួន ប៉ុន្តែនិយោជកនោះ ចាំបាច់ត្រូវពិភាក្សាជាមួយក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ដើម្បីធ្វើកិច្ចសន្យាឯកត្តភូតជាមួយពលករទាំងនោះ ។

<u>មាត្រា៨</u> : ភាគីទទួលពលករត្រូវបង់សោហ៊ុយសេវា និងការរៀបចំឯកសារផ្សេងៗជូនភាគីផ្តល់ពលករតាមការឯកភាពគ្នាដែលមានកំណត់ក្នុងកិច្ចសន្យា ។

ប្រការ១៣ : នៅពេលចុះកិច្ចសន្យាការងារ ពលករម្នាក់ៗត្រូវផ្តល់ ៖

- ជីវប្រវត្តិសង្ខេបរបស់សាមីជនមានបិទរូបថត ៤×៦ ស.ម  ២ សន្លឹក
- សំបុត្រថ្កោលទោស  ២ ច្បាប់
- លិខិតបញ្ជាក់សុខភាព ដែលចេញឲ្យដោយនាយកដ្ឋានពេទ្យការងារ  ២ ច្បាប់
- សេចក្តីចម្លងសញ្ញាប័ត្រ ឬលិខិតបញ្ជាក់មុខជំនាញ "បើសិនជាមាន"  ២ ច្បាប់
- សេចក្តីចម្លងលិខិតឆ្លងដែនរបស់សាមីជន  ២ ច្បាប់
- ប័ណ្ណសុំការងារ  ១ ច្បាប់

ប្រការ១៤ : មុនពេលចេញដំណើរទៅបរទេសភាគីផ្តល់ពលករនិងទទួលពលករ ត្រូវទទួលបន្ទុករៀបចំធ្វើកម្មសិក្សាអំពីរបៀបរបបធ្វើការងារ របៀបរបបរស់នៅទំនៀមទំលាប់ប្រពៃណី និងច្បាប់ទំលាប់ជាចាំបាច់របស់ប្រទេសទទួលពលករ ។

ប្រការ១៥ : ប្រាក់បៀវត្សរបស់ពលករម្នាក់ៗត្រូវជាប់ពន្ធតាមច្បាប់ជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ១៦ : ភាគីទទួលពលករ ត្រូវរ៉ាប់រងចេញសោហ៊ុយចំណាយឲ្យមន្ត្រីរបស់ប្រទេសផ្តល់ពលករទៅបំពេញបេសកកម្ម ដើម្បីជូនពលករទៅដល់ប្រទេសទទួលពលករត្រួតពិនិត្យល័ក្ខខ័ណ្ឌការងារ ទីកន្លែងធ្វើការងារ និងទីស្នាក់អាស្រ័យរបស់ពលករដែលបានកំណត់ក្នុងកិច្ចសន្យា ។

ភាគីផ្តល់ពលករ ត្រូវបញ្ជូនមន្ត្រីទៅពិនិត្យការអនុវត្តន៍កិច្ចសន្យាការងារដល់ទីកន្លែងក្នុងរយៈពេលដែលចាំបាច់ ។

ប្រការ១៧ : បើមានវិវាទការងារកើតឡើង ភាគីទទួលពលករត្រូវពិភាក្សានិងដោះស្រាយជាមួយពលករភ្លាម ដោយផ្អែកទៅលើកិច្ចសន្យាការងារ ។ បើការពិភាក្សាគ្នានេះមិនអាចសំរុះសំរួលគ្នាបានទេនោះ គេត្រូវផ្តល់ពត៌មានភ្លាមទៅស្ថានឯកអគ្គរាជទូត ឬ បេសកកម្មទូតរបស់ព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសនោះ ដើម្បីចូលរួមដោះស្រាយ ។

ប្រការ១៨ : ភាគីទទួលពលករ ត្រូវផ្តល់ពត៌មានដល់ភាគីផ្តល់ពលករឲ្យបាន ៤៥ ថ្ងៃមុនកាលបរិច្ឆេទនៃការវិលត្រឡប់មកមាតុប្រទេសវិញពិតប្រាកដរបស់ពលករ ។

ភាគីទទួលពលករ និងភាគីផ្តល់ពលករត្រូវរៀបចំរួមគ្នាអំពីប្រតិទិន នៃការធ្វើមាតុភូមិនិវត្តន៍របស់ពលករ ។

__ប្រការ១៩__ : ការបាត់ខ្លួនរបស់ពលករនៅក្នុងរយៈពេលអនុវត្តកិច្ចសន្យាការងារ ភាគីទទួលពលករត្រូវផ្តល់ព័ត៌មានជាបន្ទាន់ដល់ស្ថានឯកអគ្គរាជទូត ឬ បេសកកម្មទូតរបស់ព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសនោះ និងមកក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន នៃព្រះរាជាណាចក្រកម្ពុជា ។

__ប្រការ២០__ : ជនណាដែលបញ្ជូនពលករខ្មែរ ទៅធ្វើការនៅបរទេសដោយល្មើសនឹងបទបញ្ញត្តិទាំងឡាយក្នុងអនុក្រឹត្យនេះត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

__ប្រការ២១__ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

__ប្រការ២២__ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២



នរោត្តម រណឫទ្ធិ ហ៊ុន សែន

__កន្លែងទទួល__ :
- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រីទី១
- ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រីទី២
- ដូចមាត្រា ២២ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# អនុក្រឹត្យស្តីពី
# ការផ្តល់លិខិតឆ្លងដែនធម្មតា
# ជូនពលករ ពលការនី និស្សិតខ្មែរ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ២០៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្តល់លិខិតឆ្លងដែនធម្មតា ជូន ពលករ ពលការិនី និងសិស្ស និស្សិតខ្មែរ

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១.-**

ត្រូវបានផ្តល់លិខិតឆ្លងដែនធម្មតា ជូនពលករ ពលការិនីខ្មែរ ដែលត្រូវទៅធ្វើការដោយស្របច្បាប់ នៅបរទេស ដោយអាករជាបន្ទុករបស់រដ្ឋ ប៉ុន្តែ ពលករ ពលការិនី ត្រូវបង់ប្រាក់ចំនួន ៤ (បួន) ដុល្លារអាមេរិក សម្រាប់ថ្លៃថតរូប។

**មាត្រា២.-**

ត្រូវបានផ្តល់លិខិតឆ្លងដែនធម្មតា ជូនសិស្ស និស្សិតខ្មែរ ដែលទទួលបានអាហារូបករណ៍ទៅសិក្សានៅក្រៅប្រទេស ដោយអាករជាបន្ទុករបស់រដ្ឋ ប៉ុន្តែ សិស្ស និងនិស្សិត ត្រូវបង់ប្រាក់ចំនួន ៤ (បួន) ដុល្លារអាមេរិក សម្រាប់ថ្លៃថតរូប។

សំណើសុំផ្តល់លិខិតឆ្លងដែនធម្មតាសម្រាប់សិស្ស និស្សិតខ្មែរ ដែលទទួលបានអាហារូបករណ៍ទៅសិក្សានៅក្រៅប្រទេស ត្រូវមានការបញ្ជាក់ពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៣.-**

លិខិតឆ្លងដែនធម្មតា ត្រូវផ្តល់ជូនពលករ ពលការិនី និងសិស្ស និស្សិតខ្មែរ ក្នុងរយៈពេលយ៉ាងយូរ ២០ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។

**មាត្រា៤.-**

អនុក្រឹត្យលេខ ៥៦៨ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្តល់លិខិតឆ្លងដែនធម្មតា ជូន ពលករ ពលការិនី និងសិស្ស និស្សិតខ្មែរ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ